សាកលវិទ្យាល័យភូមិន្ទកសិកម្ម

ROYAL UNIVERSITY OF AGRICULTURE

មហាវិទ្យាល័យ សេដ្ឋកិច្ចកសិកម្ម និង អភិវឌ្ឍន៍ជនបទ

FACULTY OF AGRICULTURAL ECONOMICS AND RURAL DEVELOPMENT



ឯក ស្រីខួច

EK SREYKHOUCH


# ការសិក្សាអំពីតួនាទីយេនឌ័រក្នុងប្រព័ន្ធកសិកម្ម
# ក្នុងឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ

# THE STUDY ON GENDER ROLES IN FARMING SYSTEMS
# IN TNAOT CHUM COMMUNE, BARAY DISTRICT,
# KOMPONG THOM PROVINCE

ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី១៣
(២០១២-២០១៦)

សារណាបញ្ចប់ការសិក្សា
ភ្នំពេញ, ខែ កញ្ញា ឆ្នាំ២០១៦

សាកលវិទ្យាល័យភូមិន្ទកសិកម្ម

ROYAL UNIVERSITY OF AGRICULTURE

សារណា

THESIS

# ការសិក្សាអំពីតួនាទីយេនឌ័រក្នុងប្រព័ន្ធកសិម្ម ក្នុងឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ

# THE STUDY ON GENDER ROLES IN FARMING SYSTEMS IN TNAOT CHUM COMMUNE, BARAY DISTRICT, KOMPONG THOM PROVINCE

ឯក ស្រីខួច

EK SREYKHOUCH

សារណាថ្នាក់បរិញ្ញាបត្រ ជំនាន់ទី ១៣

ភ្នំពេញ, ខែកញ្ញា ឆ្នាំ ២០១៦

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

3

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សាកលវិទ្យាល័យភូមិន្ទកសិកម្ម

មហាវិទ្យាល័យ សេដ្ឋកិច្ចកសិកម្ម និង អភិវឌ្ឍន៍ជនបទ

3

ឯក ស្រីខួច

EK SREYKHOUCH

ការសិក្សាអំពីតួនាទីយេនឌ័រក្នុងប្រព័ន្ធកសិកម្ម ក្នុងឃុំត្នោតជុំ
ស្រុកបារាយណ៍ ខេត្តកំពង់ធំ

THE STUDY ON GENDER ROLES IN FARMING SYSTEMS
IN TNAOT CHUM COMMUNE, BARAY DISTRICT,
KOMPONG THOM PROVINCE

សមាសភាពគណៈកម្មការមេប្រយោគ

| | | | |
|---|---|---|---|
| ប្រធានគណៈមេប្រយោគ | ៖ | សាស្ត្រាចារ្យបណ្ឌិត | ង៉ោ ប៊ុនថាន |
| អ្នកដឹកនាំ | ៖ | បណ្ឌិត | នាង ម៉ាលីន |
| អ្នកជំនួយការ | ៖ | កញ្ញា | យ៉ើ អាស៊ីគីន |
| | ៖ | កញ្ញា | សឿង លីលី |

ជំនាន់ទី១៣
(២០១២-២០១៦)

សារណាបញ្ចប់ការសិក្សា
ភ្នំពេញ, ខែ កញ្ញា ឆ្នាំ ២០១៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យភូមិន្ទកសិកម្ម

**មហាវិទ្យាល័យ សេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ**

3

3

សារណា

THESIS

ការសិក្សាអំពីតួនាទីយេនឌ័រក្នុងប្រព័ន្ធកសិកម្ម ក្នុងឃុំត្នោតជុំ
ស្រុកបារាយណ៍ ខេត្តកំពង់ធំ
THE STUDY ON GENDER ROLES IN FARMING SYSTEMS
IN TNAOT CHUM COMMUNE, BARAY DISTRICT,
KOMPONG THOM PROVINCE

គណៈកម្មការសារណា

| | | | | |
|---|---|---|---|---|
| អ្នកដឹកនាំ | ៖ | បណ្ឌិត | នាង ម៉ាលីន | ...................................... |
| អ្នកជំនួយការ | ៖ | កញ្ញា | យ៉ើ អាស៊ីគីន | ...................................... |
| | ៖ | កញ្ញា | សឿង លីលី | ...................................... |

ព្រឹទ្ធបុរស ៖ សាស្ត្រាចារ្យរង បូរ៉ា កាជី .........................................

សាកលវិទ្យាល័យភូមិន្ទកសិកម្ម
សាកលវិទ្យាធិការ

ការធានាអះអាងលើសារណា

នាងខ្ញុំ **ឯក ស្រីខួច** សូមធានាអះអាងថា រាល់ទិន្នន័យខ្លឹមសារ និងលទ្ធផលស្រាវជ្រាវទាំងអស់ដែលមានក្នុង សារណាបទនេះ ពិតជាសារណាដែលមានលក្ខណៈស្រាវជ្រាវផ្ទាល់យ៉ាងពិតប្រាកដមែន ដែលពុំបានចតចម្លងពីស្នាដៃរបស់អ្នកដទៃ ហើយក៏មិនត្រូវបានបោះពុម្ពផ្សព្វផ្សាយ ឬបង្ហាញឡើយ។

ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០១៦

**ហត្ថលេខា**

ឯក ស្រីខួច

សេចក្តីថ្លែងអំណរគុណ

ខ្ញុំម្ចាស់ ឯក ស្រីខួច

សូមក្រាបថ្វាយបង្គំ

ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

សូមថ្វាយនូវ ព្រះរាជសព្ទសាធុការពរ ថ្វាយ ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គទ្រង់ប្រកបដោយព្រះរាជសុខភាពបរិបូណ៌ ព្រះបញ្ញាវាងវៃ និង ទ្រង់គង់ប្រថាប់ ជាម្លប់ដ៏ត្រជាក់ដល់ប្រជានុរាស្ត្រ ជានិច្ចនិរន្តរ៍។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ

- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សាកលវិទ្យាល័យភូមិន្ទកសិកម្ម
- មហាវិទ្យាល័យ សេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ
- មជ្ឈមណ្ឌលឯកសារ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- មជ្ឈមណ្ឌលស្រាវជ្រាវអេកូលេន (ECOLAND)
- សាលាស្រុកបារាយណ៍

ដែលបានអនុញ្ញាត និងផ្តល់លទ្ធភាពដល់ខ្ញុំបាទបានរៀនសូត្រ និងក្រេបជញ្ជក់នូវចំណេះដឹង ផ្នែកវិទ្យាសាស្ត្រទាំងឡាយ ព្រមទាំងបង្កលក្ខណៈងាយស្រួលក្នុងការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ ក្នុងរយៈពេលធ្វើកម្មសិក្សារហូតទទួលបានជោគជ័យជាស្ថាពរ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ

- ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ង៉ោ ប៊ុនថាន សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- សាស្ត្រាចារ្យបណ្ឌិត សុក គន្ធី សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- សាស្ត្រាចារ្យបណ្ឌិត ម៉ែន សារុម សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- សាស្ត្រាចារ្យបណ្ឌិត សេង មុំ សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- បណ្ឌិត ព្រាប វិសាលទោ សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- លោក អ៊ឹង រតនា សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- សាស្ត្រាចារ្យរង បូរ៉ា កាធី ព្រឹទ្ធបុរសនៃមហាវិទ្យាល័យ សេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ
- លោក អេង លេង ព្រឹទ្ធបុរសរងនៃមហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- សាស្ត្រាចារ្យបណ្ឌិត ឆាយ គង្គា ព្រឹទ្ធបុរសរងនៃមហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- លោក អ៊ុំ វេង ព្រឹទ្ធបុរសរងនៃមហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- លោក និងលោកស្រីសាស្ត្រាចារ្យ នៃមហាវិទ្យាល័យ សេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទទាំងអស់ដែលបានបង្កនូវភាពងាយស្រួលដល់ការសិក្សា ជួយបង្ហាត់បង្រៀន ពន្យល់ណែនាំដោយប្រើអស់ទាំងកម្លាំងកាយ និងកម្លាំងបញ្ញា និងជួយដាស់តឿនក្រើនរំលឹកពីការអប់រំគ្រប់បែបយ៉ាងក្នុងពេលសិក្សាកន្លងមក។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ

- បណ្ឌិត នាង ម៉ាលីន អ្នកដឹកនាំ

- កញ្ញា យ៉ើ អាស៊ីគិន អ្នកជំនួយការ

- កញ្ញា សឿង លីលី អ្នកជំនួយការ

ដែលបានជួយពិនិត្យ ពន្យល់ ណែនាំ ចង្អុលបង្ហាញផ្លូវក្នុងការធ្វើសារណាបទនេះ ឲ្យប្រព្រឹត្តទៅដល់ទីបញ្ចប់

ប្រកបដោយភាពជោគជ័យ និងពោរពេញដោយអត្ថន័យ និងខ្លឹមសារ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ

- លោកឪពុក ឯក សុផុន

- អ្នកម្តាយ បឿន ចន្ទី

- ប្អូនប្រុស ឯក សុធារាជ

- ព្រមទាំងបងប្អូនញាតិមិត្តទាំងអស់ ដែលបានជួយបីបាច់ថែរក្សា ផ្គត់ផ្គង់ទំនុកបម្រុងអស់ពីកម្លាំងកាយចិត្ត និងសម្ភារៈគ្រប់បែបយ៉ាង។ ផ្តល់ការអប់រំទូន្មានប្រៀនប្រដៅដោយផ្តល់នូវដំបូន្មានល្អៗប្រកបដោយព្រហ្មវិហារធម៌គ្រប់បែបយ៉ាង ដើម្បីជំរុញឱ្យដំណើរការសិក្សារបស់កូនប្រព្រឹត្តទៅបានល្អប្រសើរ
ហើយទីបំផុតកូនក៏បានបញ្ចប់ការសិក្សាប្រកបដោយភាពជោគជ័យជាស្ថាពរ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ

- បណ្ឌិត នាង ម៉ាលីន

- កញ្ញា យ៉ើ អាស៊ីគីន

- កញ្ញា សឿង លីលី

- លោក សុខ គីមឈិន

- កញ្ញា អោម សុម៉ាលី

- កញ្ញា អ៊ុន សុផល

- កញ្ញា ឡុង នីតា

- កញ្ញា គង់ រចនាសុផល

- លោក កាំង គង់សេង

- លោក សុទ្ធ សេរីបុត្រ

- លោក ម៉ុង សុភា

និងមិត្តរួមថ្នាក់ទាំងអស់ ដែលបានជួយក្រើនរំលឹក ពិនិត្យ ណែនាំ និងផ្តល់ជាកម្លាំងចិត្តដល់រូបខ្ញុំសម្រេចបានជោគជ័យក្នុងការសិក្សាកន្លងមក។

## សង្ខេបសារណា

វិស័យកសិកម្ម ចូលរួមចំណែកយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចជាតិ។ ដើម្បីលើកកម្ពស់វិស័យកសិកម្មនៅកម្ពុជា ក៏ដូចជាសេដ្ឋកិច្ចជាតិ ស្ត្រីមានតួនាទីយ៉ាងចំបង ពិព្រោះកសិករកម្ពុជាចំនួន ៦៥ ភាគរយគឺជាស្ត្រី (MAFF, ២០០៦)។ យ៉ាងណាមិញ ដោយមើលឃើញពីការលំបាក និងកត្តារារាំងជាច្រើន ដែលស្ត្រីបានជួបប្រទះក្នុងវិស័យកសិកម្ម និងការប្រានចោលនូវតួរនាទីរបស់ស្ត្រីក្នុងសកម្មភាពអភិវឌ្ឍន៍ផ្សេងៗ ជាពិសេសក្នុងប្រព័ន្ធផលិតកម្មកសិកម្ម ការសិក្សាអំពីប្រធានបទ " តួនាទីយេនឌ័រក្នុងប្រព័ន្ធកសិកម្ម នៅឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ" ដែលមានបីគោលបំណងរួមមានដូចជា (១) សិក្សាពីការចូលរួម និងប្រភេទការងារក្នុងកសិដ្ឋានរវាងស្ត្រី និងបុរសក្នុងតំបន់សិក្សា (២) សិក្សាពីការចូលរួមរនៃកម្លាំងពលកម្មស្ត្រីក្នុងការរកប្រាក់ចំណូលក្នុងប្រព័ន្ធកសិកម្មនីមួយៗ (៣) វិភាគ SWOT របស់កម្លាំងពលកម្មស្ត្រីដែលរស់នៅក្នុងតំបន់សិក្សា ត្រូវបានលើកយកមកសិក្សា។

តាមរយៈការសិក្សាបានអោយដឹងថា ស្ត្រីចូលរួមចំណែកគ្រប់ផលិតកម្មកសិកម្មទាំងអស់ ជាពិសេសការដាំបន្លែ និងចិញ្ចឹមសត្វមាន់ទាជ្រូក នៅក្នុងសួនជុំវិញផ្ទះ។ ស្ត្រីចូលរួមរហូតដល់ ៨០ ភាគរយ ក្នុងការដាំបន្លែ និង ៧៧, ២៧ ភាគរយក្នុងការចិញ្ចឹមសត្វមាន់ទាជ្រូក។ រីឯការដាំដុះស្រូវ (ស្រូវវារ និងស្រូវវស្សា) និងដំឡូងមី បុរស និងស្ត្រីចូលរួមប្រហាក់ប្រហែលគ្នា។ ដោយឡែក ការងារមើលគោក្របី ស្ត្រីមិនសូវចូលរួមច្រើនដូចបុរសទេ។ ស្ត្រីចូលរួមបាន ៣៩,៥៨ ភាគរយប៉ុណ្ណោះ ក្នុងការមើលថែទាំគោក្របី។ នៅក្នុងតំបន់សិក្សា មានប្រព័ន្ធផលិតកម្មកសិកម្មចំនួន ៥ ប្រព័ន្ធ។ នៅក្នុងចំណោមប្រព័ន្ធទាំងអស់ ប្រព័ន្ធទី១មានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ជាងគេ គឺរហូតដល់ ៤.២៣ ។ ដោយឡែក ក្នុងចំណោមប្រព័ន្ធទាំងអស់ ប្រព័ន្ធដែលស្ត្រីចូលរួមបង្កើតប្រាក់ចំណូលបានច្រើនជាងគេ គឺប្រព័ន្ធទី១ គឺរហូតដល់ ៣,២៣៥,១៩១.៧៦រៀល នៃប្រាក់ចំណេញសរុប ៦,៦៣០,១៣១.៤១ រៀល។ នៅក្នុងការវិភាគ SWOT ស្ត្រីមានចំនុចខ្លាំងដូចជា ឧស្សាហ៍ព្យាយាម មិនប្រកាន់ការងារ មានពេលវេលាច្រើន ទទួលចំណេះដឹងពីវគ្គ បណ្តុះបណ្តាលច្រើន មានការសន្សំសំចៃ និងពូកែចរចារតម្លៃ និងមានចំនុចខ្សោយ ដូចជា កម្លាំងខ្សោយ មិនសូវចេះអក្សរ ខ្វះទំនុកចិត្ត និងមិនចូលចិត្តទៅឆ្ងាយ។ យ៉ាងណាមិញ ស្ត្រីត្រូវបានផ្តល់ឱកាសអោយចូលរួមវគ្គបណ្តុះ
បណ្តាលនានា និងផ្តល់ជាជំនួយជាច្រើន និងអាចរកឱកាសការងារក្រៅកសិកម្ម និងមិនមែនកសិកម្មជាច្រើន
ទៀត។ ដោយឡែក កត្តាសង្គម កត្តាគ្រួសារ និងការរីកចម្រើននៃគ្រឿងយន្តជាកត្តារាំងស្ទះដល់វត្តមានរបស់ស្ត្រី នៅក្នុងវិស័យកសិកម្ម។

សរុបសេចក្តីមក យើងអាចសន្និដ្ឋានបានថា នៅក្នុងតំបន់សិក្សា ស្ត្រីពិតជាបានចូលរួមយ៉ាងសកម្មក្នុងការស្វែងរកប្រាក់ចំណូលចូលគ្រួសារតាមរយៈការងារក្នុងប្រព័ន្ធកសិកម្មពិតមែន។ យ៉ាងណាមិញ ដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មអោយកាន់តែល្អប្រសើរជាងនេះទៅទៀត ស្ត្រីគួរព្យាយាមប្រើប្រាស់ចំនុចខ្លាំងរបស់ខ្លួន និងបង្កើនសមត្ថភាពខ្លួនឯងបន្ថែមទៀត។ រីឯ រដ្ឋាភិបាល អង្គការ ឬស្ថាប័នដែលពាក់ព័ន្ធ មិនគួរមើលរំលងពីទុកលំបាករបស់ស្ត្រីនោះទេ។ រដ្ឋាភិបាល អង្គការ ឬស្ថាប័នដែលពាក់ព័ន្ធ គួររៀបចំយុទ្ធសាស្ត្រយ៉ាងណាដើម្បីបង្កភាពងាយស្រួលដល់ស្ត្រី ដើម្បីចូលរួមក្នុងវិស័យកសិកម្មអោយកាន់តែប្រសើរឡើង។

## Abstract

Agriculture contributes significantly to the national economy. Women is a key role to promote the agricultural sector as well as the economy in the country since 65 percent of Cambodian farmer is woman (MAFF, 2006). However, by the sight of the difficulties and constraints that women face in agriculture and the rejection of women's role in development activities, particularly in the agricultural production system, the study on "Gender roles in farming system in Thnaot Chum commune, Baray district, Kompong Thom Province" is conducted, which has three objectives include (1) to understand the job distribution between man and women in each production in the study area, (2) to study about the contribution of woman labor in generating income from each farming system, and (3) to analys SWOT of woman labor in the study area.

Based on the the study, woman accounts for all production activities, particularly in growing vegetables and raising poultry, pigs in their home garden. Women participate up to 80 percent of vegetables and 77.27 percent in livestock, poultry, pigs which are grown and raised in home garden. On the other hand, for rice cultivation (floating rice and rainy season rice) and cassava, both man and woman almost equally involve in these activities. Woman does not participate as much as man in cattle herding. Women's participation is only 39.58 percent for taking care cattle. In the study area, there are five farming system. Among the five system, the first farming system is the most effective (4.23). However, among all farming system, the system that woman contributes the most is the first system as well (up to 3,235,191.76 riel of total profit 6,630,131.41 riel). The SWOT analysis, there are some strengths of woman labor such as patience and hard working, have much time, participate in many training, good at saving and negotiate price. Furthermore, woman has been given the opportunity to participate in various training courses and financial support and also be able to find employment opportunities like out-farm and non-farm job. However, woman labor also have some weaknesses such as physically weak, lack of knowledge, lack of self-confidence and do not like to go far away for home. Moreover, social factors, family factors and the new innovation of machinery is the obstacle of the presence of woman in farming system.

In summary, we can conclude that woman in the study area has been actively contributed a huge amount to income through farming system activities. However, in order to develop agricultural sector, women should try to use their strengths properly and try to improve their weaknesses. Moreover, government, organizations or institutions which involve in the sector should not overlook the woman's hardship and obstacle in agricultural sector.. Government, organizations. or

institutions which involve should prepare the strategy to create an environment for women to participate in the agricultural sector much easier.

# បញ្ជីមាតិកា

ទំព័រ


សេចក្ដីថ្លែងអំណរគុណ ........ i
សង្ខេបសារណា ........ iv
បញ្ជីមាតិកា ........ vi
បញ្ជីវិចិត្ររូប ........ ix
បញ្ជីពាក្យសរសេរកាត់ ........ xi

ជំពូក ១ សេចក្ដីផ្ដើម

១.១ លក្ខណៈទូទៅ ........ ១
១.២ មូលហេតុនៃការសិក្សា ........ ២
១.៣ គោលបំណងនៃការសិក្សា ........ ២
១.៤ ទំហំនៃការសិក្សា ........ ២

ជំពូក ២ សំយោគឯកសារ

២.១ និយមន័យ ........ ៣
២.១.១ ភេទ ........ ៣
២.១.២ យេនឌ័រ ........ ៣
២.១.៣ តួនាទីយេនឌ័រ ........ ៣
២.១.៤ ប្រព័ន្ធកសិកម្ម ........ ៤
២.២ អត្ថន័យនៃការបញ្ជ្រាបយេនឌ័រ ........ ៤
២.៣ ប្រវត្តិនៃការបញ្ជ្រាបយេនឌ័រ ........ ៤
២.៤ តួនាទីរបស់ស្ត្រីនៅក្នុងវិស័យកសិកម្ម ........ ៥
២.៥ ស្ថានភាពយេនឌ័រក្នុងប្រទេសកម្ពុជា ........ ៦
២.៦ កត្តារាំងស្ទះរបស់ស្ត្រីជនបទ ........ ៦
២.៦.១ ការកាន់កាប់ដីធ្លី ........ ៦
២.៦.២ ការដកហូតធនធានធម្មជាតិ ........ ៧
២.៦.៣ ក្រុមមូលដ្ឋាន និងធនធានសង្គម ........ ៨

២.៦.៤ ការអប់រំ ..... ៨
២.៦.៥ បច្ចេកទេស ..... ៩
២.៦.៦ ឥណទាន ..... ៩
២.៧ គោលនយោបាយបញ្ញាបយេនឌ័ររបស់ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ ..... ១០
២.៨ ការវិភាគប្រព័ន្ធកសិកម្ម ..... ១១
២.៨.១ គោលគំនិតរបស់ប្រព័ន្ធកសិកម្ម ..... ១១
២.៨.២ ការកំណត់ប្រភេទនៃប្រព័ន្ធផលិតកម្មផ្សេងៗ ..... ១១
២.៨.៣ ការកំណត់លក្ខណៈនៃប្រព័ន្ធកសិកម្មផ្សេងៗគ្នា ..... ១៣

ជំពូក ៣ វិធីសាស្ត្រសិក្សាស្រាវជ្រាវ

៣.១ ការជ្រើសរើសតំបន់សិក្សា ..... ១៥
៣.២ ការជ្រើសរើសសំណាក ..... ១៥
៣.៣ វិធីសាស្ត្រប្រមូលទិន្នន័យ ..... ១៥
៣.៣.១ ទិន្នន័យមានស្រាប់ (Secondary Data) ..... ១៦
៣.៣.២ ទិន្នន័យបឋម (Primary Data) ..... ១៦
៣.៤ វិធីសាស្ត្រវិភាគទិន្នន័យ ..... ១៦
៣.៤.១ ការវិភាគទិន្នន័យបែបគុណភាព ..... ១៧
៣.៤.២ ការវិភាគទិន្នន័យបែបបរិមាណ ..... ១៧

ជំពូក ៤ លទ្ធផល និងការពិភាក្សា

៤.១ ស្ថានភាពទូទៅនៃតំបន់សិក្សា ..... ១៨
៤.១.១ ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រខេត្តកំពង់ធំ ..... ១៨
៤.១.២ ស្ថានភាពទូទៅស្រុកបារាយណ៍ ..... ១៨
៤.១.៣ ស្ថានភាពទូទៅឃុំត្នោតជុំ ..... ១៩
៤.១.៤ ស្ថានភាពទូទៅរបស់កសិករ ..... ២១
៤.២ ការបែងចែកប្រភេទការងាររវាងបុរស និងស្ត្រីក្នុងផលិតកម្មកសិកម្មនីមួយៗ ..... ២៦
៤.២.១ ដំណាំស្រូវវស្សា ..... ២៦
៤.២.២ ដំឡូងមី ..... ២៧
៤.២.៣ បន្លែ ..... ២៧
៤.២.៤ ការចិញ្ចឹមសត្វ ..... ២៨
៤.៣ ការចូលរួមនៃកម្លាំងពលកម្មស្ត្រីក្នុងការរកប្រាក់ចំណូលក្នុងប្រព័ន្ធកសិកម្មនីមួយៗ ..... ២៩
៤.៣.១ ប្រព័ន្ធផលិតកម្មទី០១ ..... ៣០
៤.៣.២ ប្រព័ន្ធផលិតកម្មទី០២ ..... ៣១
៤.៣.៣ ប្រព័ន្ធផលិតកម្មទី០៣ ..... ៣៣
៤.៣.៤ ប្រព័ន្ធផលិតកម្មទី០៤ ..... ៣៤
៤.៣.៥ ប្រព័ន្ធផលិតកម្មទី០៥ ..... ៣៥
៤.៣.៦ ការប្រៀបធៀបសេដ្ឋកិច្ចនៃប្រព័ន្ធផលិតកម្មក្នុងតំបន់សិក្សា ..... ៣៦

៤.៣ ការវិភាគ SWOT នៃកម្លាំងពលកម្មស្រ្តីក្នុងតំបន់សិក្សា ..... ៣៨
៤.៣.១ ចំណុចខ្លាំង ..... ៣៨
៤.៣.២ ចំណុចខ្សោយ ..... ៣៩
៤.៣.៣ ឱកាស ..... ៣៩
៤.៣.៤ កត្តារារាំង ..... ៤០
ជំពូក ៥ សេចក្តីសន្និដ្ឋាន និងអនុសាសន៍
៥.១ សេចក្តីសន្និដ្ឋាន ..... ៤០
៥.២ អនុសាសន៍ ..... ៤១
បណ្ណាល័យសាស្រ្ត
ឧបសម្ព័ន្ធ
ព្រឹត្តិបត្រព័ត៌មាននិស្សិត

## បញ្ជីវិចិត្ររូប


| ល.រ | លេខលំដាប់ | ចំណងជើង | ទំព័រ |
|---|---|---|---|
| | | តារាង | |
| ១ | តារាងទី ៤.១ | តារាងចំនួនជនចំណាកស្រុកឃុំត្នោតជុំ | ២០ |
| ២ | តារាងទី ៤.២ | ស្ថានភាពមេគ្រួសារក្នុងតំបន់សិក្សា | ២២ |
| ៣ | តារាងទី ៤.៣ | កម្រិតវប្បធម៌មេគ្រួសារក្នុងតំបន់សិក្សា | ២៣ |
| ៤ | តារាងទី ៤.៤ | ប្រភេទមុខរបរចំបងរបស់មេគ្រួសារ | ២៤ |
| ៥ | តារាងទី ៤.៥ | ប្រភេទមុខរបរបន្ទាប់បន្សំរបស់មេគ្រួសារ | ២៥ |
| ៦ | តារាងទី ៤.៦ | ផលិតភាពនៃកម្លាំងពលកម្មស្រ្តី ផ្សារភ្ជាប់ទៅនឹងទុនវិនិយោគក្នុងប្រព័ន្ធទី០១ | ៣០ |
| ៧ | តារាងទី ៤.៧ | ប្រសិទ្ធភាពសេដ្ឋកិច្ចនៃទុនផលិតកម្មនៃប្រព័ន្ធទី០១ | ៣១ |
| ៨ | តារាងទី ៤.៨ | ផលិតភាពនៃកម្លាំងពលកម្មស្រ្តី ផ្សារភ្ជាប់ទៅនឹងទុនវិនិយោគក្នុងប្រព័ន្ធទី០២ | ៣២ |
| ៩ | តារាងទី ៤.៩ | ប្រសិទ្ធភាពសេដ្ឋកិច្ចនៃទុនផលិតកម្មនៃប្រព័ន្ធទី ០២ | ៣២ |
| ១០ | តារាងទី ៤.១០ | ផលិតភាពនៃកម្លាំងពលកម្មស្រ្តី ផ្សារភ្ជាប់ទៅនឹងទុនវិនិយោគក្នុងប្រព័ន្ធទី០៣ | ៣៣ |
| ១១ | តារាងទី ៤.១១ | ប្រសិទ្ធភាពសេដ្ឋកិច្ចនៃទុនផលិតកម្មនៃប្រព័ន្ធទី ០៣ | ៣៣ |

១២ តារាងទី ៤.១២ ផលិតភាពនៃកម្លាំងពលកម្មស្ត្រី ផ្សារភ្ជាប់ទៅនឹងទុនវិនិយោគក្នុងប្រព័ន្ធទី ០៤ ៣៤
១៣ តារាងទី ៤.១៣ ប្រសិទ្ធភាពសេដ្ឋកិច្ចនៃទុនផលិតកម្មនៃប្រព័ន្ធទី ០៤ ..... ៣៥
១៤ តារាងទី ៤.១៤ ផលិតភាពនៃកម្លាំងពលកម្មស្ត្រី ផ្សារភ្ជាប់ទៅនឹងទុនវិនិយោគក្នុងប្រព័ន្ធទី ០៥ ៣៥
១៥ តារាងទី ៤.១៥ ប្រសិទ្ធភាពសេដ្ឋកិច្ចនៃទុនផលិតកម្មនៃប្រព័ន្ធទី ០៥ ..... ៣៦
១៦ តារាងទី ៤.១៦ ប្រៀបធៀបទុនវិនិយោគ ចំណេញសុទ្ធក្នុងមួយកម្លាំងពលកម្ម ចំណេញសុទ្ធសរុប និង ការចូលរួមនៃកម្លាំងពលកម្មស្ត្រីក្នុងចំណេញសុទ្ធនៃប្រព័ន្ធនីមួយៗ..... ៣៦
១៧ តារាងទី ៤.១៧ ប្រៀបធៀបប្រសិទ្ធភាពសេដ្ឋកិច្ចនៃប្រព័ន្ធនីមួយៗ ..... ៣៧

ដ្យាក្រាម

១៨ ដ្យាក្រាមទី ៤.១ ភាគរយនៃស្ថានភាពយេនឌ័រ របស់មេគ្រួសារ..... ២២
១៩ ដ្យាក្រាមទី ៤.២ ប្រភេទមុខរបរបន្ទាប់បន្សំរបស់មេគ្រួសារ..... ២៤
២០ ដ្យាក្រាមទី ៤.៣ ប្រភេទមុខរបរបន្ទាប់បន្សំរបស់មេគ្រួសារ ..... ២៥
២១ ដ្យាក្រាមទី ៤.៤ ភាគរយនៃការចូលរួមនៃបុរស និងស្ត្រីក្នុងផលិតកម្មកសិកម្មនីមួយៗ ..... ២៩

គំនូសតាង

២២ គំនូសតាងទី១ ទំនាក់ទំនងរវាងកត្តាផលិតកម្ម និងប្រព័ន្ធដំណាំ និងប្រព័ន្ធចិញ្ចឹមសត្វ..... ១១

បញ្ជីពាក្យកាត់

| ពាក្យសរសេរកាត់ | | ពាក្យពន្យល់ |
|---|---|---|
| % | ៖ | ភាគរយ |
| & | ៖ | និង |
| ៛ | ៖ | រៀល |
| SPSS | ៖ | Statistic Package for Social Science |
| FAO | ៖ | Food and Agriculture Organization |
| NIS | ៖ | National Institute of Statistics |
| GDP | ៖ | Gross Domestic Product |
| SWOT | ៖ | Strength Weakness Opportunity Threat |
| FGD | ៖ | Focus Group Discussion |
| GDA | ៖ | Gender and Development |
| USAID | ៖ | United States Agency for International Development |
| NGOs | ៖ | Non-Government Organizations |
| MODE | ៖ | Monority Organization Development Organization |

# ជំពូក១
# សេចក្តីផ្តើម

# ជំពូក ១
# សេចក្តីផ្តើម

## ១.១ លក្ខណៈទូទៅ

វិស័យកសិកម្មមានតួនាទីសំខាន់ណាស់ក្នុងការចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងចូលរួមការបន្ថយភាពក្រីក្រ។ ក្នុងប្រទេសកម្ពុជា ប្រជាជន ៨០%នៃប្រជាជនសរុបដែលមានចំនួនសរុប ១៣.៤ លាននាក់ ប្រកបរបរចិញ្ចឹមជីវិតដោយពឹងផ្អែកលើវិស័យកសិកម្ម (NIS, ២០០៨)។ លើសពីនេះ វិស័យកសិកម្មរបស់កម្ពុជាបានចូលរួមចំណែកចំនួន ២៨, ៥% នៃ GDP សរុប (ក្រសួងកសិកម្ម, ២០០៦)។ ក្នុងនោះ ស្ត្រីចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់វិស័យកសិកម្ម និងសេដ្ឋកិច្ចជាតិ។ សកម្មភាពរបស់ស្ត្រីជាប្រចាំមានដូចជា ការដាំដុះកសិផល ការចិញ្ចឹមសត្វ ការកែច្នៃ ចម្អិនម្ហូប ស៊ីឈ្នួលក្នុងវិស័យកសិកម្ម ឬសហគ្រាសជនបទផ្សេងទៀត រកអុស រកទឹក ចូលរួមក្នុងការធ្វើជំនួញ ចូលរួមក្នុងទីផ្សារ ថែរក្សាសមាជិកគ្រួសារ និងផ្ទះសម្បែង (FAO, ២០១១)។ បើយោងតាមរបាយការណ៍របស់ក្រសួងកសិកម្មរុក្ខប្រមាញ់ និងនេសាទ មានចំនួនស្ត្រីប្រមាណជា ៨០% មានតួនាទីក្នុងដំណើរការផលិតចំនីអាហារ ហើយ ៦៥% នៃស្ត្រីគឺជាកសិករ (MAFF, ២០០៦)។ នេះឆ្លុះបញ្ចាំងអោយឃើញថា ស្ត្រីជាគន្លឹះដ៏សំខាន់ក្នុងការអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជា។

យ៉ាងណាមិញ បើទោះបីជាមានការផ្សព្វផ្សាយពីការលើកកម្ពស់សិទ្ធិស្ត្រីនៅក្នុងសង្គមក៏ដោយ ការរើសអើងស្ត្រីនៅតែបន្តមានរហូតមកដល់ពេលបច្ចុប្បន្ន
ដោយគេយល់ឃើញថាស្ត្រីគឺជាភេទទន់ខ្សោយ។
ផ្នត់គំនិតដែលយល់ឃើញថាស្ត្រីមិនគួររៀនសូត្របានចេះដឹងច្រើន ឬមានមុខមាត់ក្នុងសង្គម នៅតែចាក់ស្រេះក្នុងសង្គម
កម្ពុជា។ មនុស្សមួយចំនួននៅតែបន្តគិតថា ស្ត្រីគួរតែនៅផ្ទះ ធ្វើការក្នុងចង្ក្រានបាយ និងមើលថែកូន ចំណែកបុរសត្រូវធ្វើការងារនៅក្រៅផ្ទះ ដើម្បីរកចំនូលចិញ្ចឹមគ្រួសារ។ ការកំណត់ការងាររវាងស្ត្រី និងបុរស បានបង្អាក់ដល់ការងារអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ ក៏ដូចជាសង្គមជាតិទាំងមូល ព្រោះសង្គមនឹងបាត់បង់កម្លាំងពលកម្មមួយផ្នែកដ៏មានតម្លៃ។ ដូចគ្នានេះផងដែរ នៅក្នុងវិស័យកសិកម្ម ស្ត្រីជួបប្រទះបញ្ហាជាច្រើន ដោយរាល់បច្ចេកទេសកសិកម្មនៅមិនទាន់មានភាពទំនើបនៅឡើយ ហើយភាគច្រើនវាត្រូវបានផលិតឡើងដើម្បីតម្រូវអោយបុរសសម្រាប់ប្រើប្រាស់។ ម្យ៉ាងវិញទៀត រាល់ការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ការចូលរួមរបស់ស្ត្រីនៅមានកំរិតនៅឡើយ។ បើយោងទៅតាមរបាយការណ៍របស់ក្រសួង មានស្ត្រីត្រឹមតែ១០ភាគរយប៉ុណ្ណោះ ដែលបានទទួលយកការផ្សព្វផ្សាយពីកសិកម្ម
(MAFF, ២០០៦)។

សរុបសេចក្តីមក ដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មអោយបានជោគជ័យ យើងត្រូវយកចិត្តទុកដាក់លើការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងសង្គម
ជាពិសេសក្នុងវិស័យកសិកម្មដែលជាវិស័យស្នូលសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ច ជាតិ។ ហេតុនេះហើយ រាល់យុទ្ធសាស្ត្រ ឬ គម្រោងនៃការអភិវឌ្ឍន៍ជនបទនានា គេត្រូវបញ្ជ្រាបចំណេះដឹងពីយេនឌ័រទៅក្នុងនោះ ដើម្បីសម្រេចបាននូវភាពជោគជ័យគ្រប់ជ្រុងជ្រោយ។ ដោយមើលឃើញពី ការលំបាក និងកត្តារាំងជាច្រើន ដែលស្ត្រីបានជួបប្រទះក្នុងវិស័យកសិកម្ម និងការប្រានចោលនូវតួរនាទីរបស់ស្ត្រីក្នុងសកម្មភាពអភិវឌ្ឍន៍
ផ្សេងៗជាពិសេសក្នុងប្រព័ន្ធផលិតកម្មកសិកម្ម។ ផ្ទុយទៅវិញ ស្ត្រីបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍន៍សង្គម និងក្នុងប្រពន្ធ័ផលិតកម្មកសិកម្ម។ ដូចនេះ ការសិក្សាអំពីប្រធានបទ “តួនាទីយេនឌ័រក្នុងប្រព័ន្ធកសិកម្ម នៅឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ” អាចផ្តល់ជាប្រយោជន៍ និងការបង្ហាញឲ្យកាន់តែច្បាស់ពីតួនាទីរបស់ស្ត្រីក្នុងការអភិវឌ្ឍន៍សង្គម
ជាពិសេសក្នុងប្រព័ន្ធផលិតកម្មកសិកម្ម។

## ១.២ មូលហេតុនៃការសិក្សា

ដើម្បីអភិវឌ្ឍន៍វិស័យកសិម្មនៅកម្ពុជា យើងចាំបាច់ត្រូវគិតទៅលើកត្តាជាច្រើន ដូចជា ហេដ្ឋារចនាសម្ព័ន្ធ(ផ្លូវថ្នល់ ធារាសាស្ត្រជាដើម), បច្ចេកទេសកសិកម្ម, គ្រឿងយន្តកសិម្ម, ទីផ្សារកសិផល

និងការកែច្នៃកសិផល។ល។ លើសពីនេះទៅទៀត ការលើកកំពស់យេនឌ័រនៅក្នុងវិស័យកសិកម្មក៏ជាកត្តាមួយដែលយើងមិនគួរមើលរំលង ព្រោះស្ត្រី គឺជាគន្លឹះដ៏សំខាន់ក្នុងការអភិវឌ្ឍន៍វិស័យកសិកម្ម។

ការអភិវឌ្ឍន៍នឹងសម្រេចបានយឺតយ៉ាវ បើគ្មានការលើកកម្ពស់យេនឌ័រនៅក្នុងវិស័យកសិកម្ម ។ ជាក់ស្តែង រាល់សកម្មភាពការងារក្នុងកសិដ្ឋានចាំបាច់ត្រូវមានវត្តមានរបស់ស្ត្រីចូលរួម មិនថាការងារដាំដុះស្រូវ ដាំបន្លែ ឬចិញ្ចឹមសត្វនោះទេ។ យ៉ាងណាមិញ មានការងារមួយចំនួនដែលស្ត្រីជួបការលំបាក និងពុំមានលទ្ធភាពធ្វើទៅបានដោយផ្អែកទៅលើ ចំណុចខ្សោយផ្ទាល់ខ្លួន ឬក៏លក្ខខណ្ឌសង្គម វប្បធម៌។

ហេតុនេះហើយ ការសិក្សាទៅលើប្រធានបទស្តីពី "ការសិក្សាពីតួនាទីរបស់យេនឌ័រក្នុងប្រព័ន្ធកសិកម្មនៅឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ" ត្រូវបានលើកយកមកសិក្សាស្រាវជ្រាវ និងវិភាគសម្រាប់ជាគោលបំណងសិក្សាឱ្យស៊ីជម្រៅពីទិដ្ឋភាពជាក់ស្តែង សកម្មភាព និងការចូលរួមរបស់ស្ត្រីក្នុងប្រព័ន្ធកសិកម្ម តម្រូវការ និងបញ្ហាដែលស្ត្រីជួបប្រទះ។

## ១.៣ គោលបំណងនៃការសិក្សា

ប្រធានបទនេះ ត្រូវបានធ្វើការសិក្សាស្រាវជ្រាវដោយផ្តោតទៅលើគោលបំណងចំនួនបីសំខាន់ៗ ដែលរួមមានដូចខាងក្រោមនេះ៖

- សិក្សាពីការចូលរួម និងប្រភេទការងារក្នុងកសិដ្ឋានរវាងស្ត្រី និងបុរសក្នុងតំបន់សិក្សា
- សិក្សាពីការចូលរួមនៃកម្លាំងពលកម្មស្ត្រីក្នុងការរកប្រាក់ចំណូលក្នុងប្រព័ន្ធកសិកម្មនីមួយៗ
- វិភាគ SWOT របស់កម្លាំងពលកម្មស្ត្រីដែលរស់នៅក្នុងតំបន់សិក្សា

## ១.៤ ទំហំនៃការសិក្សា

ដោយរយៈពេលនៃការសិក្សាស្រាវជ្រាវនៃប្រធានបទខាងលើមានកំណត់ ដូចនេះតម្រូវឲ្យមានការកំណត់នូវទំហំនៃការសិក្សា ដោយយោងទៅតាមគោលបំណងនីមួយៗ និងប្រភេទគ្រួសារដែលត្រូវជ្រើសរើសយកមកធ្វើការសម្ភាសន៍តាមចំនួនសំណាក ដែលបានកំណត់សម្រាប់ប្រធានបទនេះ។ ការសិក្សានេះ ត្រូវបានចំណាយពេល១ខែសម្រាប់ធ្វើការប្រមូលព័ត៌មានចុះអង្កេត និងសម្ភាសន៍ផ្ទាល់ជាមួយកសិករ និងរយៈពេល ៣ ខែទៀតសម្រាប់រៀបចំទិន្នន័យបញ្ចូលក្នុង កុំព្យូទ័រ វិភាគទិន្នន័យ និងធ្វើការបកស្រាយនូវលទ្ធផលដែលវិភាគឃើញ ទើបសម្រេចបានជាសារណាបទនេះ។ ក្នុងការសិក្សាស្រាវជ្រាវនេះធ្វើការជ្រើសរើសសំណាកចំនួន ៦៣ គ្រួសារនៅក្នុងភូមិចំនួន២ គឺ ភូមិថ្មី និងភូមិព្រែកក្រោល ដែលស្ថិតនៅក្នុងឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ត្រូវបានជ្រើសរើសដើម្បីសម្ភាសន៍។ យ៉ាងហោចណាស់ សំណាក៥គ្រួសារត្រូវបានសម្ភាសន៍អាស្រ័យនឹងស្ថានភាពជាក់ស្តែងនៃប្រព័ន្ធក្សេត្របរិស្ថាននៃតំបន់សិក្សា។ ក្នុងនោះ កសិករ ១០ រូប ត្រូវបានជ្រើសរើស ដើម្បីចូលរួមធ្វើការពិភាក្សាជាក្រុម (FGD) ពីភូមិទាំងពីរ ក្នុងគោលបំណងស្វែងយកពី ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងកត្តារារាំងនៃកម្លាំងពលកម្មស្ត្រី។

# ជំពូក ២
# សំយោគឯកសារ

ជំពូក ២
សំយោគឯកសារ

២.១ និយមន័យ

២.១.១ ភេទ

ភេទ គឺជាលក្ខណៈសម្គាល់ខាងផ្នែកជីវសាស្ត្រ និងសេនេទិច ដែលជាទូទៅកំណត់ពីភាពខុសគ្នារវាងស្ត្រី និងបុរសដែលមិនអាចផ្លាស់ប្តូរបាន។ មានតែភាពខុសគ្នាបន្តិចបន្តួចនៃតួនាទីរបស់ស្ត្រី និងបុរសប៉ុណ្ណោះ ដែលកំណត់ពីភាពខុសគ្នាផ្នែកជីវសាស្ត្រ ឬរូបរាងរបស់ស្ត្រី និងបុរសដោយផ្អែកលើភេទ។ ឧទាហរណ៍ ការផ្តល់មេជីវិតគឺជាតួនាទីរបស់បុរស ហើយការមានផ្ទៃពោះ និងការបង្កើតកូនគឺជាតួនាទីរបស់ស្ត្រី (MAFF, ២០០៦)។

២.១.២ យេនឌ័រ

យេនឌ័រ សំដៅលើភាពខុសគ្នារវាងស្ត្រីនិងបុរស ដែលកំណត់ដោយសង្គម ដូចជា តួនាទី ឥរិយាបទ អាកប្បកិរិយា និងតម្លៃ។ ចរិតលក្ខណៈយេនឌ័រ កំណត់ចំពោះស្ត្រីនិងបុរស តាំងពីកុមារភាពមក ហើយត្រូវបានគិតថានឹងមានជាបន្ត។ ឧទាហរណ៍ នៅក្នុងសង្គមខ្លះស្ត្រីត្រូវបានចាត់ទុកថា ជាអ្នកដែលពឹងផ្អែកលើបុរស ហើយនៅក្នុងសង្គមខ្លះទៀត ស្ត្រីគឺជាអ្នកធ្វើសេចក្តីសម្រេចចិត្ត ឬស្ត្រី និងបុរសមានសិទ្ធិសម្រេចស្មើគ្នា។ យេនឌ័រមានលក្ខណៈខុសគ្នាពីវប្បធម៌មួយទៅវប្បធម៌មួយផ្សេងទៀត នៅក្នុងពេលមួយ ដូច្នេះលក្ខណៈទាំងអស់មានការផ្លាស់ប្តូរ (MAFF, ២០០៦)។

យេនឌ័រ គឺជាបណ្តុំនៃទម្រង់ចរិតលក្ខណៈ តួនាទី និងឥរិយាបថ ដែលសង្គម និងវប្បធម៌បានកំណត់នូវភាពខុសគ្នារវាងស្ត្រី និងបុរសនៅក្នុងសង្គមមួយ។ យ៉ាងណាមិញ ពាក្យគន្លឹះ យេនឌ័រ ត្រូវបានគេយល់ខុស និងប្រើប្រាស់មិនបានត្រឹមត្រូវដោយយល់ថា ពាក្យ យេនឌ័រ មានអត្ថន័យដូចគ្នាទៅនឹង ភេទ។ ប៉ុន្តែដូចដែលបានរៀបរាប់មកខាងលើ យេនឌ័រសំដៅទៅលើការកំណត់ភាពខុសគ្នានៃតួនាទី និងចរិតលក្ខណៈរបស់ស្ត្រី និងបុរសដោយសង្គមមួយ។ ផ្ទុយទៅវិញ ភេទសំដៅទៅលើភាពខុសគ្នាផ្នែកជីវសាស្ត្រដែលកំណត់ដោយធម្មជាតិ (Mabundza, Dlamini, & Nkambule, ២០១៤)។

២.១.៣ តួនាទីយេនឌ័រ

តួនាទីយេនឌ័រ គឺជាឥរិយាបថដែលរំពឹងទុកពីស្ត្រី និងបុរស។ តួនាទីយេនឌ័រត្រូវបានសិក្សា ហើយផ្លាស់ប្តូរតាមវប្បធម៌ផ្សេងៗគ្នា និងភាពលើសលប់។ ឥរិយាបថរបស់ស្ត្រី និងបុរសអាចផ្លាស់ប្តូរបាន (MAFF, ២០០៦)។

២.១.៤ ប្រព័ន្ធកសិកម្ម

ប្រព័ន្ធកសិកម្ម គឺជាសំណុំនៃប្រព័ន្ធការងាររចំរុះមួយ និងសមស្របនៃការងារកសិកម្មដែលគ្រួសារកសិករមួយ ឬសហគមន៍កសិកម្មគ្រប់គ្រង និងអនុវត្តជាក់ស្តែងតាមលក្ខណៈរូបសាស្ត្រ ជីវសាស្ត្រ និងសេដ្ឋកិច្ច សង្គម ហើយស្របជាមួយគោលគំនិត និងធនធានរបស់គ្រួសារកសិករ ឬសហគមន៍នោះ (សុក គីមឈិន, ២០១០)។

ម៉្យាងវិញទៀត នៅក្នុងកម្រិតអាជីវកម្មកសិកម្ម ប្រព័ន្ធកសិកម្មអាចឲ្យនិយមន័យថា ជាការគួបផ្សំនៃធនធាន (នៅក្នុងតំបន់ និងពេល) ដែលប្រើប្រាស់ដោយកសិករ និងនៅទីបញ្ចប់គាត់ទទួលបានផលិតផលផ្សេងៗដូចជា ដំណាំ និងសត្វ។ ប្រព័ន្ធផលិតកម្មកសិកម្មអាចត្រូវបាលយល់ផងដែរថាជាការគួបផ្សំដ៏ជិតស្និទ្ធ ឬច្រើននៃប្រព័ន្ធចិញ្ចឹមសត្វ និងប្រព័ន្ធកែច្នៃដំបូងនៃកសិផល (primary transform system of agriculture products) (ប៊ិល សុខា, ២០០៦)។

២.២ អត្ថន័យនៃការបញ្ជ្រាបយេនឌ័រ

ការបញ្ជ្រាបយេនឌ័រសំដៅលើដល់ដំណើរការ ឬយុទ្ធសាស្ត្រមួយដែលបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩០

សំដៅដល់ការធ្វើអោយបាននូវគោលដៅសមភាពយេនឌ័រ។ ការបញ្ជ្រាបយេនឌ័រមិនមានលក្ខណៈដូចជាទៅនឹងយុទ្ធសាស្ត្រស្ត្រីក្នុងការអភិវឌ្ឍន៍ទេ ពិព្រោះវាផ្តោតទៅលើការផ្លាស់ប្តូរ បទដ្ឋាននៃការបញ្ជ្រាបយេនឌ័រ តម្លៃ អាកប្បកិរិយា ការអនុវត្ត គំនិត និងផ្តត់គំនិតមួយ ដែលមានការឯកភាពពីមនុស្សភាគច្រើន អង្គការ សហគមន៍ និងមុខងារសង្គម។

ការបញ្ជ្រាបយេនឌ័រពាក់ព័ន្ធនឹង:

១. ការធ្វើអ្វីដែលជាការព្រួយបារម្ភ និងបទពិសោធន៍របស់ស្ត្រី និងបុរសក្លាយជាផ្នែកស្នូលមួយនៃការរៀបចំ និងការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃគោលនយោបាយ និងកម្មវិធីលើគ្រប់វិស័យនៅក្នុងសង្គម។

២. ការផ្លាស់ប្តូរគោលនយោបាយ និងការណែនាំសំដៅជំរុញអោយមានការលើកកម្ពស់សមភាពយេនឌ័រ យ៉ាងសកម្ម។

៣. ការគិតគូរជាថ្មីពីតម្លៃវប្បធម៌សង្គម និងគោលដៅអភិវឌ្ឍន៍រយៈពេលវែង។

## ២.៣ ប្រវត្តិនៃការបញ្ជ្រាបយេនឌ័រ

ក្រោយពីសន្និសីទក្រុងប៉េកាំង (Beijing) នៅឆ្នាំ ១៩៩៥ ពិភពលោកបានចាត់ទុកការបញ្ជ្រាបយេនឌ័រ ជាយុទ្ធសាស្ត្រគន្លឹះសម្រាប់សម្រេចបាននូវសមភាពយេនឌ័រ។ ដោយសារតែ ប្រជាជនប្រមាណជា ៧០ ភាគរយនៃប្រជាជនក្រីក្រនៅលើពិភពលោក រស់នៅអាស្រ័យទៅលើវិស័យកសិកម្ម រុក្ខប្រមាញ់ នេសាទ និងចិញ្ចឹមសត្វ ដែលក្នុងនោះ ក្នុងចំណោមប្រជាជនដែលក្របំផុត១០ នាក់ មាន៦នាក់ជាស្ត្រី និងកុមារី។ ស្ត្រីទាំងអស់នោះ ជួបប្រទះភាពអត់ឃ្លាន និងកង្វះសារធាតុចិញ្ចឹម កង្វះការទទួលបានសេវាសុខភាព ការអប់រំ និងសិទ្ធិក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ ដែលបណ្តាលមកពីការងារដែលទទួលបានប្រាក់កំរៃទាប ការងារមិនទទួលបានប្រាក់កំរៃ និងពលកម្មកុមារ។ ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៨០ មក មានមតិជាច្រើនបានលើកឡើងថា ការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាពចាំបាច់ត្រូវមានការយល់ដឹងពីតួនាទីរបស់ស្ត្រី និងបុរស និងទំនួលខុសត្រូវរបស់ពួកគេនៅក្នុងសហគមន៍ និងទំនាក់ទំនងរបស់ពួកគេ។ ទាំងនេះត្រូវបានគេស្គាល់ថាជា ដំណើរការ GAD (យេនឌ័រ និងការអភិវឌ្ឍន៍)។ ការលើកកម្ពស់ថានៈរបស់ស្ត្រីមិនត្រឹមតែជាបញ្ហារបស់ស្ត្រីតែម្នាក់ឯកនោះទេ វាជាគោលដៅមួយដែលមានការចូលរួមពីបុរស និងស្ត្រី (Batista et al., ២០១៤)។

សម្រាប់ប្រទេសកម្ពុជា សន្និសីទក្រុងប៉េកាំង បានផ្តល់នូវគោលការណ៍សំខាន់ៗសម្រាប់ជាមគ្គុទ្ទេសក្នុងការបញ្ជ្រាបយេនឌ័រនៅក្នុងប្រទេសកម្ពុជា ដែលជំរុញឲ្យរដ្ឋាភិបាលពង្រឹងនូវគោលជំហររបស់ខ្លួនក្នុងការដោះស្រាយបញ្ហាយេនឌ័រ ទៅក្នុងដំណើរការអភិវឌ្ឍន៍របស់ខ្លួន។ សន្និសីទក្រុងប៉េកាំងបូក៥ ឆ្នាំ២០០១ បានលើកឡើងជាថ្មីនូវភាពចាំបាច់ ក្នុងការធានាឲ្យមានការយកចិត្តទុកដាក់បន្ថែមទៀតទៅលើសមភាពយេនឌ័រ។ រាជរដ្ឋាភិបាលកម្ពុជាដែលជាហត្ថលេខីមួយក្នុងចំណោមហត្ថលេខីនានា នៅក្នុងការប្រកាសសន្និសីទបានបង្ហាញនូវការប្តេជ្ញាចិត្តរបស់ខ្លួន នៅក្នុងការធានាឲ្យបាននូវសមភាពយេនឌ័រ។ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) គឺជាកាតាលីករមួយផ្សេងទៀតសម្រាប់ប្រទេសកម្ពុជាក្នុងការបញ្ជ្រាបយេនឌ័រ (MAFF, ២០០៦)។

“សមភាពយេនឌ័រនៅគ្រប់ទិដ្ឋភាពនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម” ទស្សនវិស័យនេះបានបណ្តុះគំនិតដោយផ្អែកលើឯកសារថ្នាក់ជាតិ ដូចជារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចលើកទីមួយ និងទីពីរ (SEDP I&II) យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ឆ្នាំ២០០៣-២០០៥ (NPRS) គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDG) យុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល (ខែកក្កដា ឆ្នាំ២០០៤) និងសន្ធិ សញ្ញាអន្តរជាតិដទៃទៀតដែលពាក់ព័ន្ធ នឹងសមភាពយេនឌ័រ។ “ការបែងចែកដោយយុត្តិធម៌សម្រាប់ស្ត្រី : ការវាយតម្លៃយេនឌ័រនៅកម្ពុជា ឆ្នាំ២០០៤” ក៏បានបណ្តុះគំនិតមួយផងដែរនៅក្នុងការតម្រែតម្រង់ទិសដៅ និងជំរុញឲ្យមានការបញ្ជ្រាបយេនឌ័រ (MAFF, ២០០៦)។ ក្រសួងកិច្ចការនារី ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទជាដើម បានបញ្ចូលចំណេះដឹងពីយេនឌ័រទៅរាល់គម្រោងអភិវឌ្ឍន៍។ ក្រសួងកសិកម្ម (២០០៦) បានលើកឡើងថា

មានគម្រោងជាច្រើន ដែលមានបញ្ចូលចំណេះដឹងពីយេនឌ័រមានដូចជា បច្ចេកទេសគ្រប់គ្រងចំរុះកត្តាចង្រៃ (IPM), គម្រោងអភិវឌ្ឍន៍គុណភាពផលិតផលកសិកម្ម (AQIP), គម្រោងផ្សព្វផ្សាយបច្ចេកទេសកសិកម្ម កម្ពុជា-អូស្រ្តាលី (CAAEP), គម្រោងអភិវឌ្ឍន៍ផលិតភាពកសិកម្ម (APIP)។

## ២.៤ តួនាទីរបស់ស្ត្រីនៅក្នុងវិស័យកសិកម្ម

វិស័យកសិកម្ម គឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ។ ប៉ុន្តែ ការអភិវឌ្ឍន៍វិស័យកសិកម្ម នៅមានភាពយឺតយ៉ាវនៅឡើយ ដោយសារស្ត្រីដែលជាផ្នែកមួយដ៏សំខាន់ជួបប្រទះនឹងការកត្តារារាំងជាច្រើន ដែលនឹងរៀបរាប់លម្អិតនៅចំណុចបន្ទាប់ទៀត។ មានការស្រាវជ្រាវជាច្រើន ដែលលើកឡើងពីសារៈសំខាន់នៃការចូលរួមរបស់ស្ត្រី ក្នុងវិស័យកសិកម្ម។ នៅក្នុងរបាយការណ៍របស់អង្គការស្បៀងអាហារពិភពលោក បានបង្ហាញថាមានស្ត្រីចូលរួមចំណែកជាកម្លាំងពលកម្មក្នុងវិស័យកសិកម្មទូទាំងពិភពលោក មានប្រមាណជា ៤៣ ភាគរយ (SOFA & Doss, ២០១១)។ យ៉ាងណាមិញ តួលេខនៃការចូលរួមរបស់ស្ត្រីក្នុងវិស័យកសិកម្ម អាចមានភាពខុសគ្នាពីតំបន់មួយទៅតំបន់មួយ និងពីប្រទេសមួយទៅប្រទេសមួយ អាស្រ័យទៅលើអាយុរបស់ស្ត្រី និងឋានៈក្នុងសង្គមរបស់ស្ត្រីនៅក្នុងតំបន់នោះ ។ ជាក់ស្តែង ស្ត្រីមានតួនាទីយ៉ាងសំខាន់ក្នុងការធានាបាននូវសុវត្ថិភាពស្បៀងអាហារ ដោយស្ត្រីបានចូលរួមកាត់បន្ថយភាពអត់ឃ្លាន បង្កើនសុវត្ថិភាពស្បៀងអាហារ ក៏ដូចជាសារជាតុចិញ្ចឹម និងកាត់បន្ថយភាពក្រីក្រ។ ដូចដែលបានលើកឡើង ក្នុងរបាយការណ៍មួយរបស់ USAID ដែលបានដកស្រង់ពី របាយការណ៍របស់អង្គការស្បៀងអាហារពិភពលោក ដែលចេញផ្សាយក្នុងឆ្នាំ ២០១១ ថា “ប្រសិនបើស្ត្រីត្រូវបានផ្តល់នូវធនធានដូចគ្នាដែលបុរសទទួលបាន នោះស្ត្រីក្នុងប្រទេសកំពុងអភិវឌ្ឍន៍ នឹងអាចបង្កើនផលិតភាពក្នុងកសិដ្ឋានបានប្រមាណជា ២០ ទៅ៣០ ភាគរយ។ ហើយផលិតផលកសិកម្មរបស់ប្រទេសកំពុងអភិវឌ្ឍន៍នឹងកើនឡើងបានពី ២,៥ ទៅ ៤ ភាគរយ ដែលអាចកាត់បន្ថយចំនួនអ្នកអត់ឃ្លាននៅលើពិភពលោកបានពី ១២ ទៅ១៧ ភាគរយ ស្មើនឹង ១០០ ទៅ ១៥០ លាននាក់”(USAID, ២០១២)។ របាយការណ៍ដដែល បានលើកឡើងថា នៅក្នុងឆ្នាំ២០១០ មានប្រជាជនប្រមាណជា ៩២៥ លាននាក់ ដែលកង្វះនូវសារជាតុចិញ្ចឹម ក្នុងនោះមានប្រជាជន ៩០៦ លាននាក់រស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ (USAID, ២០១២)។ អាស្រ័យហេតុនេះការលើសកម្ពស់យេនឌ័រមានសារៈសំខាន់ណាស់ក្នុងការធានាបាននូវសុវត្ថិភាពស្បៀងអាហារ ក៏ដូចជាបង្កើននូវសេដ្ឋកិច្ចជាតិ ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍។

## ២.៥ ស្ថានភាពយេនឌ័រក្នុងប្រទេសកម្ពុជា

ការយល់ឃើញរបស់សង្គម បានកសាងឡើងដោយផ្អែកលើប្រវត្តិសាស្រ្តកន្លងមក និងចាក់ឫសគល់យ៉ាងជ្រៅទៅក្នុងគុណតម្លៃ និងផ្នត់គំនិត។ ទំនៀមទំលាប់វប្បធម៌ ដើរតួនាទីយ៉ាងសំខាន់ ក្នុងការកំណត់ភារកិច្ចទទួលខុសត្រូវរបស់ស្ត្រី និងបុរសនៅក្នុងសង្គម។

កន្លងមកនេះ បុរសភាគច្រើនតែងមានគំនិតមើលស្រាលលើស្ត្រីដោយចាត់ទុកថាស្ត្រីជាភេទទន់ខ្សោយ។ សព្វថ្ងៃនេះ ឋានៈរបស់ស្ត្រីត្រូវបានលើកតម្កើងអោយមានសិទ្ធិស្មើនឹងបុរសនៅក្នុងសង្គមជាតិ ក៏ប៉ុន្តែបុរសនៅមិនទាន់ទទួលយកសិទ្ធិនេះបានទូលំទូលាយនៅឡើយទេ។ បុរសមួយចំនួននៅតែគិតថា តួនាទីរបស់ស្ត្រីគឺនៅផ្ទះ ដាំបាយ ហើយប្រសិនបើស្ត្រីមានដំណែងខ្ពស់ជាងបុរស បុរសនោះហាក់បីដូចជាមានឋានៈអន់ជាងមិត្តភក្តិរបស់ខ្លួន។

សមភាពយេនឌ័រ គឺជាបញ្ហាស្នូលមួយនៃដំណើរការអភិវឌ្ឍន៍ និងមិនអាចផ្តាច់ចេញពីបញ្ហាសង្គមផ្សេងទៀតបានឡើយ។ បញ្ហាគន្លឹះគឺត្រូវធ្វើយ៉ាងណាដើម្បីកែលំអរសកម្មភាពយេនឌ័រនៅគ្រប់វិស័យទាំងអស់ ក្នុងគោលបំនងស្វែងរកនូវជំនាញ និងឋានៈដែលចាំបាច់ដល់ស្ត្រី ក្នុងការចូលរួមនៅក្នុងសង្គមបច្ចុប្បន្ន ដោយឈរលើមូលដ្ឋានស្មើភាពគ្នានឹងបុរស។

សមភាពយេនឌ័រមិនមែនមានន័យថា ស្ត្រីនិងបុរសមានចំនួនស្មើគ្នា ឬក៏មានន័យថា សម្រាប់តែស្ត្រីនោះទេ។ សមភាពយេនឌ័រតម្រូវអោយស្ត្រី និងបុរស ក្មេងស្ត្រី និងក្មេងប្រុស មានឱកាសស្មើគ្នាក្នុងការប្រើសិទ្ធរបស់ខ្លួនដើម្បីទទួលបានសុវត្ថិភាព និងធនធាននានា និងសិទ្ធក្នុងការបញ្ចេញមតិយោបល់។ ការផ្តល់សិទ្ធិអំណាយអោយស្ត្រី នឹងធានាបានថាស្ត្រី និងបុរស គឺជាដៃគូស្មើភាពគ្នាក្នុងការអភិវឌ្ឍន៍។

ប្រទេសកម្ពុជាបានបង្ហាញនូវការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការធានាបាននូវសមភាពយេនឌ័រ តាមរយៈគោលដៅអភិវឌ្ឍន៍ជាអាទិភាពរបស់ខ្លួន ការចុះហត្ថលេខាលើការប្រកាសនានា ការបង្កើតគណកម្មការលើកម្ពស់ស្ត្រីនៅគ្រប់ក្រសួង ការផ្តល់កូតាដល់ស្ត្រីក្នុងការចូលរួមក្នុងរដ្ឋបាលផ្សេងៗ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (MAFF, ២០០៦)។

## ២.៦ កត្តារាំងស្ទះរបស់ស្ត្រីជនបទ

### ២.៦.១ ការកាន់កាប់ដីធ្លី

នៅលើពិភពលោក មានប្រទេសជាច្រើនដែលមិនទាន់ផ្តល់សិទ្ធគ្រប់គ្រាន់សម្រាប់ស្ត្រីក្នុងការកាន់កាប់ដីធ្លីដោយឯករាជ្យនៅឡើយទេ។ នៅក្នុងច្បាប់ ស្ត្រីជារឿយៗមិនត្រូវបានធានាអោយមានសិទ្ធក្នុងការកាន់កាប់ដីធ្លីនោះទេ។ នៅក្នុងការអនុវត្តន៍នៃទំនៀមទម្លាប់ ឬក៏ប្រពៃណី ការកាន់កាប់ដីដោយផ្ទាល់របស់ស្ត្រីក៏នៅមានកំរិតនៅ ឡើយ។ ការមានសិទ្ធកាន់កាប់ដីធ្លីមិនត្រឹមតែកំណត់ពីទ្រព្យសម្បត្តិដែលបុគ្គលម្នាក់មាននោះទេ តែមានបានកំណត់នូវលទ្ធភាពដែលបុគ្គលម្នាក់អាចទទួលបាននូវប្រាក់កម្ចី ការគាំទ្រផ្នែកសេវាកម្មកសិកម្ម និងអំណាចនៅក្នុងសង្គម ក្នុងការចរចារដើម្បីទទួលបានធនធាន និងការអំណាចក្នុងការសម្រេចចិត្ត។ ស្ត្រីជនបទមានសិទ្ធិកាន់កាប់ដីធ្លីក្នុងនាមជាអ្នកម្ចាស់និងអ្នកប្រើប្រាស់ សព្វថ្ងៃនេះស្ថិតនៅក្រោមរូបភាពស្មុគស្មាញនៃជម្លោះរវាងសិទ្ធស្របច្បាប់និងច្បាប់ទំនៀមទម្លាប់ ក៏ដូចជា ការផ្ទេរទ្រព្យសម្បត្តិពីគ្រួសារ និងការអនុវត្តរបស់បុគ្គល(FAO, ២០០៥)។

ដោយសារមានការកើនឡើងនូវជម្លោះដីធ្លី ប្រទេសកម្ពុជាកំពុងដោះស្រាយបញ្ហានេះតាមទិដ្ឋភាពច្បាប់ទាក់ទងនឹងកម្មសិទ្ធិ និងសិទ្ធិទទួលកេរ្តិ៍ដំណែល។ ច្បាប់ភូមិបាលឆ្នាំ២០០១ និងអនុក្រឹត្យស្តីពី សម្បទានដីសង្គមកិច្ចបានចែងពីសិទ្ធិ ការទទួល និងការគ្រប់គ្រងដីធ្លី។ ទោះបីជាមានអ្នកខ្លះជឿថាគ្មានការរើសអើងចំពោះស្ត្រី ក្រុមជនជាតិភាគតិច និងអ្នកក្រីក្រក៏ដោយ ក៏នៅមានក្រុមជនងាយរងគ្រោះជាច្រើនទៀត ដែលត្រូវបានគេដកហូតដីធ្លី និងមានលទ្ធភាពតិចតួចក្នុងការកាន់កាប់ដីធ្លី។ ករណីនេះ នៅពេលដែលពួកគេដាក់របស់ធានា ឬទ្រព្យសម្បត្តិបញ្ចាំ ដើម្បីទទួលបានប្រាក់កម្ចី ការលែងលះ និងសិទ្ធិក្នុងការតវ៉ាលើដីធ្លី។ គ្រួសារដែលស្ត្រីជាមេគ្រួសារកាន់កាប់ដីធ្លី មានទំហំតូចជាគ្រួសារដែលបុរសជាមេគ្រួសារ ជាពិសេសពួកគេតែងប្រឈមមុខនឹងភាពក្រីក្រ (MAFF, ២០០៦)។

កន្លងមកការចុះបញ្ជីកម្មសិទ្ធិដីធ្លីមិនមានការចុះហត្ថលេខារួមគ្នាប្តី និងប្រពន្ធទេ។ ជាទូទៅគេចុះតែឈ្មោះប្តីប៉ុណ្ណោះ ជាពិសេសនៅតាមតំបន់ជនបទ។ ការការពារសន្តិសុខស្ត្រីកាន់តែមានសារៈសំខាន់ខ្លាំងឡើង នៅពេលមានការដាក់សម្ពាធលើដីធ្លីកាន់តែមានភាពតានតឹង និងការចាប់យកដីធ្លីកើតឡើង។ សូម្បីតែនៅពេលមានឈ្មោះទាំងប្តី និងប្រពន្ធនៅលើបញ្ជីកម្មសិទ្ធិដីធ្លីក៏ដោយ ក៏បុរសនៅតែជាអ្នកសម្រេចចិត្តធំជាងលើការប្រើប្រាស់ដីធ្លី។ ស្ត្រីក្រីក្រភាគច្រើនរស់នៅក្នុងគ្រួសារដែលបុរសជាមេគ្រួសារ (MAFF, ២០០៦)។

### ២.៦.២ ការដកហូតធនធានធម្មជាតិ

ស្ត្រីគឺជាអ្នកផលិតផលិតផលកសិកម្ម ហើយផលិតផលទាំងអស់នោះពឹងផ្អែកលើធនធានធម្មជាតិជាធនធានចំបង ដើម្បីដាំដុះដំណាំ បន្លែជុំវិញផ្ទះ ការនេសាទ ការកែច្នៃម្ហូបអាហារ និងសំភារៈនានា។ ស្ត្រីក៏បានដកហូតនូវអនុផលព្រៃឈើសម្រាប់បរិភោគ និងផលិតផលិតផលកសិកម្ម។ ព្រៃឈើក៏បានផ្តល់នូវអុស ជំរក និងរុក្ខជាតិជាឱសថ។ យ៉ាងណាមិញ សុវត្ថិភាពស្បៀងអាហារ និងសេដ្ឋកិច្ចសហគមន៍មូលដ្ឋាន ត្រូវបានទទួលរងផលប៉ះពាល់ដោយសារការបាត់បង់នូវលទ្ធភាពក្នុងការដកហូតនូវធនធានធម្មជាតិ។ ការសឹករិករិលនៃធនធានធម្មជាតិបានជះឥទ្ធិពលជាអវិជ្ជមានដល់ផលិភាពរបស់ស្ត្រីនៅជនបទ និងកម្រិតជីវភាពរបស់ពួកគាត់ (FAO, ២០០៥)។

ការសិក្សាមួយបានបង្ហាញពី កម្រិតជីវភាពរបស់សហគមន៍ជនជាតិភាគតិចនៅសារាវាក់ខាងជើងនៃប្រទេសម៉ាឡេស៊ីដែលរស់នៅអា

ស្រ័យលើការបរបាញ់ ប្រមូលអនុផលព្រៃឈើ និងកសិកម្មពនេចរ ត្រូវទទួលផលប៉ះពាល់ដោយសារការកាប់ឈើ និងការបាត់បង់ព្រៃឈើ ដែលជាលទ្ធផលនាំមកនូវការសឹករេចរិលដី ការថយចុះនូវគុណភាពទឹកទន្លេ ការបាត់បង់ជីវចម្រុះ និងការថយចុះនូវចំនួនត្រីធម្មជាតិ និងសត្វព្រៃ។ អាស្រ័យហេតុនេះ ដើម្បីរកមុខរបរផ្សេងទៀតមកជំនួស ធ្វើអោយមានការកើនឡើងការចំណាកស្រុករបស់បុរស ដោយបន្សល់ទុកស្ត្រីនៅប្រឈមមុខដោះស្រាយនឹងបញ្ហាការធ្លាក់ចុះនូវធនធានធម្មជាតិ (FAO, ២០០៥)។ នៅក្នុងរបាយការណ៍របស់ Elise Wall (២០១៤) បានលើកឡើងថា ការប្រែប្រួលអាកាសធាតុបានធ្វើអោយមានការកើនឡើងនូវការចំណាកស្រុក និងមានសម្ពាធផ្នែកសេដ្ឋកិច្ច ដែលធ្វើអោយស្ត្រីកម្ពុជាត្រូវបន្ថែមទំនួលខុសត្រូវបន្ថែមទៀតនៅក្នុងការងារកសិកម្ម និងជានាពីជីវភាពរស់នៅរបស់គ្រួសារ។

### ២.៦.៣ ក្រុមមូលដ្ឋាន និងធនធានសង្គម

ការអភិវឌ្ឍន៍ក្រុមស្ត្រី ជាយុទ្ធសាស្ត្រដើម្បីជួយអោយស្ត្រីបានទទួលនូវព័ត៍មាន ពង្រឹងនូវអំណាចក្នុងការចរចាររបស់ពួកគាត់ និងបង្កើតឱកាសអោយគាត់អាចទទួលបានផលប្រយោជន៍សេដ្ឋកិច្ច។ ទោះបីជាយ៉ាងណាក៏ដោយ ជាក់ស្តែង ដោយសារតែចំណេះដឹងតិចតួចពីយេនឌ័រ ដំណើរការរបស់សហគមន៍ដែលធ្លាប់មានពីមុន និងបញ្ហាពេលវេលារបស់ស្ត្រីខ្លួនឯងផ្ទាល់ បានធ្វើអោយស្ត្រីមិនអាចចូលរួមជាសកម្មជាមួយអង្គការដែលមានបំណង ផ្តល់នូវប្រយោជន៍ធនធានសង្គម និងការពង្រឹងសិទ្ធិអំណាចរបស់ស្ត្រីបានឡើយ។ ច្បាប់សង្គម បទដ្ឋានសង្គម គោលគំនិត សិទ្ធិនៃការកាន់កាប់ដីធ្លី សេដ្ឋកិច្ចគ្រួសារ ស្ថានភាពសង្គម និងឥរិយាបថបុគ្គល គឺជាកត្តាដែលរាំងស្ទះមិនអាចអោយស្ត្រីចូលរួមក្នុងស្ថាប័នស្របច្បាប់ដើម្បីការពារបរិស្ថាន។ ឧទាហរណ៍ ស្ត្រីដែលមានទំនួលខុសត្រូវក្នុងផ្ទះផង និងក្នុងកសិដ្ឋានផង គឺមានភាពមមាញឹកពេញមួយថ្ងៃ មិនអាចចូលរួមប្រជុំបានទេ។ ស្ត្រីខ្លះទៀត គឺខ្វះ បណ្តាញទាក់ទងជាមួយមន្ត្រី និងប្រធានសមាគមន៍ដែលជាបុរស (FAO, ២០០៥)។

នៅក្នុងប្រទេសកម្ពុជា ស្ត្រីដែលគ្មានស្វាមី និងស្ត្រីដែលមានជីវភាពក្រីក្រ ត្រូវបានរកឃើញថាមានទំនាក់ទំនងដាច់ឆ្ងាយពីអ្នកភូមិដទៃទៀត ដោយសារតែពួកគាត់ពុំមានពេលវេលាគ្រប់គ្រាន់សម្រាប់ប្រាស្រ័យទាក់ទងគ្នា ដោយពួកគាត់ត្រូវចំណាយពេលជាច្រើនធ្វើការតែម្នាក់ឯង ចំអិនអាហារ ដងទឹក និងថែទាំផ្ទះសម្បែង។ ដោយសារតែបន្ទុកការងារដែលមានមុខងារជាច្រើន ដូចជា ការងារដែលមិនទទួលបានប្រាក់កម្រៃនៅក្នុងកសិដ្ឋាន និងក្នុងផលិតកម្ម ការងារផ្ទះ និងទំនួលខុសត្រូវក្នុងការមើលថែទាំសមាជិកគ្រួសារ ធ្វើអោយស្ត្រីបានបាត់បង់ឱកាសក្នុងការចូលរួមជាសកម្ម និងមានប្រសិទ្ធភាពជាមួយនឹងអង្គការនៅក្នុងមូលដ្ឋាន។ ការសិក្សាមួយនៅក្នុងប្រទេសថៃបានរកឃើញ ពីភាពខុសគ្នារវាងស្ត្រី និងបុរសក្នុងការចូលរួមក្នុងអង្គការមូលដ្ឋាន។ ស្ត្រីភាគច្រើនចូលរួមជាមួយអង្គការមូលដ្ឋានដែលផ្តោតសំខាន់លើ សេដ្ឋកិច្ចនៅក្នុងផ្ទះ និងកិច្ចការផ្ទះសម្បែង។ ចំណែកឯ បុរសភាគច្រើនចូលរួមជាមួយអង្គការដែលស្វែងរកវិធីសាស្ត្របង្កើនផលិតភាពកសិកម្ម និងបង្កើនប្រាក់ចំណូល។ ម៉្យាងវិញទៀត លក្ខខណ្ឌក្នុងការចូលរួមក្នុងអង្គការមូលដ្ឋាន ទាមទារឲ្យមាន កម្រិតនៃទ្រព្យសម្បត្តិដូចជា ដីធ្លី សត្វចិញ្ចឹម ឬក៏ធនធានមនុស្ស។ ជាហេតុធ្វើអោយ គ្រួសារក្រីក្រ និងស្ត្រីមិនអាចចូលរួមជាសមាជិកបាន។ ហេតុដូច្នេះហើយ ស្ត្រីមានលទ្ធភាពតិចជាងបុរសក្នុងការសម្រេចចិត្ត នៅក្នុងអង្គការមូលដ្ឋាន (FAO, ២០០៥)។

### ២.៦.៤ ការអប់រំ

ភាពខុសគ្នានៃយេនឌ័រក្នុងការទទួលបានការអប់រំ គឺបណ្តាលអោយមានវិសមភាពក្នុងការការទទួលបានធនធានដទៃទៀត។ ការផ្តល់ការអប់រំអោយស្ត្រីមានសារៈសំខាន់ណាស់ក្នុងការពង្រឹងសិទ្ធិអំណាចស្ត្រី។ ស្ត្រីយ៉ាងហោចណាស់ត្រូវមានការអប់រំថ្នាក់មូលដ្ឋាន ដើម្បីអោយពួកគាត់អាចអភិវឌ្ឍន៍ជំនាញដែលទាក់ទងនឹងការពង្រីក

ផលិតភាពកសិកម្ម និងសកម្មភាពសេដ្ឋកិច្ចនានា។ ស្ត្រីដែលមិនមានការអប់រំថ្នាក់មូលដ្ឋាន ធ្វើអោយគាត់បាត់បង់ឱកាសថ្មីៗ និងនៅតែមិនមានលទ្ធភាពដូចបុរសក្នុងការចូលរួមសកម្មភាពអភិវឌ្ឍន៍ផ្សេងៗ។ នៅទូទាំងទ្វីបអាស៊ី គេបានរកឃើញថា ស្ត្រីមិនបានចូលរួមក្នុងការអប់រំ ក៏ដូចជាវគ្គបណ្តុះបណ្តាលផ្សេងៗស្មើគ្នាទៅនឹងបុរសទេ (FAO, ២០០៥)។

ជាក់ស្តែង នៅកម្ពុជា ក្នុងចំណោម១ភាគរយនៃកសិករដែលទទួលបានការផ្សព្វផ្សាយកសិកម្ម មានស្ត្រីតែ១០ភាគរយប៉ុណ្ណោះដែលទទួលបានការផ្សព្វផ្សាយ។ សេវាផ្សព្វផ្សាយភាគច្រើនមិនបានផ្តោតទៅលើជាស្ត្រី ឬបុរសនៅឡើយទេ។ នៅពេលដែលមានការផ្តល់សេវាកម្មតិចតួចនោះ ស្ត្រីពុំមានឱកាសទទួលបានការផ្តល់សេវាកម្មតិចតួចនោះទេ ដោយសារតែរវល់មើលថែទាំកូន បញ្ហាពេលវេលា ការធ្វើដំណើរ កត្តាចំណេះដឹង សេដ្ឋកិច្ច គ្រួសារ និងកត្តាសង្គម វប្បធម៌ (MAFF, ២០០៦)។

### ២.៦.៥ បច្ចេកទេស

ស្ត្រីនៅទីជនបទ មានតួនាទីជាអ្នកផលិតនៅក្នុងផលិតកម្មក្នុងកសិដ្ឋាន និងផ្ទះ ក៏ដូចជាអ្នកផ្តល់ការថែទាំត្រូវការជំនួយពីបច្ចេកទេស ដើម្បីសម្រួលការងាររបស់ពួកគាត់ និងបង្កើនផលិតភាពនិងសុខមាលភាពក្នុងគ្រួសារ។អ្នកវិទ្យាសាស្ត្រជនជាតិឥណ្ឌាម្នាក់បានលើកឡើងថា ប្រសិនបើស្ត្រីទទួលបានការពង្រឹងសិទ្ធិអំណាចផ្នែកព័ត៌មានបច្ចេកវិទ្យា និងជំនាញ គ្រប់សមាជិកទាំងអស់នៅក្នុងគ្រួសារនឹងទទួលបានផលប្រយោជន៍។ ទោះបីជាយ៉ាងណាក៏ដោយ ទំនោរនៃប្រពៃណី បានចាក់ស្រេះនៅក្នុងអត្តចរិតរបស់អ្នកវិទ្យាសាស្ត្រ អ្នកបច្ចេកទេស និងអ្នកផ្សព្វផ្សាយ បច្ចេកទេស ដែលបង្កអោយមានគម្លាតរវាងតម្រូវការខុសគ្នារបស់យេនឌ័រ និងសកម្មភាពសម្រាប់ផ្តល់ និងអភិវឌ្ឍន៍បច្ចេកទេស (FAO, ២០០៦)។

នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ការអភិវឌ្ឍន៍បច្ចេកទេស និងកម្មវិធីផ្សព្វផ្សាយ មិនបានឆ្លើយតបទៅនឹងបន្ទុកការងារដែលពាក់ព័ន្ធនឹងសកម្មភាពជាប្រចាំរបស់ស្ត្រីនោះទេ។ ជាក់ស្តែង កម្មវិធីទាំងអស់នោះមិនបានកត់សម្គាល់ពីតម្រូវការរបស់ស្ត្រី ថាតើបច្ចេកទេសបែបណាដែលគាត់ត្រូវការសម្រាប់បង្កើនផលិតភាពការងាររបស់ពួកគាត់។ ឧទាហរណ៍ដូចជា នៅប្រទេសនេប៉ាល់ជាដើម មានការខិតខំប្រឹងប្រែងតិចតួចណាស់ក្នុងការបង្កើតឧបករណ៍ ដើម្បីសម្រួលបន្ទុកដល់ស្ត្រី បើទោះបីជានៅក្នុងកម្មវិធីជាតិ និងគោលនយោបាលជាតិ បានព្យាយាមលើកកម្ពស់ការពង្រឹងសិទ្ធិអំណាចស្ត្រីក៏ដោយចុះ (FAO, ២០០៦)។

### ២.៦.៦ ឥណទាន

ការផ្តល់ឥណទាន គឺជាប្រភពធនធានដ៏សំខាន់សម្រាប់បុរស និងស្ត្រីនៅជនបទ នៅក្នុងទ្វីបអាស៊ី និងតំបន់ប៉ាស៊ីហ្វិច។ ផលចំណេញផ្នែកសេដ្ឋកិច្ចដ៏ខ្ពស់ បានមកពីឥរិយាបថនៃការសងមកវិញដ៏ល្អប្រសើររបស់ស្ត្រីជនបទ។ ក្រុមមីក្រូក្រេឌីត និងក្រុមមីក្រូហិរញ្ញវត្ថុ ផ្តល់នូវកម្ចីរយៈពេលខ្លីបានយ៉ាងល្អ បានជំរុញមានចលនាចរន្តសាច់ប្រាក់ដែលបានបើកឱកាសសម្រាប់ការធ្វើជំនួញ។ យ៉ាងណាមិញ នៅក្នុងតំបន់អាស៊ី ឥទ្ធិពលចំរុះនៃឥណទាន ត្រូវបានគេលើកឡើង។ ទាំងអស់នោះរួមមានដូចជា គុណសម្បត្តិនៃមីក្រូហិរញ្ញវត្ថុទៅលើកម្រិតជីវភាពរបស់ស្ត្រីនៅទីជនបទ និងសាមគ្គីភាពសង្គម ក៏ដូចជាឥទ្ធិពលក្នុងការផ្លាស់ប្តូរទំនាក់ទំនងសង្គម។ ផ្ទុយទៅវិញ ឥទ្ធិពលជាអវិជ្ជមាន គឺអាចធ្វើអោយមានជម្លោះក្នុងសហគមន៍។ បុរសមានទំនោរក្នុងការប្រើប្រាស់ស្ត្រី ដោយអោយស្ត្រីជាអ្នកប្រឈមមុខក្នុងការទូទាត់កម្ចី និងការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ។

នៅកម្ពុជា ឥណទានកសិកម្ម និងជនបទ ជាប្រភេទធនធានថ្មីមួយ។ តាមទម្លាប់ឥណទានមានលក្ខណៈជាបុគ្គល និងជាការប្រឹងប្រែងសន្សំដោយលំបាក។ ប្រាក់កម្ចីប្រើប្រាស់ដើម្បីបំពេញតម្រូវការក្នុងជីវភាពរស់នៅ និងផលិតកម្មកសិកម្ម។ ការខ្ចីប្រាក់ពីសាច់ញាតិ អាចមិនគិតការប្រាក់ ប៉ុន្តែបើខ្ចីពីអ្នករកស៊ីចងការប្រាក់វិញ អាចមានការប្រាក់ច្រើនជាង១០០ភាគរយក្នុងមួយឆ្នាំ។ សេវាកម្មមីក្រូហិរញ្ញវត្ថុរបស់អង្គការក្រៅរដ្ឋាភិបាល (NGOs) កំពុងតែកើនឡើងជាបន្តបន្ទាប់ ប៉ុន្តែចំនួននេះនៅតែមិនទាន់គ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការដែលចេះតែកើនឡើងរបស់គ្រួសារកសិករនៅឡើយទេ។ ជាធម្មតា

ស្ថាប័នមីក្រូហិរញ្ញវត្ថុតែងផ្តល់សេវាហិរញ្ញវត្ថុតែងផ្តល់សេវាប្រាក់កម្ចី ដោយពុំមានការកសាងសមត្ថភាពដើម្បីប្រើប្រាស់ប្រាក់កម្ចីអោយមានប្រយោជន៍ខ្ពស់នោះទេ (MAFF, ២០០៦)។

## ២.៧ គោលនយោបាយបញ្រ្ជាបយេនឌ័ររបស់ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ

គោលនយោបាយយេនឌ័រនេះ ផ្តល់ជាមូលដ្ឋានគ្រឹះ សម្រាប់ធ្វើការបញ្រ្ជាបយេនឌ័រ និងជាវិធីសាស្ត្រមួយចំពោះវិស័យកសិកម្ម និងការសម្របសម្រួល។ វាផ្តល់ជាគោលដៅមួយសម្រាប់ការអនុវត្តតាមតម្រូវការជាតិ ក៏ដូចជាអន្តរជាតិ នៅក្នុងវិស័យកសិកម្ម និងការអភិវឌ្ឍន៍ជនបទនៅកម្ពុជា។ ដើម្បីដោះស្រាយនូវឧបសគ្គទាំងឡាយ ដែលបានជួបប្រទះនៅក្នុងការបញ្រ្ជាបយេនឌ័រ ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទបានដាក់ចេញនូវគោលការណ៍ សំខាន់ៗដូចខាងក្រោមៈ

- គោលនយោបាយយេនឌ័រ ត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋានគ្រឹះដ៏រឹងមាំ ដែលបំពេញតាមលក្ខខណ្ឌជាតិ និងអន្តរជាតិ។ គោលនយោបាយនេះ ត្រូវបង្កើតឡើង នៅពេលដែលវិស័យកសិកម្មនៅកម្ពុជាកំពុងធ្វើការផ្លាស់ប្តូរ ដែលឈានដល់ចំនុចរួមមួយសម្រាប់បង្កើតកម្មវិធីគាំទ្រដល់ ជនក្រីក្រ និងស្ត្រី។

- ការបញ្រ្ជាបយេនឌ័រ គឺជាដំណើរការមួយឈានទៅដល់សមភាពយេនឌ័រ គឺជាសេចក្តីណែនាំរបស់រដ្ឋាភិបាលកម្ពុជា។ ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ ជាមូលដ្ឋានគ្រឹះមួយក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមមួយដ៏សំខាន់ក្នុងចំណោមយានទាំងអស់ នឹងគោរពតាមសេចក្តីណែនាំនេះ។

- ដំណើរការឆ្ពោះទៅរកសមភាពយេនឌ័រ ផ្តោតគោលដៅទៅលើស្ត្រីផង និងបុរសផង ជាពិសេសទៅលើស្ត្រី សំដៅកែតម្រូវគុល្យភាពនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមប្រកបដោយសមធម៌។

- សមភាពយេនឌ័រ ផ្តល់សិទ្ធិអំណាចអោយស្ត្រី សំដៅធានាថា ស្ត្រី និងបុរសជាដៃគូស្មើភាពគ្នាក្នុងការអភិវឌ្ឍន៍ និងធានាថាពួកគេជាអ្នកកំណត់លើទិសដៅនៃការផ្លាស់ប្តូរកត្តាសេដ្ឋកិច្ច និងសង្គម ដែលជះឥទ្ធិពលមកលើការរស់នៅរបស់ពួកគេ។

- គោលការណ៍មួយផ្សេងទៀត ដែលមានទិសដៅស្របជាមួយយុទ្ធសាស្ត្រយេនឌ័រ គឺការគោរពតាមសិទ្ធិមនុស្ស និងសិទ្ធិទទួលបានការអប់រំ ការថែទាំសុខភាព ព័ត៌មាន និងធនធានចាំបាច់នានា។

- សមភាពយេនឌ័រ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមមានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និត។ ដូច្នេះបើបាត់ផ្នែកណាមួយនោះ គេនឹងមិនអាចសម្រេចបានបទដ្ឋានដូចដែលបានចែងនៅក្នុងគោលដៅជាតិ ស្តីពីការកែលំអគុណភាពនៃការរស់នៅរបស់ស្ត្រី បុរស និងកុមារទាំងអស់នោះទេ។

- ដោយសារការផ្លាស់ប្តូរឥរិយាបទ និងការអនុវត្ត ដែលជាដំណើរការមួយទាមទាររយៈពេលយូរ ដូច្នេះការបញ្រ្ជាបយេនឌ័រជាដំណើរការរៀនសូត្រមួយសម្រាប់គូបផ្សំទ្រឹស្តី និងការអនុវត្តជាក់ស្តែងបញ្ចូលគ្នា សំដៅពង្រឹងការអនុវត្តអោយរឹងមាំបន្ថែមទៀត។

- កិច្ចខិតខំប្រឹងប្រែងដែលផ្តោតជាជាក់លាក់ទៅលើស្ត្រីត្រូវតែដាក់បញ្ចូល (MAFF, ២០០៦)។

## ២.៨ ការវិភាគប្រព័ន្ធកសិកម្ម

### ២.៨.១ គោលគំនិតរបស់ប្រព័ន្ធកសិកម្ម (Farming system concept)

ប្រព័ន្ធកសិកម្ម (Farming System) ជាប្រព័ន្ធដ៏ស្មុគស្មាញ នៃការរួមបញ្ចូលគ្នា នៃប្រព័ន្ធដំណាំ (Cropping System) និងប្រព័ន្ធចិញ្ចឹមសត្វ( Livestock Rearing System)។ ការសិក្សាតែទៅលើបច្ចេកទេស និងការវិភាគសេដ្ឋកិច្ច នៃការដាំដំណាំ និងការចិញ្ចឹមសត្វតែមួយមុខ មិនទាន់គ្រប់គ្រាន់នៅឡើយទេ។ បើទោះបីជា វាមានសារៈសំខាន់ ប៉ុន្តែ វាមិនទាន់ពន្យល់អស់ពីជម្រើសរបស់កសិករថា ហេតុអ្វីបានជាគាត់សម្រេចជ្រើសយកបច្ចេកទេសនោះ និងទទួលយកផលសេដ្ឋកិច្ចដែលបាននោះនៅឡើយទេ។ ការសិក្សាពីប្រព័ន្ធកសិកម្ម នឹងជួយយើងឆ្លើយនូវសំណួរជាច្រើន ដូចជា តើអ្វីដែលធ្វើអោយកសិករសម្រេចប្រើប្រាស់ពលកម្មទៅលើប្រភេទដំណាំមួយ ជាជាងដំណាំដទៃទៀត? ហេតុអ្វីបានជាកសិករចំណាយប្រាក់ទិញដីដើម្បីដាំដំណាំមួយប្រភេទ ជាជាងដំណាំផ្សេងទៀត? តើដំណាំអ្វីដែលគាត់ផ្តល់សារៈសំខាន់ជាងគេ? តើអ្វីជាការរំពឹងទុករបស់កសិករទៅថ្ងៃខាងមុខ?

ការវិភាគប្រព័ន្ធកសិកម្មរួមមានដូចជា៖
- ការវិភាគដែលសិក្សាពីទំនាក់ទំនងរវាងប្រព័ន្ធរងនីមួយៗដែលបង្កើតជាប្រព័ន្ធកសិកម្ម
- ការស្វែងយល់ពីរបៀបដែលកសិករបែងចែកកត្តាផលិតកម្មនៃផលិតកម្មដំណាំទៅគ្រប់សកម្មភាព
  ខុសៗគ្នា (ប្រព័ន្ធដំណាំ និងប្រព័ន្ធចិញ្ចឹមសត្វ) ដូចដែលបង្ហាញនៅ គំនូសតាងខាងក្រោម




គំនូសតាងទី១៖ ទំនាក់ទំនងរវាងកត្តាផលិតកម្ម និងប្រព័ន្ធដំណាំ និងប្រព័ន្ធចិញ្ចឹមសត្វ (Didier, ២០១១)

២.៨.២ ការកំណត់ប្រភេទនៃប្រព័ន្ធផលិតកម្មផ្សេងៗ (Identify various farming systems)

នៅក្នុងការវិភាគតំបន់មួយ ប្រព័ន្ធកសិកម្មគឺជាការប្រជាប់បញ្ចូលគ្នារវាងការដាំដំណាំ និងការចិញ្ចឹមសត្វ និងពេលខ្លះជាប្រព័ន្ធការកែច្នៃកសិផលកសិកម្ម។ ជាទូទៅក្នុងប្រព័ន្ធកសិកម្មមួយត្រូវបានអនុវត្តដោយកសិករមួយក្រុមដែលអាចទទួលបានធនធានដូចគ្នាក្នុងកំរិតប្រហាក់ប្រហែលគ្នា។ តាមទ្រឹស្តី ការប្រចាប់បញ្ចូលគ្នារវាងប្រព័ន្ធដំណាំ និងប្រព័ន្ធចិញ្ចឹមសត្វអាចមានច្រើនប្រព័ន្ធ។ ប៉ុន្តែជាក់ស្តែង នៅក្នុងតំបន់មួយ ចំនួនប្រព័ន្ធគឺមានព្រំដែនកំណត់ គឺវាអាស្រ័យទៅលើលក្ខណៈនៃដំណាំ និងសត្វនីមួយៗ និងតម្រូវការនៃកត្តាផលិតកម្មនីមួយៗ។

លើសពីនេះទៅទៀត ដំណាំមួយចំនួនឬសកម្មភាពចិញ្ចឹមសត្វមួយចំនួនអាចជួយគ្នាទៅវិញទៅមក ឬក៏អាចប្រកួតប្រជែងគ្នាដោយយោងទៅលើការប្រើប្រាស់ដី និងប្រតិទិននៃកម្លាំងពលកម្ម។ ពេលខ្លះវាមានអន្តរទំនាក់ទំនងគ្នាដោយ ធាតុចេញនៃដំណាំមួយអាចយកមកធ្វើជាធាតុចូលនៃដំណាំមួយផ្សេងទៀត។ ឧទាហរណ៍ដូចជា អនុផលនៃដំណាំមួយ អាចយកមកធ្វើចំណីអោយសត្វ ហើយកាកសំណល់នៃសត្វអាចយកមកធ្វើជាជីសម្រាប់ការដាំដំណាំវិញ។

យ៉ាងណាមិញ កសិករមិនសុទ្ធតែទទួលបានធនធានដូចគ្នាទាំងអស់នោះទេ៖
- ទំហំដី និងគុណភាពដីដែលគាត់មានគឺខុសៗគ្នា ពិព្រោះស្ថិតនៅក្នុងប្រព័ន្ធអេកូឡូស៊ីផ្សេងគ្នា និងទទួលបានភាពងាយស្រួលខុសគ្នាៗ
- កម្លាំងពលកម្មពីក្នុងគ្រួសារ ឬកម្លាំងពលកម្មដែលគាត់ជួល គឺមិនស្មើគ្នា
- ទុនផលិតកម្ម (សម្ភារៈ និងថវិកា) គឺខុសៗគ្នាពីកសិករម្នាក់ទៅកសិករម្នាក់

ចំនួននៃប្រព័ន្ធកសិកម្ម កំណត់ដោយចំនួនដែលកំណត់ដោយភាពដែលអាចបូកបញ្ចូលគ្នានៃប្រព័ន្ធដំណាំ និងប្រព័ន្ធចិញ្ចឹមសត្វ។

ការសិក្សាពីប្រវត្តិសាស្ត្រអាចជួយអោយយើងកំណត់ពីប្រព័ន្ធកសិកម្មដែលអនុវត្តនៅក្នុងតំបន់បាន។ ការសិក្សាពីប្រវត្តិសាស្ត្រអាចអោយយើងដឹងពីប្រជាសាស្ត្រនៅក្នុងតំបន់ ប្រភពដើមនៃកសិករ ការមកដល់នៃអ្នកចំណូលស្រុកថ្មី

ពីការប្រែប្រួលនៃការប្រើប្រាស់ដីពីដីដែលមិនធ្លាប់ធ្វើកសិកម្មមកធ្វើកសិកម្ម ការប្រែប្រួលនៃម្ចាស់កម្មសិទ្ធិដីនិងសិទ្ធិ និងទំនាក់ទំនងនៃកសិករ និងសកម្មភាពកសិកម្មនានា។ កត្តាទាំងអស់នេះ មានសារៈសំខាន់ណាស់ក្នុងការបែងចែកកសិករទៅតាមក្រុមផ្សេងៗគ្នា អាស្រ័យទៅលើដីដែលគាត់មាន ទាំងបរិមាណ និងគុណភាព។ ដើម្បីបែងចែកកសិករទៅតាមក្រុមផ្សេងៗគ្នា ដោយយោងទៅលើទុនវិនិយោគដែលគាត់មាន ការសម្ភាសន៍ពីប្រវត្តិសាស្ត្រគឺមានសារៈសំខាន់ណាស់ ដោយវាអាចអោយយើងដឹងពីនៅពេលណាដែលដំណាំផ្សេងៗ និងសត្វផ្សេងៗ ត្រូវបានយកមកអនុវត្ត នៅពេលណា ឬនៅក្រោមលក្ខខណ្ឌអ្វីដែល ពូជថ្មី ឧបករណ៍ថ្មី និងបច្ចេកទេសថ្មីត្រូវបានគេណែនាំ និងយកមកអនុវត្ត។ តាមរយៈសម្មតិកម្មទាំងអស់នេះ បង្ហាញថាការប្រែប្រួលបច្ចេកទេសគឺអាចជះឥទ្ធិពលដល់កសិករ និងទំនោររបស់កសិករ។ កសិករខ្លះអាចទទួលផលប្រយោជន៍ពីការផ្លាស់ប្តូរនេះ ស្របពេលដែលកសិករផ្សេងទៀតមិនអាចទទួលផលពីវា ហើយវាកាន់តែធ្វើអោយអាក្រក់ជាងមុនទៅទៀត។ ការប្រែប្រួលនៃប្រវត្តិសាស្ត្រអាចជួយអោយយើងដឹងពីការប្រែប្រួលនៃប្រព័ន្ធកសិកម្មខុសៗគ្នា ហើយវាអាចជួយអោយយើងដឹងពីប្រព័ន្ធកសិកម្មនាពេលបច្ចុប្បន្ន។

នៅចុងបញ្ចប់នៃការសិក្សាពីប្រវត្តិសាស្ត្រ ការធ្វើចំណាត់ថ្នាក់នៃប្រព័ន្ធអាចធ្វើបានដោយពឹងផ្អែកលើធនធានដែលគាត់មាន និងប្រព័ន្ធកសិកម្មដែលគាត់អនុវត្ត។

ការបែងចែកប្រព័ន្ធកសិកម្មទុកជាមុន ជួយអោយយើងងាយស្រួលក្នុងការកំណត់សំណាកដែលយើងនឹងជ្រើសមកសម្ភាសន៍នៅពេលដែលយើងវិភាគប្រព័ន្ធកសិកម្ម ហើយវាជួយអោយយើងពិពណ៌នាពីប្រព័ន្ធកសិកម្មនីមួយៗ។ ការជ្រើសរើសសំណាកគឺមិនមានលក្ខណៈចៃដន្យ និងមិនតាមរយៈស្ថិតិនោះទេ ធ្វើយ៉ាងណាអាចអោយយើងសម្ភាសន៍គ្រប់កសិកម្មនៃគ្រប់ប្រព័ន្ធកសិកម្ម (Didier, ២០១១)។

២.៨.៣ ការកំណត់លក្ខណៈនៃប្រព័ន្ធកសិកម្មផ្សេងៗគ្នា (Characterising the different farming systems)

លក្ខណៈបច្ចេកទេស និងលក្ខណៈសេដ្ឋកិច្ចរបស់ប្រព័ន្ធកសិកម្មពាក់ព័ន្ធទៅនឹង៖

- ការពិពណ៌នាពីរបៀបដែលកសិដ្ឋានត្រូវបានបង្កើតឡើង ពោលគឺ តើកត្តាផលិតកម្មអ្វីខ្លះដែលប្រព័ន្ធកសិកម្មមួយត្រូវការ
- ការពិពណ៌នា និងវិភាគពីវិធីតួនាទីនៃកសិដ្ឋានទាំងនោះ ពោលគឺ ពីរបៀបដែលប្រព័ន្ធដំណាំ និងប្រព័ន្ធចិញ្ចឹមសត្វត្រូវបានបូកបញ្ចូលគ្នា
- និង លទ្ធផលសេដ្ឋកិច្ចពីការបូកបញ្ចូលនៃប្រព័ន្ធទាំងនោះ

**ក. ការពិពណ៌នាពីកត្តាផលិតកម្ម**

❖ កម្លាំងពលកម្ម

នៅក្នុងតំបន់សិក្សា ជាទូទៅកម្លាំងពលកម្មនៅក្នុងកសិដ្ឋាន ច្រើនជាសមាជិកក្នុងគ្រួសារផ្ទាល់។ យ៉ាងណាមិញ ពេលខ្លះកសិករក៏ត្រូវការកម្លាំងពីខាងក្រៅគ្រួសារមកជួយក្នុងការងារកសិដ្ឋានផងដែរ។

យើងព្យាយាមកំណត់ តើនរណាខ្លះដែលមានវត្តមាននៅក្នុងកសិដ្ឋាន ដើម្បីដំណើរការសកម្មភាពក្នុងកសិដ្ឋានបាន? តើមនុស្សប៉ុន្មាននាក់ដែលត្រូវការដើម្បីបំពេញសកម្មភាពក្នុងប្រព័ន្ធកសិកម្មទាំងអស់នោះ? ខាងក្រោមនេះត្រូវបានគេចាត់ទុកជា កម្លាំងពលកម្មអចិន្ត្រៃយ៍ក្នុងកសិដ្ឋាន៖

- កម្លាំងពលកម្មក្នុងគ្រួសារ

តើមានសមាជិកក្នុងគ្រួសារប៉ុន្មាននាក់ដែលចូលរួមក្នុងការងារកសិដ្ឋាន? ហើយចំនួនមនុស្សប៉ុន្មាននាក់ដែលត្រូវការដើម្បីបំពេញការងារទាំងអស់នោះ? យើងត្រូវកត់ត្រាសមាជិកនីមួយៗក្នុងគ្រួសារ (ឪពុក ម្តាយ កូន តាមអាយុ និងភេទ យាយ តា ក្មួយ ។ល។) និងពេលវេលាដែលគាត់អាចធ្វើការក្នុងកសិដ្ឋានបាន ក៏ដូចជាកត្តាដែលធ្វើអោយគាត់មិនអាចចូលរួមក្នុងការងារកសិដ្ឋានបានដូចជា រវល់ក្នុងការសិក្សា ការងារផ្ទះ ឬការងារផ្សេងៗទៀត។

តើការងារទាំងអស់ត្រូវបែងចែកទៅអោយសមាជិកនានាធ្វើដោយវិធីណា? តើកំឡុងពេលណាក្នុងមួយឆ្នាំដែល ឪពុក ម្ដាយ យាយតា និងកូនធ្វើការនៅក្នុងកសិដ្ឋាន (អាស្រ័យទៅនឹងអាយុ និងភេទ)? ហើយតើការងារប្រភេទណាដែលសមាជិកនីមួយៗធ្វើ?

- កម្លាំងពលកម្មក្រៅគ្រួសារ

វាមានសារៈសំខាន់ណាស់ក្នុងការដឹង ពីការងារដែលកម្លាំងពលកម្មក្រៅគ្រួសារធ្វើ។ ចំនួនថ្ងៃ មុខងារ សមត្ថភាព និងលក្ខខណ្ឌការងារដែលគាត់ធ្វើអាចស្ថិតនៅក្នុងប្រភេទខាងក្រោម៖

- ប្រព័ន្ធនៃការជួយគ្នាទៅវិញទៅមក
- ពលកម្មដែលជួល (ទោះបីជាតម្លៃនៃការជួលក្នុងលក្ខណៈយោគយល់ក៏ដោយ)
- អាស្រ័យលើទំនាក់ទំនងសង្គមផ្សេងទៀត (ឧទាហរណ៍ ដូចជាការដោះដូរកម្លាំងជាថ្នូរនឹងការប្រើប្រាស់ដីណាមួយ ឬដើម្បីអាចប្រើប្រាស់ទឹក ឬ ខ្ចីសម្ភារៈ ឬគោសម្រាប់ភ្ជួរ)
- ពលកម្មដែលមិនចំណាយប្រាក់ជួល ប៉ុន្តែដោះដូរនឹងការរៀនសូត្រ និងទទួលបានបទពិសោធន៍

❖ ដីធ្លី

រាល់ប្រភេទដីទាំងអស់ត្រូវកំណត់អត្តសញ្ញាណ រួមមានដូចជា សិទ្ធក្នុងការកាន់កាប់ដី ដីដែលនៅឆ្ងាយ ដីដែលបច្ចុប្បន្នមិនយកមកប្រើប្រាស់ ប៉ុន្តែវាអាចមានលទ្ធភាពបង្កបង្កើនផល។

ដំណាក់កាលនៃការវិភាគទេសភាព (Landscape analysis) ចំណុចជាច្រើនត្រូវបានកំណត់អត្តសញ្ញាណ និងលើកយកមកបកស្រាយ។

- តើទំហំដីប៉ុន្មានដែលប្រើនៅក្នុងប្រព័ន្ធក្សេត្របរិស្ថាននៃទីតាំងរបស់ដី?
- តើគុណភាពនៃដីទាំងនោះយ៉ាងម៉េចដែរ? តើដីមើលទៅមានលក្ខណៈដូចម្ដេចដែរ? តើវាជម្រៅប៉ុន្មាន? មានជីវជាតិកំរិតណា? តើវាជាដីទំនាប ឬខ្ពង់រាប?
- តើមានការអភិវឌ្ឍន៍អ្វីខ្លះ (មានប្រលាយទឹក មានធារាសាស្ត្រ របង)? តើមានដើមឈើនៅក្នុងប្លង់ដីនោះទេ? បើមាន តើមានប៉ុន្មាន ហើយគេប្រើវាដើម្បីធ្វើអ្វី?
- តើកសិករអាចមានលទ្ធភាពទទួលបានធនធានអ្វីខ្លះ? តើវាផ្ដល់នូវសុវត្ថិភាពដែរឬទេ? តើកសិករមានសិទ្ធិក្នុងការប្រើប្រាស់កម្លាំងពលកម្មជាថ្នូរនឹងការប្រើប្រាស់ដីឬទេ? តើមានលក្ខខណ្ឌអ្វីខ្លះក្នុងការទទួលបានធនធានទាំងអស់នោះ (ទឹក ដើមឈើដែលមានលើដីស្រាប់)?

❖ ឧបករណ៍ និងសម្ភារៈ

ឧបករណ៍ និងសម្ភារៈដែលត្រូវការប្រើប្រាស់ក្នុងសកម្មភាពនានានៅក្នុងប្រព័ន្ធកសិកម្ម ដែលត្រូវលើកមកសិក្សារួមមានដូចជា៖

- ឧបករណ៍ប្រើដោយដៃ (ចកគ្រប់ប្រភេទ ពូថៅ កាំបិត រនាស់ ខ្វារ -ល-)
- សម្ភារៈសម្រាប់ដឹកជញ្ជូន (សូម្បីតែ កញ្ច្រែង ល្អី កន្ត្រក ដែលប្រើប្រាស់បានតែមួយឆ្នាំខូច) ការដឹកជញ្ជូនដោយសត្វ ឬដោយម៉ូតូ
- សម្ភារៈសម្រាប់សម្ងួត កែច្នៃ និងស្ដុកទុក កសិផលដែលប្រមូលផលបាន (ស្បៃហាល ម៉ាស៊ីនបោក ម៉ាស៊ីនសម្ងួត បេច្រក ជង្រុក -ល-)
- កង់ និងម៉ូតូ

អ្វីដែលយើងត្រូវការគឺ ឧបករណ៍ និងសម្ភារៈដែលចាំបាច់សម្រាប់ការធ្វើអោយប្រព័ន្ធកសិកម្មអាចដំណើរការទៅបាន។ វារួមមានទាំង ឧបករណ៍ធ្វើពីអ្វី មានចំនួនប៉ុន្មាន ពិពណ៌នាពីគុណភាព និងកម្លាំងរបស់វា និងស្វែងយល់នៅក្នុងលក្ខខណ្ឌណាកសិករអាចប្រើប្រាស់វាបាន ដោយចំណាយថវិកាអស់ប៉ុន្មាន? (Didier, ២០១១)។

# ជំពូក ៣
# វិធីសាស្ត្រសិក្សាស្រាវជ្រាវ

ជំពូក ៣
វិធីសាស្ត្រសិក្សាស្រាវជ្រាវ

## ៣.១ ការជ្រើសរើសតំបន់សិក្សា

អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ (MODE) ក្រោមការសហការណ៍ជាមួយ ឡូវ៉ាន សហប្រតិបត្តិការណ៍ (LOUVAIN COOPERATION) បានជួយលើកកម្ពស់ជីវភាពប្រជាជនខេត្តកំពង់ធំ តាមរយៈការលើកកម្ពស់ការដាំបន្លែ និងចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ។ ក្រុមគោលដៅរបស់ ម៉ូដ ស្ថិតនៅពីរស្រុកគឺស្រុកសន្ទុក និងស្រុកបារាយណ៍។ ដោយមានការគាំទ្រជាថវិការក្នុងការសិក្សាស្រាវជ្រាវទៅលើការសេដ្ឋកិច្ចគ្រួសាររបស់ក្រុមគោលដៅនៃគម្រោង ពី Louvain Cooperation ស្របនឹងគោលបំណងនៃការសិក្សាពីប្រសិទ្ធិភាពសេដ្ឋកិច្ចនៃកម្លាំងពលកម្មស្ត្រី ឃុំមួយក្នុងចំណោយឃុំគោលដៅផ្សេងទៀតរបស់គម្រោង ត្រូវបានជ្រើសរើសសម្រាប់ការសិក្សាមួយនេះ គឺឃុំត្នោតជុំ ស្រុកបារាយណ៍។ អាស្រ័យហេតុនេះទើបប្រធានបទស្តីពី “ ការសិក្សាពីតួនាទីយេនឌ័រក្នុងប្រព័ន្ធកសិកម្ម នៅឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ” ត្រូវបានលើកយកមកសិក្សា។

## ៣.២ ការជ្រើសរើសសំណាក

សំណាកចំនួន ៦៣ គ្រួសារ ត្រូវបានជ្រើសរើសដោយហេតុផលពេលវេលានៃការចុះសម្ភាសន៍មានរយៈពេលខ្លី ហើយបញ្ជីសំណួរនីមួយៗត្រូវចំណាយពេលវេលាយូរក្នុងការសម្ភាសន៍។ ។ យ៉ាងណាមិញ សំណាកយ៉ាងតិចបំផុត ៥គ្រួសារ ត្រូវបានជ្រើសរើសក្នុងប្រព័ន្ធនីមួយៗ ដោយអាស្រ័យនឹងស្ថានភាពជាក់ស្តែងនៃតំបន់ក្សេត្រ បរិស្ថាននៃតំបន់សិក្សា។

ខាងក្រោមនេះជាតារាងបង្ហាញចំនួនសំណាក ដែលបានជ្រើសរើសពីភូមិទាំងពីរនៃឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ។

តារាងទី ៣.១ ៖ ការជ្រើសរើសសំណាកក្នុងភូមិ

| ស្រុក | ឃុំ | ឈ្មោះភូមិ | ចំនួនគ្រួសារសរុបក្នុងភូមិ $N_i$ | សំណាកតាមភូមិមួយៗ $n_i$ | | សំណាកសរុប | ភាគរយ (%) |
|---|---|---|---|---|---|---|---|
| | | | | សំណាកបុរស | សំណាកស្ត្រី | | |
| បារាយណ៍ | ត្នោតជុំ | ថ្មី | ១៥៤ | ១៥ | ២០ | ៣៥ | ៥៥,៥៥ |
| | | ព្រែកក្រោល | ១៤៥ | ១៦ | ១២ | ២៨ | ៤៤,៤៥ |
| | សរុប | | ២៩៩ | ៣១ | ៣២ | ៦៣ | ១០០ |

ប្រភព៖ លទ្ធផលនៃការជ្រើសរើសសំណាក

៣.៣ វិធីសាស្ត្រប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យ មានសារៈប្រយោជន៍ណាស់ សម្រាប់ធ្វើការឆ្លុះបញ្ចាំង និងវិភាគឲ្យបានល្អិតល្អន់ ក្នុងការឆ្លើយតបទៅនឹងគោលបំណងដែលបានគ្រោងទុក។ ដោយការចុះប្រមូលទិន្នន័យក្នុងការសិក្សានេះ នឹងធ្វើឡើងតាមរយៈ ទិន្នន័យដែលមានស្រាប់ ( Secondary data ) និងទិន្នន័យចុះអង្កេត (Primary Data) ហើយធ្វើការសម្ភាសន៍ផ្ទាល់ជាមួយប្រជាពលរដ្ឋក្នុងតំបន់គោលដៅ ដែលបានជ្រើសរើសដោយប្រើបញ្ជីសំណួរ។

៣.៣.១ ទិន្នន័យមានស្រាប់ (Secondary Data)

ទិន្នន័យមានស្រាប់ គឺជាទិន្នន័យដែលបានមកពីឯកសារផ្សេងៗដែលគេបានចងក្រងរួច។ ហេតុនេះ ដើម្បី ប្រមូលបានទិន្នន័យប្រភេទនេះ ចាំបាច់ត្រូវធ្វើការស្រាវជ្រាវ និងសំយោគឯកសារពាក់ព័ន្ធនានាដែល ពាក់ព័ន្ធទៅនិង ប្រធានបទដូចជា៖

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បណ្ណាល័យសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- មន្ទីកសិកម្មខេត្តកំពង់ធំ
- របាយការណ៍ស្តីពីស្ថានភាព ភូមិ ឃុំ ដែលចុះសិក្សាស្រាវជ្រាវ
- សាលាស្រុក
- សាលាឃុំ
- ប្រព័ន្ធអ៊ីនធឺណេត
- អង្គការនានា

៣.៣.២ ទិន្នន័យបឋម (Primary Data)

ទិន្នន័យបឋម គឺជាទិន្នន័យ ដែលមានសារៈប្រយោជន៍បំផុតសម្រាប់គោលបំណងរួម ដែលអាចទទួលបានតាមរយៈការសម្ភាសន៍ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនៅក្នុងតំបន់គោលដៅ។

**ក. ការសម្ភាសន៍ដោយប្រើប្រាស់បញ្ជីសំណួរ**

ដើម្បីទទួលបានទិន្នន័យ បញ្ជីសំណួរត្រូវបានប្រើប្រាស់សម្រាប់ការសម្ភាសន៍ប្រជាជនក្នុងតំបន់សិក្សា។ ក្នុងនោះ ការសម្ភាសន៍ក្នុងគ្រួសារនីមួយៗចាំបាច់ត្រូវមានវត្តមានស្ត្រីចូលរួម ដើម្បីអាចទទួលបានព័ត៌មាន និងទិន្នន័យដែលស្របទៅនឹងប្រធានបទដែលសិក្សាពី "តួនាទីយេនឌ័រក្នុងប្រព័ន្ធកសិកម្ម នៅឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ"។

**ខ. ការពិភាក្សាជាក្រុម**

ការពិភាក្សាជាក្រុមត្រូវធ្វើឡើងដោយមានការចូលរួមពីស្ត្រីប្រមាណជា ១០នាក់ ដែលមកពីភូមិទាំងពីនៃសំណាក ដើម្បីពិភាក្សាពី ចំនុចខ្លាំង ចំនុចខ្សោយ ឱកាស និងកត្តារាំងដែលស្ត្រីជួបប្រទះក្នុងការងារកសិកម្ម។

៣.៤ វិធីសាស្ត្រវិភាគទិន្នន័យ

ទិន្នន័យដែលបានកមពីការអង្កេត និងសម្ភាសន៍ជាមួយកសិករក្នុងតំបន់គោលដៅ នឹងត្រូវបានរៀបចំទិន្នន័យនេះទៅតាមប្រភេទ និងចំណាត់ថ្នាក់តារាង Spread Sheet រួចធ្វើការបញ្ចូលក្នុងកម្មវិធី Ms. Excel ហើយធ្វើការវិភាគទៅតាមចំណុចនីមួយៗ ដែលនឹងបង្ហាញជា មធ្យម ភាគរយ តារាង ក្រាហ្វិច ដ្យាក្រាម។ ដើម្បីធ្វើចំណាត់ថ្នាក់កសិករទៅតាមប្រព័ន្ធផលិតកម្មនីមួយៗ ការសិក្សាបានប្រើប្រាស់រូបមន្ត Concatenate រួច Sort សំណាកទាំងអស់ដើម្បីអោយក្រុមកសិករដែលអនុវត្តដូចគ្នារត់ចូលតាមក្រុមតែមួយ។ លើសពីនេះ ការសិក្សាបានប្រើប្រាស SPSS ដើម្បីវិភាគដោយប្រាស់ប្រើប្រាស់ឧបករណ៍ចំនួនពីរគឺ Frequency និង Crosstab។ រួចបញ្ចូលក្នុងកម្មវិធី Ms. Word ដើម្បីបកស្រាយ តាមចំណុចនីមួយៗ និងចងក្រងជាសារណា។ ការវិភាគទិន្នន័យមានពីរបែបគឺ៖

៣.៤.១ ការវិភាគទិន្នន័យបែបគុណភាព

គឺជាទិន្នន័យ ដែលឆ្លុះបញ្ចាំងពីទស្សនៈយល់ឃើញ គំនិតរបស់អ្នកផ្តល់កិច្ចសម្ភាសន៍។ គ្រប់ទិន្នន័យទាំងអស់ដែលទទួលបាន ត្រូវគេយកមកធ្វើការសំយោគយកគំនិតរួម ដើម្បីបង្ហាញដល់សាធារណជនឲ្យយល់ និងស្គាល់ពីស្ថានភាពពិតក្នុងតំបន់សិក្សា។ ទិន្នន័យទាំងអស់នេះទទួលបានតាមរយៈការវិភាគ SWOT ជាដើម។

៣.៤.២ ការវិភាគទិន្នន័យបែបបរិមាណ

គឺជាទិន្នន័យដែលទាក់ទងនឹងតួរលេខ ដូចជាកម្លាំងពលកម្មក្នុងគ្រួសារ កម្លាំងពលកកម្មស្រ្តី ចំណូលក្នុងកសិដ្ឋាន ចំណាយក្នុងកសិដ្ឋាន ប្រសិទ្ធិភាពសេដ្ឋកិច្ច។

# ជំពូក ៤
# លទ្ធផល និងការពិភាក្សា

ជំពូក ៤
លទ្ធផល និងការពិភាក្សា

## ៤១. ស្ថានភាពទូទៅនៃតំបន់សិក្សា

### ៤.១.១ ស្ថានភាពទូទៅ និងទីតាំងភូមិសាស្ត្រខេត្តកំពង់ធំ

ខេត្តកំពង់ធំ គឺជាខេត្តមួយដែលស្ថិតនៅចំផ្ទៃកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា និងមានចំងាយផ្លូវ ១៦៨ គីឡូម៉ែត្រពីទីក្រុងភ្នំពេញ តាមបណ្តោយផ្លូវជាតិលេខ៦។ ខេត្តនេះមានព្រំប្រទល់៖

- ខាងត្បូង ជាប់ខេត្តកំពង់ចាម និងខេត្តកំពង់ឆ្នាំង
- ខាងជើង ជាប់ខេត្តព្រះវិហារ ភាគឦសាន ជាប់ខេត្តស្ទឹងត្រែង និងភាគពាយ័ព្យ ជាប់ខេត្តសៀមរាប
- ខាងលិច ជាប់បឹងទន្លេសាប
- ខាងកើត ជាប់ខេត្តក្រចេះ។

ខេត្តកំពង់ធំជាខេត្តដែលមានផ្ទៃដីធំទី២នៅក្នុងប្រទេសកម្ពុជាស្មើនឹង ១៣ ៨១៤ គីឡូម៉ែត្រការ៉េ ដែលមាន ៨ ស្រុក-ក្រុង, ៨១ ឃុំ-សង្កាត់ និង ៧៣៤ ភូមិ ដែលមានចំនួនប្រជាជនសរុប ៧៦៣.៩៤៣ នាក់ ស្រីចំនួន ៣៩១.៩៣០ នាក់។ ខេត្តកំពង់ធំ មានផ្ទៃដីកសិកម្មចំនួន ២៤៩,៣០០ ហិកតា ដែលក្នុងនោះផ្ទៃដីស្រូវវស្សាមានចំនួន ២១៣.៤២៦ហិកតា និងស្រូវប្រាំង ៤៣.៩៩៨ហិកតា។

ស្រូវទាំងពីររដូវនេះគេប៉ាន់ស្មានថា ស្រូវវស្សាមានចំនួន ៥២៩.២៩៦តោន ឯស្រូវប្រាំងមានចំនួន ១៩៣.៩៣២តោន (របាយការណ៍មន្ទីរកសិកម្មខេត្តកំពង់ធំ, ២០១៥)។

៤.១.២ ស្ថានភាពទូទៅស្រុកបារាយណ៍

ស្រុកបារាយណ៍ គឺជាស្រុកមួយក្នុងចំណោមស្រុក-ក្រុងទាំង៨ របស់ខេត្តកំពង់ធំ។ ហើយស្រុកនេះគឺជាស្រុកមួយដែលមានការរីកចម្រើនគួរសមបើប្រៀបធៀបទៅនឹងស្រុកនានា។ ការរីកចម្រើននេះបណ្តាលមកពីស្រុកនេះ ឆ្លងកាត់ដោយផ្លូវជាតិលេខ៦ ដែលជាផ្លូវភ្ជៀវទេសចរណ៍ធ្វើដំណើរទៅកាន់ខេត្តសៀមរាប។ មួយវិញទៀត គឺស្រុកនេះមានស្ទឹងជីនិតហូរកាត់ ដែលស្ទឹងនេះអំណោយផលដល់ការធ្វើកសិកម្ម និងការនេសាទ។

ក្នុងស្រុកបារាយណ៍មានឃុំចំនួន១៨ឃុំ និងមានប្រជាជន ៤១.៦៤៦ គ្រួសារស្មើនឹង ២០១.០៥៩នាក់ ក្នុងនោះមានស្ត្រីចំនួន ១០៣.០៤០នាក់។ ប្រជាជនមានប្រមាណ ៧៦,៩ ភាគរយមានមុខរបរជាកសិករធ្វើស្រែចំការ
ក្រៅពីនេះប្រកបរបរបន្ទាប់បន្សំផ្សេងទៀតដូចជាដាំដំណាំហូបផ្លែ ចិញ្ចឹមសត្វ ជាងចម្លាក់ ជាងឈើ និងលក់ដូរ
បន្តិចបន្តួច។

ស្រុកបារាយណ៍មានព្រំប្រទល់ដូចខាងក្រោម៖

- ខាងត្បូង ទល់នឹង ស្រុកព្រៃឈរ ស្រុកជើងព្រៃ និងបាធាយ (ខេត្តកំពង់ចាម)
- ខាងជើង ទល់នឹង ស្រុកសន្ទុក (ខេត្តកំពង់ធំ)
- ខាងលិច ទល់នឹង ស្រុកជលគិរី និងស្រុកកំពង់លែង (ខេត្ត កំពង់ឆ្នាំង)
- ខាងកើត ទល់នឹង ស្រុកស្ទឹងត្រង់ និងស្រុកចម្ការលើ (ខេត្តកំពង់ចាម)

៤.១.៣ ស្ថានភាពទូទៅឃុំត្នោតជុំ

**ក. ទីតាំងភូមិសាស្ត្រនៃឃុំត្នោតជុំ**

ឃុំត្នោតជុំ គឺជាឃុំនៅភាគខាងជើងនៃទីរួមស្រុកបារាយណ៍ ដែលមានចំងាយ ១៨,៦គីឡូម៉ែត្រពីទីរួមស្រុកបារាយណ៍ ហើយមានចំងាយប្រហែល ៤០ គីឡូម៉ែត្រពីទីរួមខេត្ត។ ឃុំត្នោតជុំមានព្រំប្រទល់៖

- ខាងត្បូង ទល់នឹង ឃុំចុងដូង ស្រុកបារាយណ៍
- ខាងជើង ទល់នឹង ឃុំញ្ញោ ឃុំតាំងត្រសាំង និងឃុំប្រាសាទ ស្រុកសន្ទុក
- ខាងលិច ទល់នឹង ឃុំកំពង់ថ្មា ស្រុកសន្ទុក
- ខាងកើត ទល់នឹង ឃុំញ្ញោ ស្រុកសន្ទុក

ឃុំត្នោតជុំចែកចេញជា 9 ភូមិដែលមានប្រជាជនសរុប ៨.៩៥៥នាក់ ស្រី ៤.៥៥៨នាក់។

**ខ. ស្ថានភាពឃុំត្នោតជុំនាពេលបច្ចុប្បន្នលើវិស័យកសិកម្ម**

ឃុំនេះមានផ្ទៃដីកសិកម្មសរុបឆ្នាំ ២០១៤ គឺ ៣.៧៦៥ ហិកតា ដោយផ្ទៃដីស្រែប្រាំងសរុប ២៧០ ហិកតា ផ្ទៃដីស្រូវប្រាំងដាំដុះជាក់ស្តែងមាន ២៧០ ហិកតា ផ្ទៃដីស្រែវស្សាសរុប ៣.៤៩៥ ហិកតា ផ្ទៃដីស្រូវវស្សាដាំដុះជាក់ ស្តែងមាន ២.៩៣២ ហិកតា។ ស្រូវប្រាំងទទួលបាលទិន្នផលជាមធ្យម ៤ តោនក្នុងមួយហិកតា និងស្រូវវស្សាទទួលបានទិន្នផលជាមធ្យម ២ តោនក្នុងមួយហិកតា។ ជាក់ស្តែង យើងឃើញថាទិន្នផលស្រូវប្រាំងខ្ពស់ជាងទិន្នផល ស្រូវវស្សា ប៉ុន្តែផ្ទៃដីដាំដុះស្រូវប្រាំងបែរជាមានចំនួនតិចជាងស្រូវវស្សាទៅវិញ។ មូលហេតុ គឺបណ្តាលមកពីប្រព័ន្ធស្រោចស្រពក្នុងឃុំនៅរដូវប្រាំងមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ដីស្រែដែលទទួលបានពីប្រព័ន្ធស្រោចស្រព មានចំនួនត្រឹមតែ ៦០ ហិកតាប៉ុណ្ណោះ ដែលស្មើនឹង ១,៦ ភាគរយនៃផ្ទៃដីស្រែសរុប។ ហេតុនេះហើយ ប្រជាជនក្នុងឃុំ ភាគច្រើនអាចធ្វើស្រែបានតែម្តងប៉ុណ្ណោះក្នុងមួយឆ្នាំ គឺប្រភេទពូជស្រូវប្រពៃណី ដោយពឹងផ្អែកលើទឹកភ្លៀង។

បច្ចុប្បន្ននេះ ដោយទិន្នផលស្រូវទាប កសិករមួយចំនួនបានទុកស្រែគាត់អោយនៅទំនេរចោល ជាពិសេសស្រែក្រោមដែលស្ថិតនៅឆ្ងាយពីភូមិ។ ដីស្រែដែលទំនេរនោះ សព្វថ្ងៃត្រូវបានគេយកធ្វើជាដីសម្រាប់ឃ្វាលសត្វ

ពាហនៈនានា ដូចជាគោក្របី ជាដើម។ ផ្ទុយទៅវិញ កសិករបានបង្កើនផលិតភាពដីថ្មី ដោយការដាំដុះដំណាំដំឡូងមីនៅលើដីស្រែលើ ដែលនៅជិតភូមិ។ ចំណែក ការធ្វើកសិកម្ម មានលក្ខណៈទំនើបកម្មជាមុន ដោយយើងសង្កេតមានការប្រើប្រាស់គ្រឿងយន្ត ដូចជា ត្រាក់ទ័រ គោយន្ត ម៉ាស៊ីនបោក ម៉ាស៊ីនច្រូត ម៉ាស៊ីនកិនស្រូវ ម៉ាស៊ីនកាប់ដំឡូង ជំនួសកម្លាំងគោក្របី និងកម្លាំងមនុស្ស។ ទិន្នន័យនៅក្នុងឯកសារព័ត៌មាន ស្ដីពីស្ថានភាពឃុំ ត្នោតជុំ ឆ្នាំ២០១៥ បានអោយដឹងថា ក្នុងឃុំ មានត្រាក់ទ័រសម្រាប់ភ្ជួរដីចំនួន ៩គ្រឿង គោយន្តសម្រាប់ភ្ជួរដីចំនួន ១៨៩ គ្រឿង ម៉ាស៊ីនច្រូតស្រូវចំនួន ២ គ្រឿង និងម៉ាស៊ីនសម្រាប់បោកស្រូវចំនួន ៣៦ គ្រឿង (សាលាឃុំ, ២០១៥)។

### គ. មុខរបរប្រជាជន

ក្នុងចំណោមប្រជាជនសរុប ប្រជាជនដែលប្រកបមុខរបរធ្វើកសិកម្មមានចំនួន ៨១,៣ ភាគរយ និងប្រជាជនដែលប្រកបមុខរបរចំបងក្រៅពីវិស័យកសិកម្ម មានចំនួន ១៨,៧ ភាគរយ។ ប្រជាជនមានមុខរបរចំបង គឺលើ វិស័យកសិកម្មមានដូចជា ធ្វើស្រែ ដាំដំណាំរយៈពេលវែង ចិញ្ចឹមសត្វ និងនេសាទ។ ក្រៅពីនេះ នៅមានមុខរបរផ្សេងទៀត ដូចជា អាជីវកម្ម ជាងផ្ទះ ជាងកាត់ដេរ ឡើងត្នោត ដេរកន្ទេលរំចេក ដេរស្លឹកត្នោត ក្រងអង្រឹង និងលក់កម្លាំងពលកម្មជាដើម។ តាមរយៈទិន្នន័យពីថ្នាក់ឃុំ ឆ្នាំ ២០១៥ អ្នកប្រកបមុខរបរសិប្បកម្ម និងអាជីវកម្មដោយគ្រឿងយន្តមាន ម៉ាស៊ីនកិនស្រូវខ្នាតមធ្យមនិងធំ ចំនួន ១០ កន្លែង កន្លែងជួសជុលកង់ម៉ូតូចំនួន ២ កន្លែង។ ចំណែក អ្នកប្រកបមុខរបរផ្ដល់សេវាកម្ម មាន អ្នកលក់គ្រឿងបរិភោគ និងទំនិញប្រើប្រាស់ ៥ កន្លែង អ្នកលក់ខោអាវស្បែកជើង និងគ្រឿងក្រអូប ២ កន្លែង អ្នកលក់គ្រឿងអលង្ការ ២ កន្លែង អ្នកផ្ដល់សេវាកម្មខ្នាតតូចដូចជា ជាងកាត់សក់ ១ កន្លែង និងអ្នកធ្វើអាជីវកម្មខ្នាតតូចដូចជា លក់បាយ គុយទាវ ២ កន្លែង (សាលាឃុំ, ២០១៥)។

### ឃ. ចំណាកស្រុក

ចំណាកស្រុក មានច្រើនប្រភេទណាស់ ហើយគោលបំណងនៃការចំណាកស្រុករបស់បុគ្គលម្នាក់ៗគឺខុសគ្នា។ ប្រជាជនក្នុងឃុំត្នោតជុំភាគច្រើន ធ្វើចំណាកស្រុកដើម្បីស្វែងរកការងារធ្វើ។

ចំណាកស្រុកទៅភ្នំពេញគឺជាប្រភេទចំណាកស្រុកពីទីជនបទទៅទីក្រុង (Rural-urban migration) ដោយ យុវជនច្រើនទៅធ្វើជាកម្មករសំណង់ និង យុវនារីច្រើនទៅធ្វើជាកម្មការនីរោងចក្រ។ យុវជន ធ្វើចំណាកស្រុកភាគច្រើនជាចំណាកស្រុកតាមរដូវកាល (ក្រោយពីរួចដៃពីការធ្វើស្រែចម្ការ) ដើម្បីរកប្រាក់ចំណូលបន្ថែមជួយគ្រួសារ។ ចំណែក យុវនារី គឺនៅធ្វើការនៅភ្នំពេញជាប់ពេញមួយឆ្នាំ ដោយគ្រាន់តែផ្ញើរប្រាក់ប្រចាំខែមកផ្គត់ផ្គង់គ្រួសារ ហើយ ៤ ទៅ ៥ ខែ ទើបមកលេងផ្ទះម្ដង ។ ក្រៅពី ចំណាកស្រុកទៅកាន់រាជធានីភ្នំពេញ ក៏មានការចំណាកស្រុកទៅខេត្តនានាដែរ ដូចជា ខេត្តកំពង់ចាម ខេត្តសៀមរាប និងទៅទីរួមខេត្តកំពង់ធំផ្ទាល់ ក្នុងគោលបំណងស្វែងរកការងារដូចគ្នា។ យ៉ាងណាមិញ ក៏មានការធ្វើចំណាកស្រុកក្នុងតំបន់(Internal migration)ផងដែរ ពិព្រោះនៅក្នុងឃុំ ពុំសូវមានសកម្មភាពសេដ្ឋកិច្ចច្រើនសម្រាប់អោយប្រជាជនប្រកបរបរចិញ្ចឹមជីវិត។

ប្រជាជនមួយចំនួនធំ បានធ្វើបន្លាស់ទីជាប្រចាំថ្ងៃ (Daily Commuters) ទៅឃុំ ឬស្រុកដែលនៅជិតៗ ដើម្បីស្វែងរកការងារធ្វើ និងត្រលប់មកផ្ទះវិញជារៀងរាល់ថ្ងៃ។ នៅក្នុងឃុំ ស្រ្តីមួយចំនួន ដឹកត្រី បន្លែ សត្វ ឬនំ បង្អែមនានា តាមម៉ូតូ ឬកង់ ដើម្បីទៅលក់នៅឃុំ និងស្រុកដទៃទៀត។ ចំណែកបុរស ស្វែងរក

តារាងទី ៤.១ តារាងចំនួនជនចំណាកស្រុកឃុំត្នោតជុំ

| ល.រ | ភូមិ | ក្នុងប្រទេស | ក្រៅប្រទេស | សរុប |
|---|---|---|---|---|
| ១ | ត្នោតជុំទី១ | ៣៨ | ១១ | ៤៩ |
| ២ | ត្នោតជុំទី២ | ១៧ | ៣០ | ៤៧ |
| ៣ | ត្នោតជុំទី៣ | ៣០ | ១៨ | ៤៨ |
| ៤ | ត្នោតជុំទី៤ | ១៤ | ០ | ១៤ |
| ៥ | ត្នោ | ១៤២ | ១៨ | ១៦០ |

| | | | | |
|---|---|---|---|---|
| ៦ | ព្រែកក្រោល | - | - | - |
| ៧ | បន្ទាយចាស់ | ១៣៥ | ២៦ | ១៦១ |
| ៨ | ថ្មី | ១០៩ | ១៩ | ១២៨ |
| ៩ | កងមាស | ២៥៨ | ៤ | ២៦២ |
| ១០ | សរុប | ៧៤៣ | ១២៦ | ៨៦៩ |

ប្រភពៈទិន្នន័យស្ថានភាពឃុំឆ្នាំ២០១៥

ការងារសំណង់ធ្វើ ភាគច្រើននៅឯកំពង់ថ្ម។ ដោយឃុំត្នោតជុំស្ថិតនៅជិតរមនីយដ្ឋាន បឹងសម្រឹត (ឃុំចុងដូង) ប្រជាជនមួយចំនួន អាចទទួលបានការងារធ្វើជា អ្នកអនាម័យ អ្នកថែសួន អ្នកលក់សំបុត្រចូលលេងកម្សាន្ត និងកម្មករសំណង់ ហើយអាចត្រលប់មកផ្ទះវិញរៀងរាល់ល្ងាច។ ក្រៅពីការធ្វើចំណាកស្រុកក្នុងប្រទេសក៏មានការធ្វើចំណាកស្រុកទៅក្រៅប្រទេសផងដែរ មានដូចជា ប្រទេសថៃ ប្រទេសកូរ៉េ ជាដើម។ តារាងខាងលើ ជាតួលេខបង្ហាញពីចំនួនជនចំណាកស្រុកនៅក្នុងប្រទេស និងក្រៅប្រទេសរបស់ឃុំត្នោតជុំ។

**ង. ហេដ្ឋារចនាសម្ព័ន្ធសង្គមក្នុងឃុំត្នោតជុំ**

នៅក្នុងឃុំ មានផ្លូវសរុប ២១.៣០០ ម៉ែត្រ ក្នុងនោះ ផ្លូវក្នុងឃុំក្រាលដោយគ្រួសសក្រហម មានប្រវែងសរុប ១២.០០០ ម៉ែត្រ និងផ្លូវស្រុកឆ្លងកាត់ឃុំ មានប្រវែង ៩.៣០០ ម៉ែត្រ។

ប្រភេទសាសារៀននៅក្នុងខេត្តមានចំនួន ៧ កន្លែងដូចជាៈ

- មតេយ្យសហគមន៍ចំនួន ១ កន្លែងត្រូវជា ៥ ថ្នាក់
- មតេយ្យរដ្ឋចំនួន ១ កន្លែងត្រូវជា ៤ បន្ទប់
- បឋមសិក្សារដ្ឋចំនួន ៤ កន្លែងត្រូវជា ២៧ បន្ទប់
- អនុវិទ្យាល័យរដ្ឋចំនួន ១ ត្រូវជា ៤ បន្ទប់

ចំនួនគ្រូដែលបង្រៀនផ្ទាល់នៅតាមសាលារៀនខាងលើនេះ ដោយមិនរាប់បញ្ចូលចំនួនបុគ្គលិកធ្វើការងារក្នុងការិយាល័យមានៈ

- ចំនួនគ្រូបង្រៀនផ្ទាល់នៅមតេយ្យសហគមន៍ ៥ នាក់
- ចំនួនគ្រូបង្រៀនផ្ទាល់នៅមតេយ្យរដ្ឋ ៤ នាក់
- ចំនួនគ្រូបង្រៀនផ្ទាល់នៅបឋមសិក្សារដ្ឋ ២២ នាក់
- ចំនួនគ្រូបង្រៀនផ្ទាល់នៅអនុវិទ្យាល័យរដ្ឋ ១០ នាក់

ប្រភពៈ ទិន្នន័យស្ថានភាពឃុំឆ្នាំ២០១៥

៤.១.៤ ស្ថានភាពទូទៅរបស់កសិករ

**ក. ស្ថានភាពយេនឌ័ររបស់មេគ្រួសារ**

ស្ថានភាពយេនឌ័ររបស់មេគ្រួសារពិតជាមានសារៈសំខាន់ក្នុងការរកប្រាក់ចំណូល និងបង្កើនប្រាក់ចំណូល ក្នុងគ្រួសារ។ តាមការសិក្សាបានបង្ហាញថា មានស្ត្រីដែលជាមេគ្រួសារចំនួន ១២ គ្រួសារ ស្មើនឹង ១៩ ភាគរយ ហើយមានបុរសជាមេគ្រួសារចំនួន ៥១គ្រួសារ ស្មើនឹង ៨១ ភាគរយ ។ បើតាមតួលេខ យើងសង្កេតឃើញថា មេគ្រួសារដែលជាស្ត្រីមានចំនួនតិចជាង មេគ្រួសារដែលជាបុរស។ នេះបង្ហាញថា បុរសនូវតែមានសមត្ថភាព អំណាចជាអ្នកគ្រប់គ្រងបែងចែកធនធាន ធ្វើការសម្រេចចិត្តនានា និងមានទំនួលខុសត្រូវខ្ពស់ចំពោះគ្រួសារច្រើនជាងស្ត្រី។



ដ្យាក្រាមទី ៤.១ ៖ ភាគរយនៃស្ថានភាពយេនឌ័រ របស់មេគ្រួសារ

**ខ. ស្ថានភាពគ្រួសាររបស់មេគ្រួសារ**

ការសិក្សានេះមានគោលបំណងចង់ដឹង ពីកម្លាំងពលកម្ម ក៏ដូចជាការគ្រប់គ្រងការងារអាជីវកម្ម កសិកម្ម និងមុខរបរផ្សេងៗទៀត។ ក្នុងនោះយើងសង្កេតឃើញថាស្ត្រីនៅតែជាកម្លាំងយ៉ាងសំខាន់នៅក្នុងគ្រួសារដែលមិនអាចខ្វះបានហើយចំពោះមេគ្រួសារដែលមានភេទជាស្ត្រីគឺជាអ្នករកប្រាក់ចំណូលផង និងគ្រប់គ្រងគ្រួសារផង។ ជាក់ស្តែង មេគ្រួសារដែលជាស្ត្រីទាំង ១២ គ្រួសារនោះ សុទ្ធតែមានស្ថានភាពគ្រួសារជាស្ត្រីមេម៉ាយ។ នេះបង្ហាញថា ស្ត្រីដែលជាមេគ្រួសារត្រូវមានទំនួលខុសត្រូវខ្ពស់ក្នុងគ្រួសារ ដោយគាត់ត្រូវមានតួនាទីច្រើន ជាអ្នករកប្រាក់ផ្គត់ផ្គង់គ្រួសារផង និងជាមើលថែក្នុងគ្រួសារផង។

តារាងទី ៤.២៖ ស្ថានភាពមេគ្រួសារក្នុងតំបន់សិក្សា

| ល.រ | ស្ថានភាពរបស់មេគ្រួសារ | បុរស | | ស្ត្រី | |
|---|---|---|---|---|---|
| | | ចំនួន(នាក់) | ភាគរយ | ចំនួន(នាក់) | ភាគរយ |
| ១ | នៅលីវ | - | - | - | - |
| ២ | រៀបការ | ៥១ | ៨១ | - | - |
| ៣ | លែងលះ | - | - | - | - |
| ៤ | មេម៉ាយ/ពោះម៉ាយ | - | - | ១២ | ១៩ |
| ៥ | សរុប | ៥១ | ៨១ | ១២ | ១៩ |

ប្រភព៖ ទិន្នន័យអង្កេត

**គ. កម្រិតវប្បធម៌របស់មេគ្រួសារ**

តាមរយ:តារាងទី ៤.៣ បង្ហាញថា មេគ្រួសារដែលជាបុរស មានកម្រិតវប្បធម៌ខ្ពស់បំផុតត្រឹមថ្នាក់វិទ្យាល័យ។ ចំណែក មេគ្រួសារដែលជាស្ត្រីវិញមានកម្រិតវប្បធម៌ខ្ពស់បំផុតត្រឹមតែថ្នាក់បឋមសិក្សាប៉ុណ្ណោះ។ ភាគច្រើនស្ត្រីមិនបានចូលរៀន គឺមាន ៧នាក់ នៃ១២នាក់ និង ៥នាក់ទៀត រៀនបានត្រឹមថ្នាក់បឋម។ បើទោះបីជា មេគ្រួសារដែលជាបុរសមានការអប់រំខ្ពស់ជាងស្ត្រីក៏ពិតមែន តែមានមេគ្រួសារបុរសតែ ៨ នាក់ស្មើនឹង ១២,៧ ភាគរយប៉ុណ្ណោះដែលរៀនបានថ្នាក់អនុវិទ្យាល័យ និង ៥ នាក់ ស្មើនឹង ៧,៩ ភាគរយប៉ុណ្ណោះដែលរៀនបានត្រឹមថ្នាក់ វិទ្យាល័យ។ មេគ្រួសារបុរសដែលរៀនបានត្រឹមថ្នាក់បឋមសិក្សាមានរហូតដល់ទៅ ៤៩,២ ភាគរយ។ មូលហេតុដែលបណ្តាលអោយមេគ្រួសារទទួលបានការអប់រំ ពិព្រោះនៅក្នុងឃុំពុំមានសាលារៀនគ្រប់គ្រាន់

ដូចបានបង្ហាញក្នុងតារាងទី ៤.១។ ក្នុងតំបន់មានត្រឹមថ្នាក់អនុវិទ្យាល័យប៉ុណ្ណោះ។ បើសិស្សានុសិស្សចង់បន្តទៅថ្នាក់វិទ្យាល័យ ត្រូវទៅបន្ត នៅតាំងក្រសាំងដែលស្ថិតនៅឆ្ងាយពីភូមិ។ វាជាឧបសគ្គមួយក្នុងការបន្តការសិក្សា ជាពិសេសស្ត្រី ដោយក្លាយប៉ះពាល់ដល់សុវត្ថិភាពផ្ទាល់ខ្លួន។ ម៉្យាងវិញទៀតកត្តាទំនៀមទំលាប់ប្រពៃណី ក៏ជាកត្តារាំងស្ទះមិនអោយស្ត្រីបន្តការសិក្សាបានខ្ពស់។ ដូចដែលបានលឺចាស់ៗពីមុននិយាយថា ក្មេងស្រីអោយរៀនច្រើនខ្លាចចេះសរសេរសំបុត្រស្នេហា ឬស្រីបង្វិលចង្ក្រានមិនជុំ។ កត្តាមួយផ្សេងទៀត គឺដោយសារកម្រិតជីវភាពក្រីក្រ ធ្វើអោយទាំងកុមារាកុមារី បោះបង់ចោលការសិក្សាទាំងកណ្តាលទី ដើម្បីជួយការងារក្នុងកសិដ្ឋាន ឬរកការងារផ្សេងទៀតធ្វើ។ ប៉ុន្តែ បើសិនមានជម្រើសរវាងកូនប្រុស និងកូនស្រី ឪពុកម្តាយច្រើនទុកឱកាសអោយកូនប្រុសជាជាងកូនស្រី។ ទាំងអស់នេះ ជាកត្តាខាងក្រៅ។ យ៉ាងណាមិញមានកត្តាខាងក្នុងមួយចំនួនដែរ ដែលបណ្តាលអោយកុមារបោះបង់ចោលការសិក្សារ ដោយកុមារខ្លួនឯងមិនចាប់អារម្មណ៍ក្នុងការរៀនសូត្រ ចង់រកការងារធ្វើ ឬទៅឃ្វាលក្របីដោយសារមានគ្នាច្រើន។

តារាងទី ៤.៣៖ កម្រិតវប្បធម៌មេគ្រួសារក្នុងតំបន់សិក្សា

| ភេទរបស់មេគ្រួសារ | កម្រិតវប្បធម៌របស់មេគ្រួសារ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | មិនចេះអក្សរ | | បឋមសិក្សា | | អនុវិទ្យាល័យ | | វិទ្យាល័យ | | សរុប | |
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ប្រុស | ៧ | ១១.១ | ៣១ | ៤៩.២ | ៨ | ១២.៧ | ៥ | ៧.៩ | ៥១ | ៨១ |
| ស្ត្រី | ៧ | ១១.១ | ៥ | ៧.៩ | ០ | ០ | ០ | ០ | ១២ | ១៩ |
| សរុប | ១៤ | ២២.២ | ៣៦ | ៥៧.១ | ៨ | ១២.៧ | ៥ | ៧.៩ | ៦៣ | ១០០ |

ប្រភព៖ទិន្នន័យវិភាគ

### ឃ. មុខរបរចំបង បន្ទាប់បន្សំរបស់មេគ្រួសារ

មុខរបររបស់ប្រជាជន ត្រូវបានគេបែងចែកជា ៣ ប្រភេទមានដូចជា ការងារកសិកម្ម ការងារក្រៅកសិកម្ម និងការងារមិនមែនកសិកម្ម។ ការងារកសិកម្ម ជាការងារដែលបង្កបង្កើនផលកសិកម្មនៅក្នុងកសិដ្ឋានរួមមានដូចជាការដាំដំណាំស្រូវ ដំណាំចម្ការ បន្លែ ការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី។ល។ នៅក្នុងតំបន់សិក្សា មេគ្រួសារដែលប្រកបការងារកសិកម្មមានប្រមាណជា ៨៣ ភាគរយ។ ចំណែក ការងារក្រៅកសិកម្ម មានដូចជាអ្នកស៊ីឈ្នួលក្នុងកសិកម្ម នេសាទ ឡើងត្នោត ដែលកសិករមិនមានដីសម្រាប់បង្កបង្កើនផល ប៉ុន្តែធ្វើការងារដែលគាំទ្រដល់ការផលិត កសិផល។ នៅក្នុងតំបន់សិក្សា មិនមានមេគ្រួសារណាដែលពឹងផ្អែកលើមុខរបរក្រៅកសិកម្មជាចំបងនោះទេ ពិព្រោះកសិករសុទ្ធតែមានដីបង្កបង្កើនផលទោះតិចក្តីច្រើនក្តី។ យ៉ាងណាមិញ កសិករដែលមានជីវភាពខ្សត់ខ្សោយ បានប្រកបការងារក្រៅកសិកម្មជាការងារបន្ទាប់បន្សំ ដើម្បីរកប្រាក់ចំណូលបន្ថែមជួយគ្រួសារ។ ការងារមិនមែនកសិកម្ម ជាការងារដែលមិនពាក់ព័ន្ធនឹងកសិកម្ម មានដូចជា អាជីវករ កម្មករសំណង់ មន្ត្រីរាជការ ជាងធ្វើផ្ទះ។ ជាក់ស្តែង មេគ្រួសារដែលមានមុខរបរចំបងមិនមែនកសិកម្ម មានប្រមាណតែ ១៧ ភាគរយប៉ុណ្ណោះ។



ដ្យាក្រាមទី ៤.២ ប្រភេទមុខរបរចំបងរបស់មេគ្រួសារ

តារាងទី ៤.៤ ប្រភេទមុខរបរចំបងរបស់មេគ្រួសារ

| ប្រភេទមុខរបរ | | ចំនួន | ភាគរយ |
|---|---|---|---|
| ការងារកសិកម្ម | កសិករ | ៥២ | ៨២,៥ |
| ការងារមិនមែនកសិកម្ម | អ្នកថែសួន | ១ | ១,៦ |
| | អ្នកត្បាញកន្ទេរ, ស្លឹក, អង្រឹង | ៣ | ៤,8 |
| | កម្មករសំណង់ | ២ | ៣,២ |
| | ជាងផ្ទះ | ១ | ១,៦ |
| | មន្ត្រីរាជការ | ១ | ១,៦ |
| | អាជីវករ | ១ | ១,៦ |
| | មេផ្ទះ | ២ | ៣,២ |
| សរុប | | ៦៣ | ១០០ |

ប្រភពៈទិន្នន័យវិភាគ

**ង.មុខរបរបន្ទាប់បន្សំរបស់មេគ្រួសារ**

ក្រៅពីមុខរបរចំបង មេគ្រួសារត្រូវមានមុខរបរបន្ទាប់បន្សំផ្សេងទៀត ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។ នៅក្នុងតំបន់សិក្សា បើទោះបីជាគាត់មានមុខរបរចំបងការងារមិនមែនកសិកម្មក្តី នៅរដូវធ្វើស្រែគាត់តែងឆ្លាតពេលមកធ្វើស្រែជាការងារបន្ទាប់បន្សំ។ ចំណែកមេគ្រួសារដែលមានការងារកសិកម្ម ក៏ដូចគ្នា គាត់តែងរកការងារក្រៅកសិកម្ម និងមិនមែនកសិកម្មមកធ្វើបន្ថែម ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។ អ្នកខ្លះ នៅរដូវធ្វើស្រែ គាត់ឆ្លៀតពេលភ្ជួរស្រែខ្លួនឯងផង និងភ្ជួរអោយគេផងអោយគេផង ដើម្បីយកកម្រៃ។ ដល់រដូវប្រមូលផលដំឡូង គាត់ទៅស៊ីឈ្នួលដកដំឡូង និងកាប់ដំឡូង។ ជាពិសេស ដោយតំបន់សិក្សានៅជិតដងស្ទឹងជីនិតស្ទឹងជីនិត និងសម្បូរដោយបឹងបួរ កសិករអាចនេសាទដើម្បីទុកបរិភោគខ្លួនឯងខ្លះ និងលក់ដូរបានខ្លះ។ ក្រៅពីនេះ ប្រជាជនខ្លះប្រកបរបរមិនមែនកសិកម្ម ដូចជា ជាងសាងសង់ផ្ទះ អ្នកលក់ដូរ និងកម្មករសំណង់ជាដើម។



| | | | |
|---|---|---|---|
| ការងារកសិកម្ម | កសិករ | ៦ | ២០ |
| ការងារក្រៅកសិកម្ម | អ្នកស៊ីឈ្នួលភ្ជួរ | ២ | ៦,៧ |
| | អ្នកស៊ីឈ្នួលក្នុងកសិកម្ម | ១ | ៣,៣ |
| | អ្នកគង្វាលគោ-ក្របី | ២ | ៦,៧ |
| | អ្នកនេសាទ | ៧ | ២៣,៣ |
| ការងារមិនមែនកសិកម្ម | ជាងផ្ទះ | ៥ | ១៦,៧ |
| | កម្មករសំណង់ | ៧ | ២៣,៣ |
| | សរុប | ៣០ | ១០០ |

ប្រភព៖ទិន្នន័យវិភាគ

៤.២ ការបែងចែកប្រភេទការងាររវាងបុរស និងស្ត្រីក្នុងផលិតកម្មកសិកម្មនីមួយៗ

៤.២.១ ដំណាំស្រូវវស្សា

ដំណាំស្រូវវស្សា ជាដំណាំប្រពៃណីរបស់ប្រជាជនខ្មែរ ។ ដំណាំស្រូវវស្សានេះ ពឹងផ្អែកទាំងស្រុងលើទឹកភ្លៀង។ ម៉្យាងវិញទៀត ដោយសារតែប្រព័ន្ធធារាសាស្ត្រនៅក្នុងតំបន់សិក្សាមិនទាន់មានគ្រប់គ្រាន់នៅឡើយ ជាហេតុនាំឲ្យដំណាំស្រូវវស្សា ត្រូវបានកសិករជាច្រើននៅតែបន្តដាំរហូតដល់ពេលបច្ចុប្បន្ន។ ម៉្យាងវិញទៀត ការដាំដុះស្រូវវស្សា គឺសមស្របនឹងលក្ខខណ្ឌប្រព័ន្ធអេកូឡូស៊ីរបស់តំបន់សិក្សា ដោយតំបន់នេះស្ថិតក្នុងប្រព័ន្ធបឹងទន្លេសាប ដែលលិចទឹកជំនន់បឹងទន្លេសាបជារៀងរាល់ឆ្នាំ។ ស្រូវវស្សាដែលដាំដុះក្នុងតំបន់សិក្សា មានពីរប្រភេទដូចជា៖

- **ស្រូវវារ ឬស្រូវឡើងទឹក** ជាប្រភេទស្រូវវស្សា ដែលអាចធន់នឹងជំនន់បឹងទន្លេសាបបាន ព្រោះវាមានលទ្ធភាពលូតលាស់បានក្នុងជម្រៅទឹកជ្រៅបាន ៣ ទៅ ៥ ម៉ែត្រតាមប្រភេទពូជ។ ក្នុងតំបន់សិក្សាពូជដែលគេនិយមយកមកប្រើប្រាស់មានដូចជា ផ្កាព្រលិត បង្កក អង្គារ និងនាងសួន។ ស្រូវវារ ជាប្រភេទស្រូវធ្ងន់ ប្រើរយៈពេលពី ៦ ទៅ ៧ ខែទម្រាំទទួលបានផល។ កសិករចាប់ផ្តើម ភ្ជួរ និងព្រួសពូជស្រូវនៅកំឡុងខែ ៥ ទៅខែ ៦ ដោយរង់ចាំទឹកភ្លៀង។ បច្ចុប្បន្ន ការភ្ជួររាស់គេមិនប្រើគោក្របីដូចពីមុនទៀតនោះទេ កសិករភាគច្រើន ភ្ជួរគោយន្តដោយខ្លួនឯងឬជួលគេ និងអ្នកខ្លះមានលទ្ធភាពជួលត្រាក់ទ័រសម្រាប់ភ្ជួរ។ ការងារភ្ជួររាស់ ជាទូទៅជាការងាររបស់បុរស។ ចំណែកការព្រោះស្រូវវិញ ភាគច្រើនមានតែបុរសទេដែលចេះព្រួស ប៉ុន្តែ ស្ត្រី ជាអ្នកជួយជញ្ជូនពូជស្រូវ និងទូលល្អីស្រូវពេលព្រោះ។ ស្រូវវារ មិនប្រើប្រាស់ជី និងថ្នាំគីមីច្រើននោះទេ គឺគេប្រើជីលាមកគោសម្រាប់ទ្រាប់បាតមុនពេលព្រោះតែម្តងប៉ុណ្ណោះ ហើយមានកសិករខ្លះមិនប្រើសោះតែម្តង។ ចំណែក ថ្នាំគីមីវិញ គេប្រើសម្រាប់សម្លាប់ស្មៅក្នុងករណីមានស្មៅដុះក្រាស់ក្នុងស្រែ បើមានស្មៅតិចតួចគេដកដោយដៃប៉ុណ្ណោះ។ ការងារបាចជី និងបាញ់ថ្នាំស្មៅ ជាការងារបុរស ស្ត្រីកម្រធ្វើណាស់ ប៉ុន្តែស្ត្រីភាគច្រើនគឺទៅជួយជញ្ជូនជី និងដងទឹកសម្រាប់លាយថ្នាំស្មៅ។ ប៉ុន្តែបើត្រូវបោចស្មៅដោយដៃ បុរស និងស្ត្រីចូលរួមធ្វើដូចគ្នា។ លុះដល់ពេលប្រមូលផល គេនិយមជួលម៉ាស៊ីនច្រូតសម្រាប់ច្រូត។ យ៉ាងណាមិញ នៅមានកសិករខ្លះនៅច្រូតដោយដៃ ដោយសារគាត់ខ្វះខាតដើមទុនមិនអាចជួលម៉ាស៊ីនច្រូតបាន និងកសិករដែល មានដីតូចៗ។ ការងារប្រមូលផល ស្ត្រីនិងបុរសចូលរួមធ្វើជាមួយគ្នា តែភាគច្រើនគឺស្ត្រីជាអ្នកច្រូត។ បើប្រើម៉ាស៊ីនច្រូត វិញ កសិករត្រូវទៅកាន់ការ៉ុងច្រក និងដឹកជញ្ជូនមកផ្ទះវិញ។ ទិន្នផលស្រូវវារទាបជាងស្រូវដទៃ ព្រោះវាជាដំណាំយថាផល ប្រសិនបើមានទឹកគ្រប់គ្រាន់នោះវាទទួលបានទិន្នផលខ្ពស់ ប៉ុន្តែបើជំនន់ខ្លាំងពេក ឬរាំងស្ងួតនោះផលនឹងធ្លាក់ចុះខ្លាំង។ ជាក់ស្តែង នៅក្នុងឆ្នាំ២០១៥ ស្រូវវារទទួលបានទិន្នផលជាមធ្យមត្រឹមតែ ១,១១ តោនប៉ុណ្ណោះ ដោយសារតែឆ្នាំនោះគ្មានទឹកភ្លៀងគ្រប់គ្រាន់ ធ្វើអោយស្រូវស្កកម្ហូមអស់ចំនួនទ។ យោងតាមដ្យាក្រាមទី ៤.៤ ស្ត្រីចូលរួមក្នុងការដាំដុះស្រូវវារជាមធ្យម ៤៧,៣៦ ភាគរយ ហើយការចូលរួមរបស់បុរសវិញជាមធ្យម ៥២,៦៤ ភាគរយ។

- **ស្រូវវស្សា (ស្រូវធ្ងន់ និងស្រូវកណ្តាល)** ជាប្រភេទស្រូវវស្សាដែលពឹងផ្អែកលើទឹកភ្លៀង។ កសិករច្រើនធ្វើស្រូវនេះនៅស្រែលើ។ ស្រូវធ្ងន់មានច្រើនពូជដូចជា ផ្កាខ្ញី លាក់សន្លឹក ខា១១ រាំងជ័យ។ល។ ប៉ុន្តែនៅក្នុងតំបន់សិក្សា កសិករនិយមដាំស្រូវ រាំងជ័យ។ ស្រូវធ្ងន់ប្រើរយៈពេលត្រឹមតែ ៦ ខែប៉ុណ្ណោះគឺលឿនជាងស្រូវវារ ១ ខែ។ ដូច្នេះ ក្រោយពីប្រមូលផល ស្រូវធ្ងន់ កសិករអាចប្រមូលផលស្រូវវាបន្តបាន។ ចំណែក ស្រូវកណ្តាល មានលក្ខណៈប្រហាក់ប្រហែលដូចគ្នានឹងស្រូវធ្ងន់ដែលប៉ុន្តែវាមានអាយុកាលខ្លីជាងស្រូវធ្ងន់១ ខែ។ ពូជស្រូវកណ្តាលមានច្រើនប្រភេទដូចជា រំចង់ ផ្កាម្លិះ រំចេក រំដួល។ល។ ក្នុងតំបន់សិក្សា នាពេលបច្ចុប្បន្ន គេនិយមដាំពូជ រំដួល។ ការដាំដុះស្រូវរំដួល និងការបែងចែកប្រភេទការងាររវាងបុរស និងស្ត្រីគឺដូចគ្នានឹងស្រូវធ្ងន់ ដែរ។ ចំណែកឯ ទិន្នផលស្រូវកណ្តាលជាមធ្យមក្នុងឆ្នាំ២០១៥ នៃតំបន់សិក្សា ទទួលបាន ១,៥៣ តោនក្នុងមួយហិកតា។ សម្រាប់ស្រូវធ្ងន់កសិករនិយមប្រើប្រាស់ជីលាមកគោ លាយជាមួយជីគីមី ដើម្បីទ្រាប់បាត។ បន្ទាប់មកគេភ្ជួររាស់ និងព្រោះដូចគ្នានិងស្រូវវារដែរ ព្រោះការស្ទូងត្រូវចំណាយកម្លាំងពលកម្ម និងពេលវេលាយូរ។ ប៉ុន្តែគេភ្ជួរផ្តួលវាម្តងទៀតនៅពេលដែលស្រូវមានកម្ពស់ពាក់កណ្តាលកំពូនជើង(អាយុបាន ១ ខែ)។ នៅក្នុងដំណាក់កាលនេះផងដែរ កសិករបាចជីគីមីម្តងទៀត ដើម្បីអោយស្រូវស្ទុះលូតលាស់បានល្អ។ បន្ទាប់មក កសិករមើលថែទាំ ដកស្មៅ ឬបាញ់ថ្នាំស្មៅ ប្រសិនបើមានស្មៅដុះក្រាស់។ លុះដល់ ចុងខែ ១១ ឬដើមខែ ១២ ស្រូវទុំល្អ ទើបគេប្រមូលផលដោយម៉ាស៊ីនច្រូតភាគច្រើន។ ប៉ុន្តែនៅតែមានកសិករមួយចំនួននៅតែប្រមូលផលដោយដៃ ដោយដៃមានទំហំតិចតួច។ ក្នុងករណីច្រូតដៃ កសិករនិយមប្រវាស់ដៃគ្នា និងប្រើកម្លាំងពលកម្មក្នុងគ្រួសារប៉ុណ្ណោះ។ ចំណែកឯទិន្នផល (ឆ្នាំ ២០១៥) វិញ ទទួលបាន ១, ៣៨ តោនក្នុងមួយហិកតា ដោយសារតែឆ្នាំនោះមានការខ្វះខាតទឹក ហើយស្រូវស្លកអស់ច្រើន។ រីឯការបែងចែកប្រភេទការងារក្នុងការដាំដុះស្រូវធ្ងន់វិញគឺប្រហាក់ប្រហែលគ្នានឹងស្រូវវារដែរ។ យោងតាមដ្យាក្រាមទី ៤.៤ ស្ត្រីចូលរួមក្នុងការដាំដុះស្រូវវស្សាជាមធ្យម ៥០ ភាគរយ ហើយការចូលរួមរបស់បុរសវិញជាមធ្យម ៥០ ភាគរយ។

### ៤.២.២ ដំឡូងមី

កសិករច្រើនដាំដំឡូងមីលើដីស្រែ។ កសិករច្រើនដាំដំឡូងមីនៅខែ១ ហើយវាមានអាយុកាល ៦ ខែ ទើបអាចប្រមូលផលបាន។ មុនពេលចាប់ដាំដំឡូងមី កសិករត្រូវភ្ជួរលុបជញ្ជ្រាំងស្រូវដែលសល់ក្រោយប្រមូលផលស្រូវដើម្បីអោយជញ្ជ្រាំងស្រូវ និងស្មៅរលួយក្លាយជាជីធម្មជាតិ។ បន្ទាប់មក កសិករត្រូវដើររកទិញ ឬសុំដើមដំឡូងមីពីកសិករដទៃទៀត។ បន្ទាប់ពីបានដើមហើយ គេចាប់ផ្តើមភ្ជួររាស់ដីអោយស្អាត រួចបាចជីនិងពូនរងដាំ។ ការដាំដំឡូងមី មានការចូលរួមទាំងប្រុសទាំងស្រី។ ប៉ុន្តែស្រីៗភាគច្រើនជាកាប់ដើមជាកង់ៗរួចជាស្រេច ហើយបុរសជាអ្នកដាំ។ នៅក្នុងតំបន់សិក្សា កសិករមិនមានការថែទាំបន្ទាប់ពីដាំដូចជា យកល្បាស់ តែងមែក ឬបាចជីបន្ថែមទៀតទេ គឺគេរង់ចាំដល់ពេលប្រមូលផលតែម្តង។ លុះដល់ពេលប្រមូលផល ប្រុសៗជាអ្នកដក រីឯស្រីជាអ្នកចាំលួសយកតែមើមនិងប្រមូលដាក់រទេះទុកអោយបុរសដឹកមកផ្ទះ។ ប៉ុន្តែសម្រាប់គ្រួសារដែលមានកម្លាំងពលកម្មបុរសគ្រប់គ្រាន់ បុរសមានតួនាទីជាអ្នកប្រមូលផលនិងដឹកជញ្ជូនដំឡូងមកផ្ទះ។ ស្រីៗដែលនៅផ្ទះ ជាអ្នកកាប់ដំឡូង ហាល និងចាំសារដំឡូង។ បច្ចុប្បន្ននេះ មានកសិករមួយចំនួនតូចកែច្នៃម៉ាស៊ីនសម្រាប់កាប់ដំឡូងដើម្បីពន្លឿនការងារអោយឆាប់ហើយ។ ដោយការប្រមូលផលដំឡូងធ្វើនៅខែវស្សា ទើបធ្វើអោយការហាលប្រើពេលយូរ ហើយស្ត្រីមានការនឿយហត់ខ្លាំងក្នុងការសារដំឡូងចុះឡើង។ បន្ទាប់ពីដំឡូងស្ងួត កសិករប្រមូលដំឡូងច្រកបាវ នឹងចាំឈ្មួញមកទិញដល់ផ្ទះ។ទិន្នផលដំឡូងមីជាមធ្យមក្នុងឆ្នាំ ២០១៦ គឺ ៣,៤៦ តោនស្ងួតក្នុងមួយហិកតា។ យោងតាមដ្យាក្រាមទី ៤.៤ ស្ត្រីចូលរួមក្នុងការដាំដុះដំឡូងមីជាមធ្យម ៥៤,៩០ភាគរយ ហើយការចូលរួមរបស់បុរសវិញជាមធ្យម ៤៥,១០ ភាគរយ។

៤.២.៣ បន្លែ

នៅក្នុងចំណោមភូមិទាំង ៩ របស់ឃុំ មានតែភូមិថ្មីប៉ុណ្ណោះដែលមានសកម្មភាពដាំបន្លែច្រើនជាងគេ។ ចំណែកឯភូមិដទៃទៀតវិញ ប្រជាជនដាំបន្លែតិចតួចសម្រាប់បរិភោគ។ កត្តាដែលនាំអោយភូមិថ្មីមានការដាំបន្លែច្រើន ពីព្រោះកសិករមានដីធំទូលាយ ហើយភូមិនៅជិតថ្នល់ជាតិ ងាយដឹកកសិផលទៅលក់នៅឯកំពង់ផ្ទុំ។ យ៉ាងណាមិញ កសិករច្រើនដាំបន្លែនៅរដូវប្រាំងប៉ុណ្ណោះ ដោយនៅរដូវវស្សាដីជាំទឹក ធ្វើអោយពិបាកក្នុងការដាំ។ កសិករនិយមដាំបន្លែដូចជា ត្រកួន ស្ពៃចង្កឹះ ស្ពៃក្រញាញ់ ត្រប់ នននោង ត្រសក់ ឃ្លោក ជី ស្លឹកគ្រៃ ជាដើម។ ការងារដាំបន្លែ ភាគច្រើនជាការងាររបស់ស្ត្រី ពីព្រោះស្ត្រីជាអ្នកនៅផ្ទះជាប់ រីឯបុរសត្រូវចំណាកស្រុក ឬរកការងារធ្វើឆ្ងាយពីផ្ទះដូចជាការងារសំណង់ជាដើម។ យ៉ាងណាមិញ បុរសច្រើនចូលរួមជួយក្នុងសកម្មភាពរៀបចំដី និងសាងសង់ទ្រើងជាដើម ហើយការងារដាំដុះ ថែទាំ និងប្រមូលផលជាការងាររបស់ស្ត្រី។ យោងតាមដ្យាក្រាមទី ៤.៤ ស្ត្រីចូលរួមក្នុងការដាំដុះបន្លែជាមធ្យម ៨០ ភាគរយ ហើយការចូលរួមរបស់បុរសវិញជាមធ្យម ២០ ភាគរយ។

៤.២.៤ ការចិញ្ចឹមសត្វ

**ក. សត្វមាន់ ទា ជ្រូក**

កសិករភាគច្រើន ចិញ្ចឹមមាន់ទា សម្រាប់ហូប និងលក់ដូរតិចតួច។ ការចិញ្ចឹមមាន់ ទា នៅក្នុងតំបន់សិក្សាមិនមានអនុវត្តតាមបច្ចេកទេសនោះទេ គឺគេច្រើនអោយវាស៊ីអង្ករ ឬស្រូវ និងលែងវាចោល។ ចំណែក ឯទ្រុងវិញ គេសាងសង់នៅក្រោមផ្ទះ។ យ៉ាងណាមិញ មានកសិករមួយចំនួនតូច ដែលជាកសិកររបស់អង្គការម៉ូដ (MODE) បានចិញ្ចឹមមាន់តាមបច្ចេកទេស ទាំងការសាងសង់ទ្រុង ការចាក់វ៉ាក់សាំង ការផ្តល់ថ្នាំ ការផ្តល់ចំនី។ ចំណែក នៅភូមិព្រែកក្រោល ក៏មានការចិញ្ចឹមទាយកពងជាលក្ខណៈមធ្យមមួយកន្លែងដែរ។ ក្នុងការចិញ្ចឹមមាន់ទា ភាគច្រើនស្ត្រីមានតួនាទី ជាអ្នកផ្តល់ចំនី និងថែរក្សាបោសសំអាតទ្រុងជាប្រចាំថ្ងៃ។ ចំណែក ការសាងសង់ទ្រុង ការលាយវ៉ាក់សាំង ព្យាបាល ភាគច្រើនស្ត្រីមិនចេះនោះទេ ហើយវាជាការងាររបស់បុរស។ នៅក្នុងតំបន់សិក្សា មិនសូវមានកសិករចិញ្ចឹមជ្រូកប៉ុន្មាននោះទេ ដោយសារតែវាមិនសូវចំណេញ ជ្រូកឈឺច្រើន និងត្រូវចំណាយច្រើន។ យ៉ាងណាមិញ កសិករខ្លះចិញ្ចឹមជ្រូកមេ ដើម្បីយកកូនលក់ និងកសិករខ្លះទៀតចិញ្ចឹមជ្រូកសាច់។ ការចិញ្ចឹមជ្រូក នៅមិនមានលក្ខណៈបច្ចេកទេសនៅឡើយទេ។ ការចិញ្ចឹកជ្រូកភាគច្រើនជាការងាររបស់ស្ត្រី គឺគាត់ជាអ្នកអោយចំនី បោសសំអាតទ្រុង។ ករណីជ្រូកឈឺ កសិករច្រើនរកថ្នាំរុក្ខជាតិក្នុងភូមិ ដូចជាត្រួយស្តៅអោយជ្រូកស៊ី។ បើសិនជា វាមិនជា ទើបគេហៅពេទ្យមកចាក់ថ្នាំ។ បុរសច្រើន ជួយមើលការខុសត្រូវពេលសាងសង់ទ្រុង ដាក់បា និងចាប់ជ្រូកលក់។ យោងតាមដ្យាក្រាមទី ៤.៤ ស្ត្រីចូលរួមក្នុងការចិញ្ចឹម មាន់ទា ជាមធ្យម ៧៧,២៧ ភាគរយ ហើយការចូលរួមរបស់បុរសវិញជាមធ្យម ២២,៧៣ ភាគរយ។

**ខ. សត្វគោ-ក្របី**

កសិករចិញ្ចឹមគោក្របី គឺមិនដើម្បីជាកម្លាំងក្នុងការភ្ជួររាស់ និងដឹកជញ្ជូនទៀតឡើយ ដោយបច្ចុប្បន្នគេប្រើគ្រឿងយន្តមកជំនួសវិញ។ ក្នុងតំបន់សិក្សា ក្នុងមួយគ្រួសារមានចិញ្ចឹមគោជាមធ្យម ៣ ក្បាល។ កសិករចិញ្ចឹមគោក្របីដើម្បីធ្វើអាជីវកម្មតែប៉ុណ្ណោះ។ កសិករដែលមានគោ ក្របីចំនួនតិច ឬកសិករដែលខ្វះកម្លាំងពលកម្មក្នុងគ្រួសារច្រើនជួលអោយគេមើលគោក្របី ដោយតម្លៃ ២០,០០០ រៀលក្នុងមួយក្បាលក្នុងមួយខែ។ កសិករខ្លះជួលគេមើលនៅរដូវប្រាំង ហើយកសិករខ្លះយកគោក្របីមកទុកផ្ទះវិញនៅរដូវវស្សា ហើយច្រូតស្មៅអោយវាស៊ី លាយជាមួយចំបើងខ្លះ។ ចំណែកកសិករខ្លះ មិនជួលគេមើលនោះទេដោយគាត់មានចំនីគ្រប់គ្រាន់ និងមានពេលសម្រាប់មើលថែទាំគោ។ ផ្ទុយទៅវិញ កសិករខ្លះ ជួលគេមើលពេលមួយឆ្នាំពេញតែម្តង ដោយទៅមើលម្តងម្កាលតែពេលឈឺ ឬដាក់បាជាដើម។ ការងារមើលគោក្របី ភាគច្រើនជាការងាររបស់បុរសក្នុងគ្រួសារ ជាពិសេសអ្នកដែលស៊ីឈ្នួលមើលក្របីអោយគេ ពីព្រោះត្រូវនៅវាលក្រោមជាប់រហូត។ យ៉ាងណាមិញ បើគ្រួសារខ្វះកម្លាំងពលកម្មជាបុរស ឬគាត់ជាស្ត្រីមេម៉ាយ ការងារឃ្វាលគោ យកគោទៅចង អោយទឹកគោ គឺស្ត្រីជាអ្នករ៉ាប់រងទាំងស្រុង។ យោងតាមដ្យាក្រាមទី ៤.៤ ស្ត្រីចូលរួមក្នុងការមើលថែទាំគោក្របី ជាមធ្យម ៣៩,៥៨ ភាគរយ

ហើយការចូលរួមរបស់បុរសវិញជាមធ្យម ៦០,៤២ ភាគរយ។




- ប្រព័ន្ធទី០៤: ស្រូវវស្សា&ដំឡូងមី+មុខរបរបន្ទាប់បន្សំ (ស្វាយចន្ទី+បន្លែ+សត្វ)
- ប្រព័ន្ធទី០៥: ស្រូវវស្សា+មុខរបរបន្ទាប់បន្សំ(ស្វាយចន្ទី+បន្លែ+សត្វ)

ក្នុងការគណនាសេដ្ឋកិច្ចនៅក្នុងប្រធានបទនេះ គឺត្រូវការប្រើប្រាស់រូបមន្តដូចខាងក្រោមៈ

- ចំណូលដុល = បរិមាណសរុប x តម្លៃ

  TR = Q x P
- ចំណាយដុល = ចំណាយប្រែប្រួលសរុប + ចំណាយថេរសរុប

  TC = TVC + TFC
- ចំណូលសុទ្ធ = ចំណូលដុល - ចំណាយដុល

  NI =TR – TC

- ប្រសិទ្ធភាពសេដ្ឋកិច្ចនៃទុនផលិតកម្ម = ចំណូលដុល/ ចំណាយដុល

  EE = TR / TC
- តម្លៃរំលោះអចលនទ្រព្យ = (តម្លៃដំបូង - តម្លៃចុងក្រោយ)/ អាយុកាលប្រើប្រាស់

  D = (Po – Pn) / T

(បូរ៉ា កាជី, ២០១៤)

៤.៣.១ ប្រព័ន្ធផលិតកម្មទី០១

យោងតាមតារាងទី១ ក្នុងឧបសម្ព័ន្ធ មធ្យមនៃចំណូលពីផលិតកម្មស្រូវឡើងទឹកក្នុងផ្ទៃដីមួយហិកតា ចំណូលពីស្រូវវស្សា&ដំឡូងមីក្នុងផ្ទៃដីមួយហិកតា ចំណូលពីមុខរបរបន្ទាប់បន្សំ ទុនវិនិយោគ និងកម្លាំងពលកម្មក្នុងគ្រួសារជាមធ្យមក្នុងប្រព័ន្ធទី០១ បានបង្ហាញអោយឃើញថា ចំណូលពីស្រូវឡើងទឹកក្នុងផ្ទៃដីមួយហិកតាជាមធ្យម ៥៣៥.៥៦៤,៨១ រៀល ចំណូលពី ស្រូវវស្សា និងដំឡូងមីក្នុងផ្ទៃដីមួយហិកតាជាមធ្យម ២.៥៤២.២២៨,៣៤ រៀល ចំណូលពីមុខរបរបន្ទាប់បន្សំក្នុងការងារកសិកម្ម ៤.១០៨.៧៩៧,៦២ រៀល និងត្រូវការទុនវិនិយោគ ២.២៧០.៥៣៩,៨០ រៀល និងកម្លាំងពលកម្មសរុប ១៨៧ ថ្ងៃ ក្នុងនោះកម្លាំងពលកម្មស្ត្រីសរុប ៩០ ថ្ងៃ។

តារាងទី ៤.៦ ផលិតភាពនៃកម្លាំងពលកម្មស្ត្រី ផ្សារភ្ជាប់ទៅនឹងទុនវិនិយោគក្នុងប្រព័ន្ធទី០១

| ល.រ | ប្រភេទ | ទុនវិនិយោគក្នុងមួយថ្ងៃនៃប្រព័ន្ធទី០១ (៛) | ចំណេញសុទ្ធក្នុងមួយថ្ងៃនៃប្រព័ន្ធទី០១ (៛) | ចំណេញសុទ្ធសរុបក្នុងប្រព័ន្ធទី០១ (៛) | ការចូលរួមនៃកម្លាំងពលកម្មស្ត្រីក្នុងចំណេញសុទ្ធនៃប្រព័ន្ធទី០១ (៛) |
|---|---|---|---|---|---|
| ១ | ស្រូវឡើងទឹក | ៣៦.៩៥៤,៤២ | ៦៦.០៩៣,៥៥ | ១.១៧៩.៣៨៨,៨៩ | ៦៩៩.៤៩០,១២ |
| ២ | ស្រូវវស្សា&ដំឡូងមី | ១៣.១៨៣,៩៦ | ២៤.៩១៧,២៣ | ១.៣៤១.៩៤៤,៩០ | ៧៣៧.៦៥៣,៨៩ |
| ៣ | មុខរបរបន្ទាប់បន្សំ | ៥.៨៨៣,៦០ | ៣៣.៥៥៦,២៩ | ៤.១០៨.៧៩៧,៦២ | ១.៧៩៨.០៤៧,៧៥ |
| មធ្យម | | ១៨.៦៧៣,៩៩ | ៤១.៥២២,៣៦ | - | - |
| សរុប | | - | - | ៦.៦៣០.១៣១,៤១ | ៣.២៣៥.១៩១,៧៦ |

ប្រភពៈ ទិន្នន័យវិភាគ

ក្នុងប្រព័ន្ធផលិតកម្មទី០១ មនុស្សម្នាក់អាចទទួលបានប្រាក់ចំណេញសុទ្ធជាមធ្យមពីការធ្វើស្រូវឡើងទឹក ៦៦.០៩៣,៥៥ រៀលក្នុងមួយថ្ងៃ ដោយត្រូវការទុនវិនិយោគ ៣៦.៩៥៤,៤២ រៀលក្នុងមួយថ្ងៃ ហើយស្ត្រីបានចូលរួមបង្កើតប្រាក់ចំណូលសរុប ៦៩៩.៤៩០,១២ រៀល នៃប្រាក់ចំណេញសុទ្ធ ១.១៧៩.៣៨៨,៨៩ រៀល។ នៅលើផ្ទៃដីតែមួយ កសិករដែលដាំដុះស្រូវវស្សា ឆ្លាស់នឹងដំឡូងមី ទទួលបានប្រាក់ចំណេញសុទ្ធជាមធ្យម ២៤.៩១៧,២៣ រៀលក្នុងមួយថ្ងៃ ដោយត្រូវការទុនវិនិយោគ ១៣.១៨៣,៩៦ រៀលក្នុងមួយថ្ងៃ ហើយស្ត្រីបានចូលរួមបង្កើតប្រាក់ចំណូលសរុប ៧៣៧.៦៥៣,៨៩ រៀល នៃប្រាក់ចំណេញសុទ្ធ ១.៣៤១.៩៤៤,៩០ រៀល។ ចំពោះមុខរបរបន្ទាប់បន្សំវិញ មនុស្សម្នាក់អាចទទួលបានប្រាក់ចំណេញសុទ្ធជាមធ្យម ៣៣.៥៥៦,២៩ រៀលក្នុងមួយថ្ងៃ ដោយត្រូវការទុនវិនិយោគ ៥.៨៨៣,៦០ រៀលក្នុងមួយថ្ងៃ ហើយស្ត្រីបានចូលរួមបង្កើតប្រាក់ចំណូលសរុប ១.៧៩៧.០៤៧,៧៥ រៀល នៃប្រាក់ចំណេញសុទ្ធសរុប ៤.១០៨.៧៩៧,៦២ រៀល។

ក្នុងប្រព័ន្ធនេះ ចំណូលសុទ្ធបានពីមុខរបរបន្ទាប់បន្សំគឺច្រើនជាងគេ ហើយក្នុងនោះផលិតកម្មគោ និងក្របីទទួលបានប្រាក់ចំណេញសុទ្ធច្រើនជាងគេ (១.៩៣៤.៨០៩,៥២ រៀល) ហើយមានប្រសិទ្ធភាពសេដ្ឋកិច្ចដល់ទៅ ៧, ២៨ សូមមើលតារាងទី៦ ក្នុងឧបសម្ព័ន្ធ។

តារាងទី ៤.៧ ប្រសិទ្ធភាពសេដ្ឋកិច្ចនៃទុនផលិតកម្មនៃប្រព័ន្ធទី០១

| ចំណូលដុល (TR) | ចំណាយសរុប (TC) | ចំណូលសុទ្ធ (NI) | ប្រសិទ្ធភាពសេដ្ឋកិច្ច (E) |
|---|---|---|---|
| ៩.០០៨.៥៩២,៣៨ | ២.១២៩.៨៨៩,៥៥ | ៦.៦៣០.១៣២,៤១ | ៤,២៣ |

ប្រភពៈទិន្នន័យវិភាគ

តារាងខាងលើនេះបង្ហាញពីប្រសិទ្ធិភាពសេដ្ឋកិច្ចនៃទុនផលិតកម្មនៃប្រព័ន្ធផលិតកម្មទី០១ ដែលចំណូលដុល ៩.០៨៣.៧៩២,៣៩ រៀល ចំណាយដុល ២.២០៧.៣៥៩,៤៩ រៀល ចំណូលសុទ្ធ ៦.៨៧៦.២៣៣,៦០
រៀល។ ដូច្នេះប្រសិទ្ធិភាពសេដ្ឋកិច្ចគឺ ៤,១២ មានន័យថា កសិករវិនិយោគ ១ រៀល នឹងទទួលបានចំណូលដុល ៤,១២ រៀលមកវិញ ហើយបើដក ១ កសិករនឹងឃើញចំណេញសុទ្ធ ៣,១២ រៀល។

៤.៣.២ ប្រព័ន្ធផលិតកម្មទី០២

យោងតាមតារាងទី២ ក្នុងឧបសម្ព័ន្ធ មធ្យមនៃចំណូលពីផលិតកម្មស្រូវឡើងទឹកក្នុងផ្ទៃដីមួយហិកតា ចំណូលពីស្រូវវស្សាក្នុងផ្ទៃដីមួយហិកតា

ចំណូលពីមុខរបរបន្ទាប់បន្សំ ទុនវិនិយោគ និងកម្លាំងពលកម្មក្នុងគ្រួសារជាមធ្យមក្នុងប្រព័ន្ធទី០២ បានបង្ហាញអោយឃើញថា ចំណូលពីស្រូវឡើងទឹកក្នុងផ្ទៃដីមួយហិកតាជាមធ្យម ៥៥២.៦៣២,១៤ រៀល ចំណូលពីស្រូវវស្សាក្នុងផ្ទៃដីមួយហិកតាជាមធ្យម ៧៥៨.១៥៥,៧២ រៀល ចំណូលពីមុខរបរបន្ទាប់បន្សំក្នុងការងារកសិកម្ម ១.៦៤៤.៦៣៨,១០ រៀល និងត្រូវការទុនវិនិយោគ ២.១៨៤.៤០៣,៥៦ រៀល និងកម្លាំងពលកម្មសរុប ៩៥ ថ្ងៃ ក្នុងនោះកម្លាំងពលកម្មស្ត្រីសរុប ៤៥ ថ្ងៃ ។

តារាងទី ៤.៨ ផលិតភាពនៃកម្លាំងពលកម្មស្ត្រី ផ្សារភ្ជាប់ទៅនឹងទុនវិនិយោគក្នុងប្រព័ន្ធទី ០២

| ល.រ | ប្រភេទ | ទុនវិនិយោគក្នុងមួយថ្ងៃ នៃប្រព័ន្ធទី០២ (៛) | ចំណេញសុទ្ធក្នុងមួយថ្ងៃ នៃប្រព័ន្ធទី០២ (៛) | ចំណេញសុទ្ធសរុបក្នុងប្រព័ន្ធទី០២ (៛) | ការចូលរួមនៃកម្លាំងពលកម្មស្ត្រីក្នុងចំណេញសុទ្ធនៃប្រព័ន្ធទី០២ (៛) |
|---|---|---|---|---|---|
| ១ | ស្រូវឡើងទឹក | ៤៧.៧៤១,៧៣ | ៤៨.០៥៩,១៦ | ១.១៤១.៦០០,០០ | ៤០០,៧៨៦,៩៩ |
| ២ | ស្រូវវស្សា | ៥៩.១១៨,៨៥ | ៧៦.១៦១,៧២ | ១.១៦៨.៧៥០,០០ | ៤៣៤.៧៥៦,៤៨ |
| ៣ | មុខរបរបន្ទាប់បន្សំ | ១០.៥៤៥,៩០ | ៣៣.១០៣,៨០ | ១.៦៤៤.៦៣៨,១០ | ៧៣៦.០០៧,៧៩ |
| មធ្យម | | ៤៧.៧៤១,៧៣ | ៤៨.០៥៩,១៦ | - | - |
| សរុប | | - | - | ៣.៩៥៤.៩៨៨,១០ | ១.៥៧១.៥៥១,២៦ |

ប្រភពៈទិន្នន័យវិភាគ

ក្នុងប្រព័ន្ធផលិតកម្មទី០២ មនុស្សម្នាក់អាចទទួលបានប្រាក់ចំណេញសុទ្ធជាមធ្យមពីការធ្វើស្រូវឡើងទឹក៤៨.០៥៩,១៦ រៀលក្នុងមួយថ្ងៃ ដោយត្រូវការទុនវិនិយោគ ៤៧.៧៤១,៧៣ រៀលក្នុងមួយថ្ងៃ ហើយស្ត្រីបានចូលរួមបង្កើតប្រាក់ចំណូលសរុប ៤០០.៧៨៦,៩៩ រៀល នៃប្រាក់ចំណេញសុទ្ធ ១.១៤១.៦០០,០០ រៀល។ ចំណែក កសិករដែលដាំដុះស្រូវវស្សា ទទួលបានប្រាក់ចំណេញសុទ្ធជាមធ្យម ៧៦.១៦១,៧២ រៀលក្នុងមួយថ្ងៃ ដោយត្រូវការទុនវិនិយោគ ៨៧.៤២៤,២៤ រៀលក្នុងមួយថ្ងៃ ហើយស្ត្រីបានចូលរួមបង្កើតប្រាក់ចំណូលសរុប ៤៣៤.៧៥៦,៤៨ រៀល នៃប្រាក់ចំណេញសុទ្ធ ១.១៦៨.៧៥០,០០ រៀល។ ចំពោះមុខរបរបន្ទាប់បន្សំវិញ មនុស្សម្នាក់អាចទទួលបានប្រាក់ចំណេញសុទ្ធជាមធ្យម ៣៣.១០៣,៨០ រៀលក្នុងមួយថ្ងៃ ដោយត្រូវការទុនវិនិយោគ ១០.៥៤៥,៩០ រៀលក្នុងមួយថ្ងៃ ហើយស្ត្រីបានចូលរួមបង្កើតប្រាក់ចំណូលសរុប ៧៣៦.០០៧,៧៩ រៀល នៃប្រាក់ចំណេញសុទ្ធសរុប ១.៦៤៤.៦៣៨,១០ រៀល។

ក្នុងប្រព័ន្ធនេះ ចំណូលសុទ្ធបានពីការធ្វើស្រូវវស្សាគឺច្រើនជាងគេ ដោយទទួលបានប្រាក់ចំណេញសុទ្ធ ១.១៦៨.៧៥០,០០ រៀល ហើយមានប្រសិទ្ធភាពសេដ្ឋកិច្ច ១, ៩៧ សូមមើលតារាងទី៧ ក្នុងឧបសម្ព័ន្ធ។

តារាងទី ៤.៩ ប្រសិទ្ធភាពសេដ្ឋកិច្ចនៃទុនផលិតកម្មនៃប្រព័ន្ធទី ០២

| ចំណូលសរុប (TR) | ចំណាយសរុប (TC) | ចំណូលសុទ្ធ (NI) | ប្រសិទ្ធភាពសេដ្ឋកិច្ច (E) |
|---|---|---|---|
| ៦.៣៩៤.៤០៤,៧៦ | ២.៦១៦.៣៩៩,៩៩ | ៣.៧៧៨.០០៤,៧៦ | ២,៤៤ |

ប្រភពៈទិន្នន័យវិភាគ

តារាងខាងលើនេះបង្ហាញពីប្រសិទ្ធិភាពសេដ្ឋកិច្ចនៃទុនផលិតកម្មនៃប្រព័ន្ធផលិតកម្មទី០២ ដែលចំណូលដុល ៦.៣៩៤.៤០៤,៧៦ រៀល ចំណាយដុល ៣.៦១៦.៣៩៩,៩៩ រៀល ចំណូលសុទ្ធ ៣.៧៧៨.០០៤,៧៦ រៀល។ ដូច្នេះប្រសិទ្ធិភាពសេដ្ឋកិច្ចគឺ ២,៤៤ មានន័យថា កសិករវិនិយោគ ១ រៀល នឹងទទួលបានចំណូលដុល ២,៤៤ រៀលមកវិញ ហើយបើដក ១ កសិករនឹងឃើញចំណេញសុទ្ធ ១,៤៤ រៀល។

៤.៣.៣ ប្រព័ន្ធផលិតកម្មទី០៣

យោងតាមតារាងទី៣ ក្នុងឧបសម្ព័ន្ធ មធ្យមនៃចំណូលពីផលិតកម្មស្រូវឡើងទឹកក្នុងផ្ទៃដីមួយហិកតា ចំណូលពីមុខរបរបន្ទាប់បន្សំ ទុនវិនិយោគ និងកម្លាំងពលកម្មក្នុងគ្រួសារជាមធ្យមក្នុងប្រព័ន្ធទី០៣ បានបង្ហាញអោយឃើញថា ចំណូលពីស្រូវឡើងទឹកក្នុងផ្ទៃដីមួយហិកតាជាមធ្យម ៥៤៣.២០៩,៣៧ រៀល ចំណូលពីមុខរបរបន្ទាប់បន្សំក្នុងការងារកសិកម្ម ១.៦៨៧.១២៧,៣៥ រៀល និងត្រូវការទុនវិនិយោគ ១.៦២៧.៩១៥,៣៨ រៀល និងកម្លាំងពលកម្មសរុប ៨៣ ថ្ងៃ (Mainday) ក្នុងនោះកម្លាំងពលកម្មស្ត្រីសរុប ៤៨ ថ្ងៃ (Mainday) ។

តារាងទី ៤.១០ ផលិតភាពនៃកម្លាំងពលកម្មស្ត្រី ផ្សារភ្ជាប់ទៅនឹងទុនវិនិយោគក្នុងប្រព័ន្ធទី ០៣

| ល.រ | ប្រភេទ | ទុនវិនិយោគក្នុងមួយថ្ងៃនៃប្រព័ន្ធទី០៣ (៛) | ចំណេញសុទ្ធក្នុងមួយថ្ងៃនៃប្រព័ន្ធទី០៣ (៛) | ចំណេញសុទ្ធសរុបក្នុងប្រព័ន្ធទី០៣ (៛) | ការចូលរួមនៃកម្លាំងពលកម្មស្ត្រីក្នុងចំណេញសុទ្ធនៃប្រព័ន្ធទី០៣ (៛) |
|---|---|---|---|---|---|
| ១ | ស្រូវឡើងទឹក | ៤៨.៧៩៣,៥៩ | ៦៤.១៥៦,៩២ | ៨៤៩.៥៩២,០០ | ៥៥០.៤៦៦,៤១ |
| ២ | មុខរបរបន្ទាប់បន្សំ | ៩.៣៦០,១៩ | ២៥.១៣៦,៦១ | ១.៦៨៧.១២៧,៣៥ | ១.១៤៤.៨០៥,០០ |
| មធ្យម | | ២៩.០៧៦,៨៩ | ៤៤.៦៤៦,៧៧ | - | - |
| សរុប | | - | - | ២.៥៣៦.៧១៩,៣៥ | ១.៦៩៥.២៧១,៤១ |

ប្រភពៈទិន្នន័យវិភាគ

ក្នុងប្រព័ន្ធផលិតកម្មទី០៣ មនុស្សម្នាក់អាចទទួលបានប្រាក់ចំណេញសុទ្ធជាមធ្យមពីការធ្វើស្រូវឡើងទឹក៤៨.៧៩៣,៥៩ រៀលក្នុងមួយថ្ងៃ ដោយត្រូវការទុនវិនិយោគ ៦៤.១៥៦,៩២ រៀលក្នុងមួយថ្ងៃ ហើយស្ត្រីបានចូលរួមបង្កើតប្រាក់ចំណូលសរុប ៥៥០.៤៦៦,៤១ រៀល នៃប្រាក់ចំណេញសុទ្ធ ៨៤៩.៥៩២,០០ រៀល។ ចំពោះមុខរបរបន្ទាប់បន្សំវិញ មនុស្សម្នាក់អាចទទួលបានប្រាក់ចំណេញសុទ្ធជាមធ្យម ២៥.១៣៦,៦១ រៀលក្នុងមួយថ្ងៃ ដោយត្រូវការទុនវិនិយោគ ៩.៣៦០,១៩ រៀលក្នុងមួយថ្ងៃ ហើយស្ត្រីបានចូលរួមបង្កើតប្រាក់ចំណូលសរុប ១.១៤៤.៨០៥,០០ រៀល នៃប្រាក់ចំណេញសុទ្ធសរុប ១.៦៨៧.១២៧,៣៥ រៀល។

តារាងទី ៤.១១ ប្រសិទ្ធភាពសេដ្ឋកិច្ចនៃទុនផលិតកម្មនៃប្រព័ន្ធទី ០៣

| ចំណូលសរុប (TR) | ចំណាយសរុប (TC) | ចំណូលសុទ្ធ (NI) | ប្រសិទ្ធភាពសេដ្ឋកិច្ច (E) |
|---|---|---|---|
| ៤.៣១១.២១៧,៤៩ | ១.៦០២.៦៤៨,៣៩ | ២.៥៣៦.៧១៩,៣៥ | ២,៦៩ |

ប្រភពៈទិន្នន័យវិភាគ

តារាងខាងលើនេះបង្ហាញពីប្រសិទ្ធិភាពសេដ្ឋកិច្ចនៃទុនផលិតកម្មនៃប្រព័ន្ធផលិតកម្មទី០៣ ដែលចំណូលដុល ៤.៣១១.២១៧,៤៩ រៀល ចំណាយដុល ១.៦០២.៦៤៨,៣៩ រៀល ចំណូលសុទ្ធ ២.៥៣៦.៧១៩,៣៥ រៀល។ ដូច្នេះប្រសិទ្ធិភាពសេដ្ឋកិច្ចគឺ ២,៦៩ មានន័យថា កសិករវិនិយោគ ១ រៀល នឹងទទួលបានចំណូលដុល ២,៦៩ រៀលមកវិញ ហើយបើដក ១ កសិករនឹងឃើញចំណេញសុទ្ធ ១,៦៩ រៀល។

ក្នុងប្រព័ន្ធនេះ ចំណូលសុទ្ធបានពីមុខរបរបន្ទាប់បន្សំគឺច្រើនជាងគេ ហើយក្នុងនោះផលិតកម្មគោ និងក្របីទទួលបានប្រាក់ចំណេញសុទ្ធច្រើនជាងគេ (១.០១១.៣៨១,៩៤ រៀល) ហើយមានប្រសិទ្ធភាពសេដ្ឋកិច្ចដល់ទៅ
៤, ៧៥ សូមមើលតារាងទី៨ ក្នុងឧបសម្ព័ន្ធ។

៤.៣.៤ ប្រព័ន្ធផលិតកម្មទី០៤

យោងតាមតារាងទី៩ ក្នុងឧបសម្ព័ន្ធ មធ្យមនៃចំណូលពីស្រូវវស្សា&ដំឡូងមីក្នុងផ្ទៃដីមួយហិកតា ចំណូលពីមុខរបរបន្ទាប់បន្សំ ទុនវិនិយោគ និងកម្លាំងពលកម្មក្នុងគ្រួសារជាមធ្យមក្នុងប្រព័ន្ធទី០៤ បានបង្ហាញអោយឃើញថាចំណូលពីស្រូវវស្សា&ដំឡូងមីក្នុងផ្ទៃដីមួយហិកតាជាមធ្យម ១.៣៥២.៧៧២,៩៩ រៀល ចំណូលពីមុខរបរបន្ទាប់បន្សំ ក្នុងការងារកសិកម្ម ១.៨១១.២២៣,៣៣ រៀល និងត្រូវការទុនវិនិយោគ ២.១៤៦.៤៩១,២០ រៀល និងកម្លាំងពលកម្មសរុប ១៦០ ថ្ងៃ ក្នុងនោះកម្លាំងពលកម្មស្ត្រីសរុប ៨២ ថ្ងៃ ។

តារាងទី ៤.១២ ផលិតភាពនៃកម្លាំងពលកម្មស្ត្រី ផ្សារភ្ជាប់ទៅនឹងទុនវិនិយោគក្នុងប្រព័ន្ធទី ០៤

| ល.រ | ប្រភេទ | ទុនវិនិយោគក្នុងមួយថ្ងៃនៃប្រព័ន្ធទី០៤ (៛) | ចំណេញសុទ្ធក្នុងមួយថ្ងៃនៃប្រព័ន្ធទី០៤ (៛) | ចំណេញសុទ្ធសរុបក្នុងប្រព័ន្ធទី០៤ (៛) | ការចូលរួមនៃកម្លាំងពលកម្មស្ត្រីក្នុងចំណេញសុទ្ធនៃប្រព័ន្ធទី០៤ (៛) |
|---|---|---|---|---|---|
| ១ | ស្រូវវស្សា&ដំឡូងមី | ២០.៩៨៨,២៧ | ២១.៣៤៧,៣៩ | ១.៧៤៣.៦៦៦,៦៧ | ១.៤៩៣.៤២៧,៨២ |
| ២ | មុខរបរបន្ទាប់បន្សំ | ៥.៤១៥,៨៣ | ២៣.២០៤,៧៦ | ១.៨១១.២២៣,៣៣ | ៨៤២.៣០៨,៦០ |
| មធ្យម | | ១៣,២០២,០៥ | ២៥.៥២៥,៣០ | - | - |
| សរុប | | - | - | ៣.៥៥៤.៨៩០,០០ | ២.៧៩០.៣៥៦,៥៣ |

ប្រភពៈទិន្នន័យវិភាគ

នៅក្នុងប្រព័ន្ធទី០៤ កសិករដែលដាំដុះស្រូវវស្សា ឆ្លាស់នឹងដំឡូងមីនៅលើផ្ទៃដីតែមួយ ទទួលបានប្រាក់ចំណេញសុទ្ធជាមធ្យម ២១.៣៤៧,៣៩ រៀលក្នុងមួយថ្ងៃ ដោយត្រូវការទុនវិនិយោគ ២០.៩៨៨,២៧ រៀលក្នុងមួយថ្ងៃ ហើយស្ត្រីបានចូលរួមបង្កើតប្រាក់ចំណូលសរុប ១.៤៩៣.៤២៧,៨២ រៀល នៃប្រាក់ចំណេញសុទ្ធ ១.៧៤៣.៦៦៧,៦៧ រៀល។ ចំពោះមុខរបរបន្ទាប់បន្សំវិញ មនុស្សម្នាក់អាចទទួលបានប្រាក់ចំណេញសុទ្ធជាមធ្យម ២៣.២០៤,៧៦ រៀលក្នុងមួយថ្ងៃ ដោយត្រូវការទុនវិនិយោគ ៥.៤១៥,៨៣ រៀលក្នុងមួយថ្ងៃ ហើយស្ត្រីបានចូលរួមបង្កើតប្រាក់ចំណូលសរុប ៨៤២.៣០៨,៦០ រៀល នៃប្រាក់ចំណេញសុទ្ធសរុប ១.៨១១.២២៣,៣៣ រៀល។

តារាងទី ៤.១៣ ប្រសិទ្ធភាពសេដ្ឋកិច្ចនៃទុនផលិតកម្មនៃប្រព័ន្ធទី ០៤

| ចំណូលសរុប (TR) | ចំណាយសរុប (TC) | ចំណូលសុទ្ធ (NI) | ប្រសិទ្ធភាពសេដ្ឋកិច្ច(E) |
|---|---|---|---|
| ៥.៧១៥.៣៩៤,៤៤ | ២.១៣៧.០៦០,០០ | ៣.៥៥៤.៨៩០,០០ | ២,៦៧ |

ប្រភពៈ ទិន្នន័យវិភាគ

តារាងខាងលើនេះបង្ហាញពីប្រសិទ្ធិភាពសេដ្ឋកិច្ចនៃទុនផលិតកម្មនៃប្រព័ន្ធផលិតកម្មទី០៤ ដែលចំណូលដុល ៥.៧១៥.៣៩៤,៤៤ រៀល ចំណាយដុល ២.១៣៧.០៦០,០០ រៀល ចំណូលសុទ្ធ

៣.៥៥៤.៨៨០,០០ រៀល។ ដូច្នេះប្រសិទ្ធិភាពសេដ្ឋកិច្ចគឺ ២,៦៧ មានន័យថា កសិករវិនិយោគ ១ រៀល នឹងទទួលបានចំណូលដុល ២,៦៧ រៀលមកវិញ ហើយបើដក ១ កសិករនឹងឃើញចំណេញសុទ្ធ ១,៦៧ រៀល។

ក្នុងប្រព័ន្ធនេះ ចំណូលសុទ្ធបានពីមុខរបរបន្ទាប់បន្សំគឺច្រើនជាងគេ ហើយក្នុងនោះផលិតកម្មគោ និងក្របីទទួលបានប្រាក់ចំណេញសុទ្ធច្រើនជាងគេ (១.០៤០.៧០៥,០០ រៀល) ហើយមានប្រសិទ្ធភាពសេដ្ឋកិច្ចដល់ទៅ
៥, ៣៩ សូមមើលតារាងទី៩ ក្នុងឧបសម្ព័ន្ធ។

៤.៣.៥ ប្រព័ន្ធផលិតកម្មទី០៥

យោងតាមតារាងទី៥ ក្នុងឧបសម្ព័ន្ធ មធ្យមនៃចំណូលពីស្រូវវស្សា ចំណូលពីមុខរបរបន្ទាប់បន្សំ ទុនវិនិយោគ និងកម្លាំងពលកម្មក្នុងគ្រួសារជាមធ្យមក្នុងប្រព័ន្ធទី០៥ បានបង្ហាញអោយឃើញថា ចំណូលពីស្រូវវស្សាក្នុងផ្ទៃដីមួយហិកតាជាមធ្យម ៨៧៣.៨៧៩,២៧ រៀល ចំណូលពីមុខរបរបន្ទាប់បន្សំក្នុងការងារកសិកម្ម ១.៨៩២.៨៩៨,៨១ រៀល និងត្រូវការទុនវិនិយោគ ១.៤០៨.៣៣៣,៣៣ រៀល និងកម្លាំងពលកម្មសរុប ៩៥ ថ្ងៃ ក្នុងនោះកម្លាំងពលកម្មស្ត្រីសរុប ៦២ ថ្ងៃ។

តារាងទី ៤.១៤ ផលិតភាពនៃកម្លាំងពលកម្មស្ត្រី ផ្សារភ្ជាប់ទៅនឹងទុនវិនិយោគក្នុងប្រព័ន្ធទី ០៥

| ល.រ | ប្រភេទ | ទុនវិនិយោគក្នុងមួយថ្ងៃ នៃប្រព័ន្ធទី០៥ (៛) | ចំណេញសុទ្ធក្នុងមួយថ្ងៃ នៃប្រព័ន្ធទី០៥ (៛) | ចំណេញសុទ្ធសរុបក្នុងប្រព័ន្ធទី០៥ (៛) | ការចូលរួមនៃកម្លាំងពលកម្មស្ត្រីក្នុងចំណេញសុទ្ធនៃប្រព័ន្ធទី០៥ (៛) |
|---|---|---|---|---|---|
| ១ | ស្រូវវស្សា | ៤៦.៩៨៥,៦៧ | ៨២.១១៤,៣៨ | ១.០៤០.០៨៣,៣៣ | ៦៥៨.៦២៥,៧៤ |
| ២ | មុខរបរបន្ទាប់បន្សំ | ៦.២៧៧,៦១ | ២៤.១៤៧,៧៦ | ១.៧២៣.០២៣,៨១ | ១.២២១.៨៦១,០៨ |
| មធ្យម | | ២៦.៦៣១,៦៤ | ៥៣.១៣១,០៧ | - | - |
| សរុប | | - | - | ២.៧៦៣.១០៧,១៤ | ១.៨៨០.៤៨៦,៨២ |

ប្រភពៈទិន្នន័យវិភាគ

នៅក្នុងប្រព័ន្ធទី០៥ កសិករដែលដាំដុះស្រូវវស្សា ទទួលបានប្រាក់ចំណេញសុទ្ធជាមធ្យម ៨២.១១៤,៣៨ រៀលក្នុងមួយថ្ងៃ ដោយត្រូវការទុនវិនិយោគ ៤៦.៩៨៥,៦៧ រៀលក្នុងមួយថ្ងៃ ហើយស្ត្រីបានចូលរួមបង្កើតប្រាក់ចំណូលសរុប ៦៥៨.៦២៥,៨២ រៀល នៃប្រាក់ចំណេញសុទ្ធ ១.០៤០.០៨៣,៣៣ រៀល។ ចំពោះមុខរបរបន្ទាប់បន្សំវិញ មនុស្សម្នាក់អាចទទួលបានប្រាក់ចំណេញសុទ្ធជាមធ្យម ២៤.១៤៧,៧៦ រៀលក្នុងមួយថ្ងៃ ដោយត្រូវការទុនវិនិយោគ ៦.២៧៧,៦១ រៀលក្នុងមួយថ្ងៃ ហើយស្ត្រីបានចូលរួមបង្កើតប្រាក់ចំណូលសរុប ១២២១.៨៦១,០៨ រៀល នៃប្រាក់ចំណេញសុទ្ធសរុប ១.៧២៣.០២៣,៨១ រៀល។

តារាងទី ៤.១៥ ប្រសិទ្ធភាពសេដ្ឋកិច្ចនៃទុនផលិតកម្មនៃប្រព័ន្ធទី ០៥

| ចំណូលសរុប (TR) | ចំណាយសរុប (TC) | ចំណូលសុទ្ធ (NI) | ប្រសិទ្ធភាពសេដ្ឋកិច្ច (E) |
|---|---|---|---|
| ៣.៨៩៤.២៨៥,៧១ | ១.១៣១.១៧៨,៥៦ | ២.៧៦៣.១០៧,១៤ | ៣,៤៤ |

ប្រភពៈទិន្នន័យវិភាគ

តារាងខាងលើនេះបង្ហាញពីប្រសិទ្ធិភាពសេដ្ឋកិច្ចនៃទុនផលិតកម្មនៃប្រព័ន្ធផលិតកម្មទី០៥ ដែលចំណូលដុល ៣.៨៩៤.២៨៥,៧១ រៀល ចំណាយដុល ១.១៣១.១៧៨,៥៦ រៀល ចំណូលសុទ្ធ ២.៧៦៣.១០៧,១៤ រៀល។ ដូច្នេះប្រសិទ្ធិភាពសេដ្ឋកិច្ចគឺ ៣,៤៤ មានន័យថា កសិករវិនិយោគ ១ រៀល នឹងទទួលបានចំណូលដុល ៣,៤៤ រៀលមកវិញ ហើយបើដក ១ កសិករនឹងឃើញចំណេញសុទ្ធ ២,៤៤ រៀល។

ក្នុងប្រព័ន្ធនេះ ចំណូលសុទ្ធបានពីការធ្វើស្រូវវស្សាគឺច្រើនជាងគេ ដោយទទួលបានប្រាក់ចំណេញសុទ្ធ ១.០៤០.០៨៣,៣៣ រៀល ហើយមានប្រសិទ្ធភាពសេដ្ឋកិច្ច ២, ៥២ សូមមើលតារាងទី៧ ក្នុងឧបសម្ព័ន្ធ។

### ៤.៣.៦ ការប្រៀបធៀបសេដ្ឋកិច្ចនៃប្រព័ន្ធផលិតកម្មក្នុងតំបន់សិក្សា

តារាងទី ៤.១៦ ប្រៀបធៀបទុនវិនិយោគ ចំណេញសុទ្ធក្នុងមួយកម្លាំងពលកម្ម ចំណេញសុទ្ធសរុប និងការចូលរួមនៃកម្លាំងពលកម្មស្ត្រីក្នុងចំណេញសុទ្ធនៃប្រព័ន្ធនីមួយៗ

| ល.រ | ប្រភេទ | ទុនវិនិយោគក្នុងមួយថ្ងៃ (៛) | ចំណេញសុទ្ធក្នុងមួយថ្ងៃ (៛) | ចំណេញសុទ្ធសរុប (៛) | ការចូលរួមនៃកម្លាំងពលកម្មស្ត្រីក្នុងចំណេញសុទ្ធ |
|---|---|---|---|---|---|
| ១ | ប្រព័ន្ធទី០១ | ១៨.៦៧៣,៩៩ | ៤១.៥២២,៣៦ | ៦.៦៣០.១៣១,៤១ | ៣.២៣៥.១៩១,៧៦ |
| ២ | ប្រព័ន្ធទី០២ | ៤៧.៧៤១,៧៣ | ៤៨.០៥៩,១៦ | ៣.៩៥៤.៩៨៨,១០ | ១.៥៧១.៥៥១,២៦ |
| ៣ | ប្រព័ន្ធទី០៣ | ២៩.០៧៦,៨៩ | ៤៤.៦៤៦,៧៧ | ២.៥៣៦.៧១៩,៣៥ | ១.៦៩៥.២៧១,៤១ |
| ៤ | ប្រព័ន្ធទី០៤ | ១៣.២០២,០៥ | ២៥.៥២៥,៣០ | ៣.៥៥៤.៨៩០,០០ | ២.៧៩០.៣៥៦,៥៣ |
| ៥ | ប្រព័ន្ធទី០៥ | ២៦.៦៣១,៦៤ | ៥៣.១៣១,០៧ | ២.៧៦៣.១០៧,១៤ | ១.៨៨០.៤៨៦,៨២ |

ប្រភពៈទិន្នន័យវិភាគ

ការប្រៀបធៀបនៃប្រព័ន្ធផលិតកម្មនីមួយៗ នៅក្នុងតំបន់សិក្សា គឺការប្រៀបធៀបចំណេញសុទ្ធក្នុងមនុស្សម្នាក់ក្នុងមួយថ្ងៃ និងប្រៀបធៀបប្រសិទ្ធិភាពសេដ្ឋកិច្ចរបស់ប្រព័ន្ធនីមួយៗ ដើម្បីវិភាគអោយឃើញប្រព័ន្ធណាមួយមានភាពប្រសើរជាងគេ។

ខាងលើនេះបង្ហាញពីចំណេញរបស់មនុស្សម្នាក់ក្នុងមួយថ្ងៃ ទុនវិនិយោគ ចំណេញសុទ្ធសរុបក្នុងប្រព័ន្ធនីមួយៗ ការចូលរួមនៃកម្លាំងពលកម្មស្ត្រីក្នុងចំណេញសុទ្ធ។ ក្នុងចំណោមប្រព័ន្ធទាំងអស់ ប្រព័ន្ធទី ០៥ ទទួលបានចំណេញសុទ្ធនៃមនុស្សម្នាក់ក្នុងមួយថ្ងៃច្រើនជាងគេ គឺ ៥៣.១៣១,០៧ រៀលក្នុងមួយថ្ងៃ ហើយធំបន្ទាប់គឺប្រព័ន្ធទី ០២ គឺទទួលបាន ៤៨.០៥៩,១៦ រៀលក្នុងមួយថ្ងៃ ហើយប្រព័ន្ធដែលទទួលបានចំណេញសុទ្ធក្នុងមួយកម្លាំងពលកម្មតិចជាងគេ គឺប្រព័ន្ធទី ០៤ ដោយទទួលបានត្រឹមតែ ២.៥២៥,៣០ រៀលក្នុងមួយថ្ងៃតែប៉ុណ្ណោះ។ យ៉ាងណាមិញ ក្នុងចំនោមប្រព័ន្ធទាំងអស់ ប្រព័ន្ធទី០១ កសិករទទួលបានប្រាក់ចំណេញសុទ្ធច្រើនជាងគេ គឺរហូតដល់ ៦.៦៣០.១៣១,៤១ រៀល បើទោះបីជាគាត់ទទួលបានចំណេញសុទ្ធក្នុងមួយកម្លាំងពលកម្មត្រឹមតែ ៤១.៥២២,៣៦ រៀលក្នុងមួយថ្ងៃ ពីព្រោះតែគាត់ត្រូវចំណាយពេលជាច្រើនថ្ងៃក្នុងការងារកសិកម្មច្រើនជាងប្រព័ន្ធដទៃទៀត (ជាមធ្យម ១៨៧ ថ្ងៃ) ដោយសារប្រព័ន្ធនេះមានការដាំដុះដំណាំជាច្រើនប្រភេទ ។ យើងឃើញថាស្ត្រីចូលរួមចំណែកជាច្រើនក្នុងការបង្កើតប្រាក់ចំណេញក្នុងប្រព័ន្ធនីមួយៗ ជាក់ស្តែង នៅក្នុងប្រព័ន្ធទី០១ និងប្រព័ន្ធទី០៤ ស្ត្រីចូលរួមចំណែករហូតដល់ ៣.២៣៥.១៩១,៧៦ រៀលសម្រាប់ប្រព័ន្ធទី០១ និង ២.៧៩០.៣៥៦,៥៣ រៀល សម្រាប់ប្រព័ន្ធទី០៤។ មូលហេតុដែលប្រព័ន្ធទាំងពីរនេះ មានការចូលរួមរបស់ស្ត្រីច្រើនជាងគេ ពីព្រោះប្រព័ន្ធទាំងពីរនេះសុទ្ធដាំដំឡូងមី គឺជាប្រភេទដំណាំដែលមានការចូលរួមពីស្ត្រីច្រើន។

តារាងទី ៤.១៧ ប្រៀបធៀបប្រសិទ្ធភាពសេដ្ឋកិច្ចនៃប្រព័ន្ធនីមួយៗ

| ល.រ | ប្រភេទប្រព័ន្ធ | ចំណូលសរុប (TR) (៛) | ចំណាយសរុប (TC) (៛) | ចំណូលសុទ្ធ (NI) (៛) | ប្រសិទ្ធភាពសេដ្ឋកិច្ច (E) |
|---|---|---|---|---|---|

| | | | | | |
|---|---|---|---|---|---|
| ១ | ប្រព័ន្ធទី ០១ | ៩.០០៨.៥៩២,៣៨ | ២.១២៩.៨៨៩,៥៥ | ៦.៦៣០.១៣២,៤១ | ៤,២៣ |
| ២ | ប្រព័ន្ធទី ០២ | ៦.៣៩៤.៤០៤,៧៦ | ២.៦១៦.៣៩៩,៩៩ | ៣.៧៧៨.០០៤,៧៦ | ២,៤៤ |
| ៣ | ប្រព័ន្ធទី ០៣ | ៤.៣១១.២១៧,៤៩ | ១.៦០២.៦៤៨,៣៩ | ២.៥៣៦.៧១៩,៣៥ | ២,៦៩ |
| ៤ | ប្រព័ន្ធទី ០៤ | ៥.៧១៥.៣៩៤,៤៤ | ២.១៣៧.០៦០,០០ | ៣.៥៥៤.៨៩០,០០ | ២,៦៧ |
| ៥ | ប្រព័ន្ធទី ០៥ | ៣.៨៩៤.២៨៥,៧១ | ១.១៣១.១៧៨,៥៦ | ២.៧៦៣.១០៧,១៤ | ៣,៤៤ |

ប្រភពៈទិន្នន័យវិភាគ

លទ្ធផលនៃការវិភាគប្រព័ន្ធសេដ្ឋកិច្ចនីមួយៗ ឃើញថាប្រព័ន្ធទី០១ ទទួលបានប្រាក់ចំណេញសុទ្ធខ្ពស់បំផុត៦.៦៣០.១៣២,៤១ រៀល។ រីឯ ប្រព័ន្ធទី០៣វិញ ទទួលបានប្រាក់ចំណេញសុទ្ធទាបបំផុត មានត្រឹមតែ ២.៥៣៦ .៧១៩,៣៥ រៀលប៉ុណ្ណោះ។ ប៉ុន្តែបើយើងក្រលេកមើលទៅលើប្រសិទ្ធភាពសេដ្ឋកិច្ចវិញ មាន ២ ប្រព័ន្ធដែលទទួលបានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់នោះគឺប្រព័ន្ធទី ០១ និងប្រព័ន្ធទី ០៥ ដោយប្រព័ន្ធទី ០១ ទទួលបានប្រសិទ្ធភាពសេដ្ឋកិច្ចរហូតដល់ ៤,២៣ ហើយប្រព័ន្ធទី ០៥ ទទួលបានប្រសិទ្ធភាពសេដ្ឋកិច្ច ៣,៤៤។ ចំនែកឯ ប្រព័ន្ធទី០២ ទទួលបានប្រសិទ្ធភាពសេដ្ឋកិច្ចទាបជាគេទៅវិញ បានត្រឹមតែ ២,៤៤ ដោយសារតែនៅក្នុងប្រព័ន្ធនេះ ចំណាយដុលខ្ពស់ រហូតទៅដល់ ២.៦១៦.៣៩៩,៩៩ រៀល។

## ៤.៣ ការវិភាគ SWOT នៃកម្លាំងពលកម្មស្ត្រីក្នុងតំបន់សិក្សា

ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងកត្តារារាំងនៃកម្លាំងពលកម្មស្ត្រីក្នុងតំបន់សិក្សាត្រូវបានលើឡើងមកបង្ហាញតាមរយៈឧបករណ៍ SWOT មានដូចខាងក្រោមនេះ៖

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| - មានភាពឧស្សាហ៍ព្យាយាម និងការអត់ធ្មត់ខ្ពស់<br>- ស្ត្រីចូលរួមគ្រប់សកម្មភាពមិនប្រកាន់ការងារតូចតាច<br>- ចូលរួមវគ្គបណ្តុះបណ្តាលនានា<br>- មានគំនិតសន្សំសំចៃខ្ពស់<br>- ពូកែចរចារតម្លៃ | - មានកម្លាំងខ្សោយ<br>- ខ្វះចំណេះដឹង មិនសូវចេះអក្សរ<br>- ខ្វះទំនុកចិត្តលើខ្លួនឯង<br>- មិនសូវចូលចិត្តទៅឆ្ងាយ |
| **ឱកាស** | **កត្តារារាំង** |
| - មានការលើកកម្ពស់ និងពង្រឹងសិទ្ធអំណាចស្ត្រី ពីស្ថាប័នរដ្ឋ និងអង្គការក្រៅរដ្ឋាភិបាលនានា<br>- ការផ្តល់ជាជំនួយផ្នែកហិរញ្ញវត្ថុ និងសម្ភារៈគ្រាប់ពូជ កូនមាន់ កូនជ្រូក សម្រាប់អោយស្ត្រីអាចបង្កបង្កើនផលនៅសួនជុំវិញផ្ទះ<br>- ស្ត្រីអាចរកការងារក្រៅកសិកម្មផ្សេងទៀតធ្វើ<br>- ស្ត្រីអាចរកការងារមិនមែនកសិកម្មផ្សេងទៀតធ្វើ ដោយសារនៅក្នុងភូមិមានរមណីយដ្ឋានកែច្នៃបឹងសម្រិត | - ស្ត្រីត្រូវពរពោះ នៅមើលថែកូនតូច និងធ្វើការងារផ្ទះ មិនអាចចូលរួមក្នុងសកម្មភាពកសិកម្មបានច្រើន<br>- កត្តាទំនៀមទំលាប់ប្រពៃណី មិនសូវអោយតម្លៃស្ត្រី<br>- កត្តាគ្រួសារ : ឪពុកម្តាយច្រើនផ្តល់ឱកាសអោយបុរសទទួលការសិក្សាច្រើនជាស្ត្រី<br>- កត្តាសង្គម : អសន្តិសុខក្នុងភូមិដែលរាំងស្ទះមិនអាចទៅណាឆ្ងាយ<br>- ការរីកចម្រើននៃគ្រឿងយន្ត បានកាត់បន្ថយ ឱកាសការងាររបស់ស្ត្រី |

៤.៣.១ ចំណុចខ្លាំង

**ក. ភាពឧស្សាហ៍ព្យាយាម និងការអត់ធ្មត់ខ្ពស់**

តាមរយៈការធ្វើក្រុមពិភាក្សា បានបង្ហាញពីចំណុចខ្លាំងជាច្រើនរបស់ស្ត្រីដែលស្ថិតនៅក្នុងតំបន់សិក្សា។ ទីមួយ ស្ត្រីគឺតមានមានភាពឧស្សាហ៍ព្យាយាម និងការអត់ធ្មត់ខ្ពស់។ ជាក់ស្តែង តាមរយៈការសិក្សាពីការបែងចែកប្រភេទការងាររបស់បុរស និងស្ត្រីនៅក្នុងតំបន់សិក្សារួចមកបានបង្ហាញថា ស្ត្រីអាចធ្វើការងារដែលមានភាពធុញទ្រាន់ និងចំណាយពេលយូរ ឧទាហរណ៍ដូចការ ការកាប់ដំឡូងមី ហាលស្រូវ ច្រូតស្រូវ។ រីឯបុរសច្រើនធ្វើការងារដែលប្រើកម្លាំងធ្ងន់ តែប្រើរយៈពេលខ្លី ឧទាហរណ៍ដូចជា ការងារភ្ជួររាស់ ដឹកជញ្ជូនជាដើម។

**ខ. ស្ត្រីចូលរួមគ្រប់សកម្មភាពមិនប្រកាន់ការងារតូចតាច**

ស្ត្រីចូលរួមធ្វើគ្រប់សកម្មភាពមិនប្រកាន់ការងារតូចតាច ឬការងារធំដំនោះទេ។ ភាគច្រើនការងារដាំដុះបន្លែ ដំណាំហូបផ្លែ ចិញ្ចឹមសត្វនៅផ្ទះតិចតួចច្រើនជាស្ត្រីចូលរួម។ ថ្វីត្បិតការងារទាំងអស់នេះមិនទទួលបានប្រាក់ចំណូលជាធំដុំ ប៉ុន្តែ ការដាំដំណាំ និងចិញ្ចឹមសត្វជុំវិញផ្ទះជួយការបន្ថយចំណាយក្នុងគ្រួសារទៅលើម្ហូបអាហារប្រចាំថ្ងៃ។ ទីបី ស្ត្រីមានពេលវេលានៅផ្ទះច្រើនដោយស្ត្រីមិនសូវទៅធ្វើការងារឆ្ងាយពីផ្ទះ។ ដូច្នេះ ស្ត្រីអាចចូលរួមបានច្រើនក្នុងការបង្កើនផលិតភាពកសិកម្ម ពីសួនជុំវិញផ្ទះ។

**គ. ចូលរួមវគ្គបណ្តុះបណ្តាលនានា**

ដោយស្ត្រីមានពេលទំនេរច្រើន ស្ត្រីបានចូលរួមច្រើនក្នុងសកម្មភាពនានាដូចជាចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗជាច្រើន។ ម្យ៉ាងទៀត បុរសនៅក្នុងតំបន់សិក្សាហាក់ដូចជាមិនមានចំណាប់អារម្មណ៍ក្នុងការចូលរួម ច្រើនជំរុញអោយស្ត្រីជាអ្នកចូលរួមជំនួស។ ជាហេតុធ្វើអោយស្ត្រី អាចទទួលបានចំណេះដឹងថ្មីៗជាច្រើន។

**ឃ. មានគំនិតសន្សំសំចៃខ្ពស់**

លើសពីនេះ ស្ត្រីមានគំនិតសន្សំសំចៃខ្ពស់ ចេះទុកដាក់ ចាយវាយប្រាក់ដែលជួយកាត់បន្ថយការចំណាយក្នុងកសិដ្ឋាន និងក្នុងគ្រួសារ។ ជាទូទៅលុយកាក់នៅក្នុងគ្រួសារស្ត្រីជាអ្នកទុកដាក់។ ប៉ុន្តែរាល់ការចាយវាយនានា ប្រសិនបើចំណាយតិចតួចស្ត្រីជាអ្នកសម្រេចចិត្តដោយខ្លួនឯង។ ចំណែកឯ ចំណាយធំដំ ស្ត្រីនិងបុរសច្រើនពិភាក្សានេះមុនចាយវាយ ហើយបុរសច្រើនជាអ្នកសម្រេចចិត្តក្នុងការ។

**ង. ពូកែចរចារតម្លៃ**

ម្យ៉ាងទៀត ស្ត្រីមានភាពប៉ិនប្រសប់ក្នុងការចរចារតម្លៃ។ រាល់ការលក់ដូរ ភាគច្រើនស្ត្រីជាអ្នកធ្វើដោយស្ត្រីពូកែសំដី ជាងបុរស។

៤.៣.២ ចំណុចខ្សោយ

**ក. មានកម្លាំងខ្សោយ**

យ៉ាងណាមិញ ស្ត្រីមានចំណុចខ្សោយមួយចំនួន។ ទីមួយ ស្ត្រីមានកម្លាំងខ្សោយ មិនអាចធ្វើការងារធ្ងន់ ឬប្រើប្រាស់គ្រឿងយន្តបានដូចបុរស។ ជាហេតុធ្វើអោយគាត់មិនអាចចូលរួមក្នុងសកម្មភាពមួយចំនួនដូចជា ការភ្ជួររាស់ លីសែងរបស់ធ្ងន់ៗជាដើម។

**ខ. ខ្វះចំណេះដឹង មិនសូវចេះអក្សរ**

ទីពីរ ស្ត្រីមិនសូវមានការសិក្សាបានខ្ពស់នោះទេ។ ហេតុនេះហើយវាអាចជះឥទ្ធិពលអាក្រក់ទៅលើការអភិវឌ្ឍន៍សមត្ថភាពរបស់គាត់។ ឧទាហរណ៍ នៅពេលចូលរួមវគ្គបណ្តុះបណ្តាលនានា ដោយគាត់មិនចេះអក្សរ ឬចេះតិចតួចធ្វើអោយកម្រិតនៃការទទួលយករបស់គាត់ទាប មិនសូវយល់ និងការអនុវត្តន៍ក៏មិនបានត្រឹមត្រូវល្អ។

**គ. ខ្វះទំនុកចិត្តលើខ្លួនឯង**

ទីបី គឺការខ្វះទំនុកចិត្តលើខ្លួនឯង។ ស្ត្រីយល់ឃើញថាស្ត្រីមិនអាចមានសមត្ថភាពធ្វើបានល្អដូចបុរស។ ឧទាហរណ៍ដូចជា ការព្រោះស្រូវស្ត្រីយល់ឃើញថាមានតែបុរសទេដែលអាចធ្វើបានល្អ។ ចំណែកស្ត្រីវិញទោះបីជាសាកព្យាយាមធ្វើក៏មិនអាចធ្វើបានល្អ។ យ៉ាងណាមិញ ប្រសិនបើស្ត្រីមានភាពជឿជាក់លើខ្លួនឯង នោះស្ត្រីនឹងអាចធ្វើបានដូចជាបុរសដែរ ព្រោះថាបុរសអាចធ្វើបានល្អដោយសារតែគាត់មានបទពិសោធន៍ធ្វើវារាល់ឆ្នាំ។

**ឃ. មិនសូវចូលចិត្តទៅឆ្ងាយ**

